**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បេសកកម្មរបស់នគរបាលយុត្តិធម៌

ស្រាវជ្រាវចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦


រៀបរៀងដោយ

និស្សិតឈ្មោះ លោក **ភឹខ វិចិត្រ**

សាស្ត្រាចារ្យណែនាំ

លោក **ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលរៀន ២០១២

ឆ្នាំសរសេរសារណា ២០១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **គឹង វិចិត្រ** គឺជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៦ ឆ្នាំសិក្សា ២០១២-២០១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ :

-លោកឪពុក **មុំ ឃ្លី** និងអ្នកម្តាយ **ហេង គ្រុយ** ដែលលោកអ្នកមានគុណទាំងពីរបានបង្កើតរូបរាងកាយ និងចិញ្ចឹមបីបាច់ថែរក្សា ស្រលាញ់ អប់រំទូន្មាន ទំនុកបម្រុងកូនគ្រប់បែបយ៉ាង តាំងពីតូចរហូតដល់ធំ ឱ្យកូនមានឱកាសបានសិក្សារៀនសូត្រចេះដឹងរហូតមកដល់ពេលបច្ចុប្បន្ន ដែលនេះជាគុណូបការៈយ៉ាងអនេកប្បការ និងវិសេសថ្លៃថ្លាជាទីបំផុតក្រៃលែងដែលមិនអាចកាន់ថ្លៃបាន ក្នុងជីវិតកូន ។

-លោកអ៊ុំប្រុស **តាំង ផន** អ៊ុំស្រី **ហេង ណាត្រី** លោកយាយ **ប៉ាន ពូន** និងលោកពូ **ហេង បូរ៉ា** ដែលលោកទាំងបួន តែងតែផ្តល់ទាំង កន្លែងស្នាក់នៅ ថវិការ សម្ភារៈគ្រប់ប្រភេទ និងលើកទឹកចិត្ត យកចិត្តទុកដាក់ ផ្តល់ដំបូន្មានល្អៗ ផ្តល់នូវបទពិសោធន៍ជីវិត ដល់រូបខ្ញុំក្នុងការសិក្សារៀនសូត្រ រហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ ដែលនេះជាគុណដ៏ធំធេង ក្នុងជីវិតខ្ញុំ ។ បើគ្មានរូបលោកទាំងបួនទេ ខ្ញុំក៏មិនអាចសិក្សាបានដល់ចំណុចនេះដែរ ។

-ថ្នាក់ដឹកនាំ លោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់នូវដំបូន្មាន និងបទពិសោធន៍ជាច្រើនដល់រូបខ្ញុំបាទ ដោយមិនខ្វល់ពីការនឿយហត់ ក្នុងគោលបំណងផ្តល់នូវចំណេះដឹងដ៏ច្បាស់លាស់ និងដើម្បីជាប្រទីបក្នុងការបំភ្លឺផ្លូវជីវិតរហូតទៅថ្ងៃអនាគត ។

-ជាពិសេសលោកសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌ** ដែលលោកបានណែនាំ ដឹកនាំ ផ្តល់ដំបូន្មាន ផ្តល់គំណិតយោបល់ជាច្រើន ក្នុងការសរសេរសារណាមួយនេះ រហូតទទួលបានជោគជ័យ ។

ជាចុងបញ្ចប់

**ខ្ញុំសូមបន្ទន់កាយលើកដៃប្រណម្យសំពះ ដល់វត្ថុស័ក្តិសិទ្ធទាំងឡាយទាំងពួង សូមតាមជួយថែរក្សាលោកអ្នកមានគុណទាំងអស់ ឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គលជានិរន្តរ៍!**

# អារម្ភកថា

សារណាអំពី "**បេសកកម្មរបស់នគរបាលយុត្តិធម៌**" ដែលអស់លោក-លោកស្រី កំពុងកាន់នៅក្នុងដៃនេះ គឺជាស្នាដៃថ្មីមួយរបស់ខ្ញុំបាទ ដែលបានចងក្រងរៀបរៀងឡើងនៅឆ្នាំចុងក្រោយនៃការបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ។ វាគឺជាឯកសារមួយដ៏សំខាន់ និងជាជំនួយការដ៏ល្អមួយសម្រាប់ បណ្ដាអ្នកច្បាប់ទាំងឡាយដែលមានដូចជា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា សារការី មេធាវី និសិត្សច្បាប់ នគរបាលយុត្តិធម៌ផ្ទាល់ មន្ត្រីអនុវត្តច្បាប់ ព្រមទាំងអ្នកដែលមានបំណងចង់ដឹងចង់ឮ ពីវិស័យនគរបាលយុត្តិធម៌នេះផងដែរ ។

ខ្ញុំបានប្ដេជ្ញា ខិតខំពុះពារគ្រប់ការលំបាកទាំងឡាយក្នុងការចងក្រងសារណាមួយនេះ ហើយបានព្យាយាមកែលំអរនូវឃ្លាឃ្លោងពាក្យពេចន៍ ដើម្បីបង្កលក្ខណៈឱ្យសាធារណៈជនមានភាពងាយស្រួលក្នុងការយល់អំពីអត្ថន័យ នៃពាក្យបច្ចេកទេសច្បាប់មួយចំនួនដែលត្រូវបានគេប្រើប្រាស់ នៅក្នុងវិស័យព្រហ្មទណ្ឌនេះផងដែរ ។

ជាងនេះទៅទៀត ខ្ញុំមានជំនឿ និងក្ដីសង្ឃឹមយ៉ាងមុតមាំថា ការតាក់តែងសារណាមួយនេះមិនត្រឹមតែអាចចូលរួមចំណែកក្នុង ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យច្បាប់តែប៉ុណ្ណោះទេ ថែមទាំងបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបង្ក្រាប បង្ការ និងទប់ស្កាត់នូវរាល់បទល្មើសទាំងឡាយ ព្រមទាំងអប់រំតាមរយៈខ្លឹមសារក្នុងសារណាមួយនេះ ។ ការបង្អាក់កុំឱ្យមានការប្រព្រឹត្តបទល្មើសនេះ ក៏ជាកត្តាដ៏សំខាន់នៃការពង្រឹង គោលនយោបាយកាត់បន្ថយភាពក្រីក្រ ដោយអ្នកមិនបានប្រព្រឹត្តបទល្មើសហើយក៏មិនត្រូវការថវិការសម្រាប់ជួសជុលព្យសនកម្ម ឬបង់ប្រាក់ពិន័យជាដើម ។

ដោយឡែក ខ្ញុំនឹងទទួលដោយក្ដីសោមនស្សរីករាយ នូវរាល់ការរិះគន់ទាំងឡាយក្នុងន័យស្ថាបនាទៅលើរាល់ពាក្យពេចន៍ទាំងឡាយដែលជាកំហុសអក្ខរាវិរុទ្ធ និងកំហុសអត្ថន័យដោយអចេតនាប្រការណាមួយ ពីព្រោះថា មានតែការរិះគន់ដើម្បីស្ថាបនាទេដែលអាចនាំយើងឆ្ពោះទៅគោលដៅដ៏ច្បាស់លាស់ និងត្រឹមត្រូវបាន ។ សូមអរគុណចំពោះសារធារណៈជនគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ និងគាំទ្រនូវវណ្ណកម្មថ្មីមួយនេះរបស់ខ្ញុំបាទ ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

## ជំពូកទី ១

## សមាសភាពរបស់នគរបាលយុត្តិធម៌

**ផ្នែកទី ១ មន្ត្រីនគរបាលយុត្តិធម៌** ........ ៤

**កថាខណ្ឌ ១ លក្ខខណ្ឌដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌** ........ ៥

១. ការទទួលបានតាមរយៈការប្រឡងប្រជែង ........ ៥

២. ការទទួលបានតាមរយៈឋានន្តរសក្តិនិងមុខងារ ........ ៦

**កថាខណ្ឌ ២ ការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌** ........ ៨

**កថាខណ្ឌ ៣ កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ពេលអនុវត្តមុខងារ** ........ ៨

១. នីតិវិធីវិន័យចំពោះមន្ត្រីនគរបាលយុត្តិធម៌ ........ ៩

២. ទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីនគរបាលយុត្តិធម៌ ........ ៩

៣. ការហាមឃាត់មិនឱ្យបំពេញមុខងារ ........ ៩

**កថាខណ្ឌ ៤ ការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌** ........ ១០

១. សមត្ថកិច្ចដែនដី ........ ១១

២. ការពន្លាតសមត្ថកិច្ចដែនដី ........ ១១

៣. កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច ........ ១១

**ផ្នែកទី ២ ភ្នាក់ងារនគរបាលយុត្តិធម៌** ........ ១២

**កថាខណ្ឌ ១ លក្ខខណ្ឌដើម្បីទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌** ........ ១២

១. នគរបាលជាតិ ........ ១២

២. កងរាជអាវុធហត្ថ ........ ១២

**កថាខណ្ឌ ២ ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌** ........ ១៣

**កថាខណ្ឌ ៣ កំហុសរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ពេលអនុវត្តមុខងារ** ........ ១៣

១. នីតិវិធីខាងវិន័យចំពោះភ្នាក់ងារនគរបាលយុត្តិធម៌ ..... ១៣
២. ទណ្ឌកម្មខាងវិន័យចំពោះភ្នាក់ងារនគរបាលយុត្តិធម៌ ..... ១៤
**កថាខណ្ឌ ៤ ការកំណត់សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ..... ១៤**
**ផ្នែកទី ៣ មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន ..... ១៥**
**កថាខណ្ឌ ១ ការទទួលបាននីតិសម្បទា តាមរយៈច្បាប់ដោយឡែក ..... ១៥**
១. តាមរយៈច្បាប់ស្តីពីគយ ..... ១៥
២. តាមរយៈច្បាប់ស្តីពីព្រៃឈើ ..... ១៦
៣. តាមរយៈច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ..... ១៦
**កថាខណ្ឌ ២ ការតែងតាំង និងការធ្វើសច្ចា ..... ១៧**
**កថាខណ្ឌ ៣ កំហុសមន្ត្រីរាជការ និងភ្នាក់ងារដទៃទៀតពេលអនុវត្តមុខងារ ..... ១៧**
១. នីតិវិធីខាងវិន័យ ..... ១៧
២. ទណ្ឌកម្មខាងវិន័យ ..... ១៨

## ជំពូកទី ២

## ក្របខណ្ឌគតិយុត្តនៃបេសកកម្មរបស់នគរបាលយុត្តិធម៌

**ផ្នែកទី ១ បេសកកម្មរបស់នគរបាលយុត្តិធម៌ក្នុងការពិនិត្យស្វែងរកបទល្មើស ..... ១៩**
**កថាខណ្ឌ ១ ការដឹងពីបទល្មើសដោយខ្លួនឯង ..... ២០**
**កថាខណ្ឌ ២ ការទទួលបានពាក្យបណ្តឹង ..... ២០**
១. បណ្តឹងទាមទារ ..... ២០
២. បណ្តឹងបរិហារ ..... ២០
៣. ការទទួលបណ្តឹងដោយចៃដន្យ ..... ២១
**កថាខណ្ឌ ៣ ការធ្វើកំណត់ហេតុទទួលពាក្យបណ្តឹង ..... ២២**
**កថាខណ្ឌ ៤ ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង ..... ២៣**

**កថាខណ្ឌ ៥ ការបំពានលើសកម្មភាពតុលាការ**..........២៤

**ផ្នែកទី ២ បេសកកម្មរបស់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត**..........២៤

**កថាខណ្ឌ ១ អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង**..........២៥

១. និយមន័យនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង..........២៥

២. កិច្ចនានានៃការស៊ើបអង្កេតនៅក្នុងបទល្មើសជាក់ស្តែង..........៣០

២.១ វិធានការដំបូង..........៣០

២.២ ការឆែកឆេរលំនៅដ្ឋាន..........៣១

២.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង..........៣៣

២.៤ កំណត់ហេតុស្តាប់ចម្លើយ និង ការបញ្ជាឱ្យចូលខ្លួន..........៣៣

២.៥ ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ..........៣៤

២.៦ ការឃាត់ខ្លួន..........៣៤

២.៧ ការបញ្ជូនខ្លួន..........៤០

៣. វិធានការទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង..........៤១

៣.១ ការហាមឃាត់មិនឱ្យស្តាប់ចម្លើយ..........៤១

៣.២ ចិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង..........៤១

៣.៣ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា..........៤១

៣.៤ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ..........៤២

**កថាខណ្ឌ ២ អំណាចក្នុងការស៊ើបអង្កេតបឋម**..........៤៣

១. និយមន័យនៃការស៊ើបអង្កេតបឋម..........៤៣

២. កិច្ចនានាក្នុងការស៊ើបអង្កេតបឋម..........៤៣

២.១ ការបើកការស៊ើបអង្កេតបឋម..........៤៤

២.២ វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម..........៤៤

២.៣ ការឆែកឆេរលំនៅដ្ឋាន និងឆែកឆេររូបរាងកាយ..........៤៥

២.៤ ការបញ្ជាឱ្យចូលខ្លួន និងការឃាត់ខ្លួនជនសង្ស័យ..........៤៦

២.៥ កំណត់ហេតុស្រង់ចម្លើយ និងមោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ..........៤៦

៣. ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលបានចាប់យក..........៤៧

៣.១ អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់ ....... ៤៧
៣.២ ការប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ ....... ៤៨

**ផ្នែកទី ៣ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅពេលមានដីកាចាត់ឱ្យស៊ើបសួរជំនួស** ....... ៤៨

**កថាខណ្ឌ ១ ដីកាចាត់ឱ្យស៊ើបសួរជំនួស** ....... ៤៩
១. មូលហេតុនៃការស៊ើបសួរជំនួស ....... ៤៩

**កថាខណ្ឌ ២ សិទ្ធិអំណាចមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស** ....... ៥០
១. បុព្វសិទ្ធិមន្ត្រីនគរបាលយុត្តិធម៌ ....... ៥០
២. សិទ្ធិអំណាចរបស់មន្ត្រីនគរបានយុត្តិធម៌ក្នុងការកោះហៅ និងស្តាប់ចម្លើយសាក្សី ....... ៥១
៣. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង ....... ៥១
៤. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឃាត់ខ្លួន ....... ៥២
៥. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស្តាប់ទូរស័ព្ទ ជាអាទិ៍ ....... ៥២

**កថាខណ្ឌ ៣ ភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីការបស់តុលាការ** ....... ៥៣
១. ការរក្សាការសម្ងាត់នៃការស៊ើបសួរ ....... ៥៣
២. ការចាប់បង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន ....... ៥៣
៣. ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន ....... ៥៤
៤. ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ....... ៥៤
៥. ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ....... ៥៤
៦. ការអនុវត្តដីកាកោះហៅ ឬដីកាផ្សេងៗទៀត ....... ៥៥

**ផ្នែកទី ៤ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅដំណាក់កាលជំនុំជម្រះ** ....... ៥៦

**កថាខណ្ឌ ១ បេសកកម្មនៅសាលាដំបូងរាជធានី-ខេត្ត** ....... ៥៦
១. ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ....... ៥៦
២. ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម ....... ៥៦
៣. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ ....... ៥៧
៤. ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនតាមរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន ....... ៥៧
៥. ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌ ....... ៥៧

៦. ការធានាសណ្តាប់ធ្នាប់នៃសវនាការ ........ ៥៨
៧. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ........ ៥៨
៨. ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ........ ៥៨

**កថាខណ្ឌ ២ បេសកកម្មនៅសាលាឧទ្ធរណ៍** ........ ៥៨
១. ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ ........ ៥៩
២. ការប្រគល់ដីកាកោះហៅ ........ ៥៩

**កថាខណ្ឌ ៣ បេសកកម្មនៅតុលាការកំពូល** ........ ៥៩

**ផ្នែកទី ៥ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ និងនីតិវិធីដោយខ្សែក** ........ ៦០

**កថាខណ្ឌ ១ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ** ........ ៦០
១. ការធានារ៉ាប់រងការអនុវត្តទោស ........ ៦០
២. ការស្នើសុំពិនិត្យបញ្ជី និងបង្ហាញជនជាប់ឃុំ ........ ៦១
៣. ការជូនដំណឹង ការចាប់ខ្លួន និងឃុំខ្លួនទណ្ឌិតក្នុងករណីបង្ខំដល់រូបរាងកាយ ........ ៦១

**កថាខណ្ឌ ២ បេសកកម្មនៅដំណាក់កាលនីតិវិធីដោយខ្សែក** ........ ៦២

## ជំពូកទី ៣

## បេសកកម្មរបស់នគរបាលយុត្តិធម៌នៅកន្លែងកើតហេតុ

**ផ្នែកទី ១ បេសកកម្មទៅកាន់កន្លែងកើតហេតុ** ........ ៦៣

**កថាខណ្ឌ ១ គោលបំណងនៃការស៊ើបអង្កេតកន្លែងកើតហេតុ** ........ ៦៣

**កថាខណ្ឌ ២ ដំណើរទៅកាន់កន្លែងកើតហេតុ** ........ ៦៤

**កថាខណ្ឌ ៣ ប្រតិបត្តិការនៅកន្លែងកើតហេតុ** ........ ៦៥
១. ការចាត់ចែងបឋមនៅកន្លែងកើតហេតុ ........ ៦៥
២. វិធានការសណ្តាប់ធ្នាប់សាធារណៈ ........ ៦៦
៣. ការពិនិត្យកន្លែងកើតហេតុ និងទីកន្លែងជុំវិញ ........ ៦៨

**កថាខណ្ឌ ៤ តួនាទី និងការទទួលខុសត្រូវនៅកន្លែងកើតហេតុ** ........ ៦៩

១. មន្ត្រីកាន់កាប់បញ្ជីកត់ត្រានៅកន្លែងកើតហេតុ ...... ៦៩
២. មន្ត្រីថតរូប ឬថតវីដេអូនៅកន្លែងកើតហេតុ ...... ៧០
៣. មន្ត្រីគំនូសប្លង់កន្លែងកើតហេតុ ...... ៧១
៤. មន្ត្រីឆែកឆេរ និងរឹបអូស ...... ៧១
៥. មន្ត្រីគ្រប់គ្រងវត្ថុតាង ...... ៧២

**ផ្នែកទី ២ បច្ចេកទេសក្នុងការប្រមូល និងរក្សាទុកវត្ថុតាង ...... ៧៣**

**កថាខណ្ឌ ១ ការប្រមូលវត្ថុតាងជាសំលៀកបំពាក់ ...... ៧៣**

**កថាខណ្ឌ ២ ការប្រមូលវត្ថុតាងជាឯកសារ ...... ៧៥**

**កថាខណ្ឌ ៣ ការប្រមូលវត្ថុតាងជាអេឡិចត្រូនិក ...... ៧៦**

**កថាខណ្ឌ ៤ ការប្រមូលវត្ថុតាងជាវត្ថុដែលមុតស្រួច ...... ៧៦**

**កថាខណ្ឌ ៥ ការប្រមូលវត្ថុតាងជាស្លាកស្នាមផ្សេងៗ ...... ៧៧**

**កថាខណ្ឌ ៦ ការប្រមូលភស្តុតាងជាស្នាមម្រាមដៃ ...... ៧៧**

**កថាខណ្ឌ ៧ ការប្រមូលភស្តុតាងជា ឌី អ៊ិន អេ** (DNA) ...... ៨០
១. សញ្ញាណទូទៅនៃ ឌី អ៊ិន អេ (DNA) ...... ៨០
២. ការប្រមូល និងថែរក្សា ឌី អ៊ិន អេ (DNA) ...... ៨១

**កថាខណ្ឌ ៨ ការបិទកន្លែងកើតហេតុ ...... ៨៣**
១. ការបិទកន្លែងកើតហេតុជាស្ថាពរ ...... ៨៣
២. ការបិទកន្លែងកើតហេតុជាបណ្តោះអាសន្ន ...... ៨៤
២.១ ការបិទផ្លុំបេ ...... ៨៤
២.២ ការដាក់កម្លាំងការពារ ...... ៨៤

**កថាខណ្ឌ ៩ ការគ្រប់គ្រងកំណាត់ហេតុ ...... ៨៤**

**ផ្នែកទី ៣ បេសកកម្មក្នុងការស្វែងរកជនល្មើស ...... ៨៦**

**កថាខណ្ឌ ១ ការស្វែងរកតាមរយៈការសម្ភាសន៍សាក្សី និងជនរងគ្រោះ ...... ៨៦**

**កថាខណ្ឌ ២ ការស្វែងរកតាមរយៈការស្ទបចម្លើយជនសង្ស័យ**..................................................... ៨៦

**កថាខណ្ឌ ៣ ការស្វែងរកតាមរយៈការស្ទង់មតិតាមផ្ទះ**..................................................... ៨៦

**កថាខណ្ឌ ២ ការការពារសាក្សី**..................................................... ៨៧

១. មូលហេតុនៃការការពារសាក្សី ..................................................... ៨៧

២. វិធានការណ៍ក្នុងការពារសាក្សី ..................................................... ៨៨

**សេចក្តីសន្និដ្ឋាន**..................................................... ៨៩

**អនុសាសន៍** ..................................................... ៩២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

មនុស្សគឺជា សភាវគតិមួយប្រភេទដែលមានវិចារណញ្ញាណ ខុសពីសភាវគតិដទៃទៀត ។ ពោល គឺ មនុស្សមានគំនិតបញ្ញា ស្មារតី សតិអារម្មណ៍ ចេះស្វែងរក អភិវឌ្ឍន៍ឱ្យមាននូវអ្វីដែលថ្មីដែលខុសប្លែក ចេះឈឺចាប់ ចេះទុក្ខសោក និងចេះសងសឹកចំពោះការឈឺចាប់ដែលខ្លួនទទួលរងគ្រោះពីសំណាក់ការបំពារបំពានអ្វីមួយ ។ កាលពីសម័យបុរាណ មនុស្សចូលចិត្តរស់នៅជាលក្ខណៈសហគមន៍ប្រមូលផ្តុំគ្នាដែលវាជាលក្ខណៈធម្មជាតិរបស់មនុស្ស ហើយការរស់នៅនោះ ជានិច្ចជាកាលតែងតែកើតមាននូវការឈ្លោះទាស់ទែងគ្នាដោយសារតែការចង់បានអ្វីមួយ ចង់ឈ្នះ ចង់ចាញ់ ឬចង់បានការគោរពកោតខ្លាចពីអ្នកដទៃ ដូចពាក្យគេនិយាយថា សង្គមមនុស្សគឺជាសង្គមឆ្កែចចក មានន័យថាមនុស្សតែងតែឈ្លោះគ្នា វាយតប់គ្នា ហើយអ្នកដែលមានអំណាចខ្លាំង ឬអ្នកដែលមានមាឌធំជាង ជាអ្នកឈ្នះ រីឯអ្នកដែលមានមាឌតូចជាអ្នកចាញ់ ។ ដោយឃើញស្ថានភាពដ៏អាក្រក់នេះ មនុស្សបានព្រមព្រៀងគ្នារៀបចំជ្រើសរើសនូវបុគ្គលម្នាក់ជាអ្នកដឹកនាំពួកគេ ហើយបង្កើតជាច្បាប់ក្នុងការគ្រប់គ្រងពួកគេទាំងអស់គ្នា នៅពេលដែលនរណាម្នាក់ប្រព្រឹត្តខុសច្បាប់ដែលបានចែងនោះ ជននោះនឹងត្រូវទទួលទណ្ឌកម្មជាកំហិត ដោយមនុស្សទាំងអស់ត្រូវរស់នៅក្រោមសំណាញ់នៃច្បាប់ ។ ទោះជាយ៉ាងនេះក្តី ក៏អំពើល្មើសតែងតែកើតមានឥតឈប់ឈរ ពីសម័យកាលមួយទៅសម័យកាលមួយរហូតដល់ពេលបច្ចុប្បន្ន ដែលជានិច្ចជាកាលវាបង្កជាផលវិបាក និងបង្កើតជាបញ្ហាឈឺក្បាលរាប់មិនអស់នៅក្នុងសង្គមជាតិនីមួយៗ បង្កភាពអសន្តិសុខ អសណ្តាប់ធ្នាប់ គ្មានស្ថេរភាព មនុស្សរស់នៅមានការភ័យខ្លាច ។ល។ ទាំងដែលគេបានបង្កើតក្រុមមនុស្សសម្រាប់បង្ក្រាប និងទប់ស្កាត់អំពើល្មើសទាំងអស់នោះក៏ដោយ ។ ជាទូទៅក្នុងពេលបច្ចុប្បន្ន គេហៅអំពើល្មើស ឬការរំលោភបំពានទាំងអស់នោះថាជា **បទល្មើសព្រហ្មទណ្ឌ** ។

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើរបស់មនុស្សដែលផ្ទុយច្បាប់ រំលោភច្បាប់ ហើយវាបង្កឱ្យមានភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ។ នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្ត គឺគេតែងតែមានវិធានក្នុងការតទល់ និងមាននូវប្រតិកម្មមួយរបស់សង្គមទៅលើជនដែលបានប្រព្រឹត្តបទល្មើសនោះ ។ និយាយឱ្យខ្លី គឺសង្គមនឹងទប់ស្កាត់ បង្ក្រាប ដាក់ទណ្ឌកម្មចំពោះរាល់បទល្មើសទាំងឡាយដែលពេលខ្លះរហូតដល់មានការផ្តន្ទាទោសជនដែលបានប្រព្រឹត្តនោះ ដាក់ពន្ធនាគារអស់មួយជីវិតទៀតផង ។

ដោយឡែក នៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ន នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើង យើងតែងតែយកវិធានមួយហៅថា **ក្រមព្រហ្មទណ្ឌ** ដែលជាច្បាប់សារធាតុ មានចែងពីបទល្មើសទាំងឡាយ ព្រមទាំងទោសសម្រាប់អនុវត្តចំពោះបទល្មើសទាំងនោះ ។ ទទឹងនឹងនេះ ដើម្បីឱ្យវិធានទាំងអស់នោះអនុវត្តទៅបាន យើងក៏បានបង្កើតនូវវិធាននីតិវិធីមួយដែលត្រូវបានគេហៅថា **នីតិវិធីព្រហ្មទណ្ឌ** ។ នៅក្នុងនីតិវិធីព្រហ្មទណ្ឌនេះ គឺបានកំណត់ពី វិធានដែលទាក់ទងទៅនឹងការរៀបចំ ការប្រព្រឹត្តទៅ និងបែបបទនៃកិច្ចនីតិវិធីក្នុងការវិនិច្ឆ័យលើរឿងក្តីព្រហ្មទណ្ឌ ការចោទប្រកាន់បទល្មើស ការស្រាវជ្រាវរកជនល្មើស ការស្វែងរកភស្តុតាង បែបបទនីតិវិធីនៃការជំនុំជម្រះ ព្រមទាំងកំណត់ពីសមត្ថកិច្ចរបស់ស្ថាប័នទាំងឡាយក្នុងការធ្វើប្រតិបត្តិការចាត់ការទៅលើអំពើល្មើសទាំងនោះ ដើម្បីធានានូវប្រសិទ្ធិភាពនៃដំណើរការរបស់តុលាការ ជាពិសេសស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ ទទឹមនឹងនេះ វាក៏ទាក់ទងទៅនឹងការរៀបចំផ្លូវបណ្តឹងតវ៉ាទាំងឡាយ ក៏ដូចជាបែបបទនៃការអនុវត្តទោសព្រហ្មទណ្ឌដែលតុលាការព្រហ្មទណ្ឌជាអ្នកសម្រេចផងដែរ ។

នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ជាទូទៅត្រូវបានគេបែងចែកជា ៤ ដំណាក់កាលធំៗតាមលំដាប់លំដោយ ហើយស្ថាប័ន ឬបុគ្គលដែលមានសមត្ថកិច្ចក្នុងការចាត់ការលើរឿងក្តីនោះ នៅក្នុងដំណាក់កាលនីមួយៗ ក៏មានភាពខុសៗគ្នាផងដែរ ។ ដំណាក់កាលទាំង ៤ (បួន) នោះរួមមាន :

-**ការស៊ើបអង្កេត** ដែលបំពេញដោយនគរបាលយុត្តិធម៌ស្ថិតក្រោមការដឹកនាំដោយព្រះរាជអាជ្ញា ។

-**ការចោទប្រកាន់** ដែលបំពេញដោយព្រះរាជអាជ្ញា ដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប្រទានឱ្យ ។

-**ការស៊ើបសួរ** ដែលបំពេញដោយចៅក្រមស៊ើបសួរ ឬយុត្តាធិការស៊ើបសួរ ។

-**ការជំនុំជម្រះ** ដែលបំពេញដោយចៅក្រមជំនុំជម្រះ ឬយុត្តាធិការជំនុំជម្រះ ។

យើងអាចពិនិត្យឃើញថា មានស្ថាប័នជាច្រើនដែលមានសមត្ថកិច្ចក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ ដែលមានដូចជា ស្ថាប័ន នគរបាលយុត្តិធម៌, ស្ថាប័នអយ្យការ, ស្ថាប័នស៊ើបសួរ, និងស្ថាប័នជំនុំជម្រះ ដែលស្ថាប័ននីមួយៗសុទ្ធតែមានសមត្ថកិច្ច និងបេសកកម្មខុសប្លែកពីគ្នា ។ ប៉ុន្តែ បេសកកម្មរបស់ពួកគាត់ទាំងអស់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ជានិច្ចជាកាលតែងតែមានការពាក់ព័ន្ធគ្នា និងប្រាស្រ័យគ្នាទៅវិញទៅមកក្នុងគោលដៅតែមួយដូចគ្នា គឺធ្វើការបង្ក្រាបរាល់បទល្មើសព្រហ្មទណ្ឌ ធានាសិទ្ធិសេរីភាព និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ។

ដោយឡែក នៅក្នុងវណ្ណកម្មមួយនេះ យើងសូមលើកឡើងតែបេសកកម្មរបស់ស្ថាប័នមួយដែលមានសមត្ថកិច្ចដំបូងបំផុតនៅក្នុងដំណើររឿងក្តីព្រហ្មទណ្ឌមកសិក្សាស្វែងយល់តែប៉ុណ្ណោះ ។ ស្ថាប័ននោះ គឺត្រូវបានគេហៅថា **នគរបាលយុត្តិធម៌** ។ មានចម្ងល់ជាច្រើនបានចោទថា នគរបាលយុត្តិធម៌ ជានរណា ? មានបេសកកម្មអ្វីខ្លះក្នុងដំណើរនៃរឿងក្តីព្រហ្មទណ្ឌ ? ហើយបេសកកម្មរបស់ស្ថាប័ននេះផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ ?

គោលបំណងនៃសារណានេះ គឺចង់រំលេចឱ្យឃើញពីបេសកកម្មសំខាន់ៗ ដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ ដែលជាតួអង្គមានសារៈសំខាន់ណាស់នៅក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ ។ ម៉្យាងវិញទៀត គោលបំណងមួយទៀត គឺដើម្បីឱ្យសាធារណៈជនទូទៅយល់ដឹងពីតម្លៃនៃនគរបាលយុត្តិធម៌ ដែលពួកគាត់បំពេញការងារទាំងឡាយដោយលំបាក មានគ្រោះថ្នាក់ និងហានីភ័យខ្ពស់ក្នុងគោលដៅតែមួយគត់គឺដើម្បីធ្វើឱ្យសង្គមជាតិមានសណ្តាប់ធ្នាប់សន្តិសុខ និងដើម្បីឱ្យប្រជាពលរដ្ឋរស់នៅដោយគ្មានភាពភ័យខ្លាច ធានាសិទ្ធិសេរីភាព ព្រមទាំងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលនេះគឺជាការបេសកកម្មដ៏ធំធេងរបស់នគរបាលយុត្តិធម៌ ។

រចនាសម្ព័ន្ធនៃសារណានេះ យើងនឹងធ្វើការសិក្សាទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌ ដែលត្រូវបានបែងចែកជា ៣ ជំពូកធំៗដូចតទៅ :

**-ជំពូកទី ១ សមាសភាពរបស់នគរបាលយុត្តិធម៌**

**-ជំពូកទី ២ ក្របខណ្ឌគតិយុត្តិនៃបេសកកម្មរបស់នគរបាលយុត្តិធម៌**

**-ជំពូកទី ៣ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅកន្លែងកើតហេតុ**

ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ :

# ជំពូកទី ១

# សមាសភាពរបស់នគរបាលយុត្តិធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានឡាយព្រះហស្តលេខាដោយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ បានចែងបញ្ជាក់យ៉ាងច្បាស់នូវរាល់នីតិវិធីព្រហ្មទណ្ឌ និងបុគ្គល ស្ថាប័នជាច្រើនដែលមានមុខងារតួនាទីក្នុងការប្រតិបត្តិនូវនីតិវិធីទាំងអស់នោះ នៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង ដែលក្នុងនោះយើងពិនិត្យឃើញថា ដំណើរការនៃនីតិវិធីដំបូងបំផុតគឺចេញពី នគរបាលយុត្តិធម៌ ។ សួរថា តើនគរបាលយុត្តិធម៌ជាអ្វី ? មានបេសកកម្មអ្វីខ្លះ ? ជាក់ស្តែង ក្នុងមាត្រា ៥៦ នៃក្រមនេះបានចែងបញ្ជាក់យ៉ាងច្បាស់ ពីបេសកកម្មរបស់នគរបាលយុត្តិធម៌ថា ជាជំនួយការរបស់អំណាចតុលាការ ដែលគាត់មានភារកិច្ចក្នុងការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ។ មុននឹងធ្វើការសិក្សាស៊ីជម្រៅទៅលើ បេសកកម្មរបស់នគរបាលយុត្តិធម៌ ជាដំបូងយើងត្រូវចាំបាច់ស្គាល់ពីរចនាសម្ព័ន្ធ ឬសមាសភាពរបស់នគរបាលយុត្តិធម៌ជាមុនសិន ។ តើនណារខ្លះជានគរបាលយុត្តិធម៌ ? យោង មាត្រា ៥៧ បានចែងបញ្ជាក់ពីសមាសភាពរបស់នគរបាលយុត្តិធម៌ ដែលក្នុងនោះរួមមាន ៣ (បី) ប្រភេទដូចជា :

-មន្ត្រីនគរបាលយុត្តិធម៌

-ភ្នាក់ងារនគរបាលយុត្តិធម៌

-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

ដើម្បីឱ្យកាន់តែច្បាស់លាស់លើចំណុចនេះ យើងនឹងធ្វើការសិក្សាឱ្យបានលម្អិតពី សមាសភាពរបស់នគរបាលយុត្តិធម៌ ដែលយើងនឹងបែងចែកជា ៣ (បី) ផ្នែក ដូចខាងក្រោម :

## ផ្នែកទី ១ មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងផ្នែកទី ១ នេះ យើងនឹងបញ្ជាក់ជូនឱ្យកាន់តែច្បាស់ ថាតើត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះទើបអាចទទួបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ? ហើយបន្ទាប់ពីបំពេញលក្ខខណ្ឌហើយគាត់ ត្រូវធ្វើដូចម្តេចដើម្បីចូលទៅកាន់ដំណែងជាមន្ត្រីនគរបាលយុត្តិធម៌ ? នៅពេលដែលគាត់អនុវត្តមុខងារ

របស់គាត់ ប្រសិនណាគាត់ធ្វើខុស តើនឹងមាននីតិវិធីវិន័យ ឬទណ្ឌកម្មអ្វីខ្លះលើរូបគាត់ ? ម្យ៉ាងវិញទៀត តើគាត់មានសមត្ថកិច្ចក្នុងវិសាលភាពប៉ុណ្ណា ? យើងនឹងលម្អិតលើចំណុចនីមួយៗខាងក្រោម :

**កថាខណ្ឌ ១ លក្ខខណ្ឌដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌**

ដើម្បីក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌសំខាន់ៗ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងនោះយើងនឹងធ្វើការសិក្សាតែទៅលើ លក្ខខណ្ឌចំនួន ២ (ពីរ) ប្រភេទតែប៉ុណ្ណោះ :

**១. ការទទួលបានតាមរយៈការប្រឡងប្រជែង**

ក្នុងន័យនេះ គឺលុះត្រាណាតែ ឆ្លងកាត់ការប្រឡងប្រជែងដើម្បីយកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ជាមុនសិន ទើបអាចក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌បាន ។ ប៉ុន្តែ បុគ្គលដែលមានសិទ្ធិធ្វើការប្រឡងប្រជែងបានលុះត្រាណាតែបុគ្គលនោះបានបំពេញនូវលក្ខខណ្ឌ ដែលបានចែងយ៉ាងច្បាស់ក្នុងមាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យអ្នកប្រឡងប្រជែងបានទាល់តែជា :

-មន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំរើការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងនគរបាលជាតិ ។

-នាយទាហាននៃកងរាជអាវុធហត្ថ ដែលមានបំរើការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំក្នុងកងរាជអាវុធហត្ថ ។

- **វិញ្ញាសាប្រឡង**

ចំពោះវិញ្ញាសាជាមូលដ្ឋាន ក្នុងការប្រឡងប្រជែងមានចែងក្នុងមាត្រា ៦១ រួមមានវិញ្ញាសាវិជ្ជាជីវៈចំនួន ៣ (បី) គឺ :

១. វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ

២. វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ

៣. វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចចែងក្នុងក្រមសីលធម៌ដែលគាត់តែងឡើងដោយអង្គការសហប្រជាជាតិ ។

- **គណៈមេប្រយោគនៃការប្រឡង**

ទាក់ទងនឹងគណៈមេប្រយោគនៃការប្រឡង គឺស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ ។ រីឯសមសភាពគណៈមេប្រយោគដែលពាក់ព័ន្ធនឹងមន្ត្រីនគរបាលជាតិ ឬយោធិនកងរាជអាវុធហត្ថ មានដូចជា :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ (ចំពោះមន្ត្រីនគរបាលជាតិ)

-តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ (ចំពោះយោធិននៃកងរាជអាវុធហត្ថ) ។

រីឯបែបបទនៃការចេញសញ្ញាប័ត្រ គឺត្រូវបានកំណត់ដោយប្រកាសរួម រវាងក្រសួងដែលពាក់ព័ន្ធដែលចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធនោះ និងមានបោះត្រាផង ។[1]

### ២. **ការទទួលបានតាមរយៈឋានន្តរសក្តិនិងមុខងារ**[2]

ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ក៏អាចទទួលបានតាមរយៈឋានន្តរសក្តិ និងមុខងាររបស់ពួកគាត់ផងដែរ ។ បុគ្គលទាំងអស់នោះត្រូវបានផ្តល់គុណសម្បត្តិតាមរយៈ មាត្រា ៦០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមមាន :

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ ។

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាន នាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋាន កណ្តាលសណ្តាប់ ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌនិងស្ថិតក្រោមឱវាទរបស់ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

[1] មាត្រា ៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[2] មាត្រា ៦០ កថាខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាននិង អនុប្រធានផ្នែកនៃ:

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង ។

ច. ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុក ការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា:

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាន នគរបាលស្រុក ខណ្ឌ ។

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធ ជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធ ជាតិផ្ទុះ" ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យ នគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធាន ផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ ។

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើស ព្រហ្មទណ្ឌ" ។

ញ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថដែលទទួលបន្ទុកកិច្ចការ ព្រហ្មទណ្ឌ ។

ដ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុក កិច្ចការព្រហ្មទណ្ឌ ។

ឋ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុក កិច្ចការព្រហ្មទណ្ឌ ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេត បទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់ ។

រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាលនៃនាយទាហាន កងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី ១ ទី ២ និងទី ៣ នៃមាត្រា ៦០ មានភារកិច្ចតែងតាំង មន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណា ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### កថាខណ្ឌ ២ ការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងសាមី រួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញសេចក្តីប្រកាសតែងតាំងរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ មិនទាន់អាចទៅបំពេញមុខងាររបស់នោះបានភ្លាមនោះទេពោលគឺ រាល់ការចូលកាន់តំណែង មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ដាច់ខាតត្រូវតែធ្វើសម្បថជាមុនដែលត្រូវស្បថថា ខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន ។ ដែលសម្បថនេះត្រូវធ្វើឡើងនៅសាលាឧទ្ធរណ៍ ហើយរូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។[3] ប៉ុន្តែមានអញ្ញត្រកម្មនៃសម្បថមួយ ដែលគាត់មិនចាំបាច់ធ្វើទៀតឡើយនៅពេលដែលគាត់ទទួលបាននីតិសប្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត ។

### កថាខណ្ឌ ៣ កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ពេលអនុវត្តមុខងារ

បន្ទាប់ពីបានទទួលយ៉ាងពេញសិទ្ធិជាមន្ត្រីនគរបាលយុត្តិធម៌រួចហើយ ពួកគាត់មានសិទ្ធិអំណាច និងកាតព្វកិច្ចគ្រប់គ្រាន់ ក្នុងការអនុវត្តមុខងារទាំងឡាយរបស់ខ្លួន ដែលក្រមនីតិវិធិព្រហ្មទណ្ឌប្រគល់ឱ្យ ។ យើងដឹងហើយថា ការអនុវត្ត ការប្រព្រឹត្តិកាយវិការរស់នៅប្រចាំថ្ងៃរបស់បុគ្គលគ្រប់រូបតែងតែ

---

[3] គម្រូស្តីពីសម្បថ មាននៅក្នុងឧបសម្ព័ន្ធ

មានកំហុសឆ្គងគេចមិនផុតឡើយ ។ រីឯ ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ក៏ដូច្នេះដែរ ច្បាស់ណាស់អាចនឹងកើតមានកំហុស ។ នៅក្នុងចំណុចនេះផងដែរយើងនឹងធ្វើការសិក្សាទៅលើ ថាតើពេលដែលមន្ត្រីនគរបាលយុត្តិធម៌ ធ្វើខុសក្នុងពេលអនុវត្តនូវមុខងាររបស់ខ្លួន តើនឹងទៅជាយ៉ាងណា ? តើពួកគាត់អាចត្រូវបានគេពិន័យ ឬដាក់ទោសដែរទេ? បើអាច តើមាននីតិវិធីវិន័យអ្វីខ្លះលើពួកគាត់? រាល់ចំណុចទាំងអស់នឹងត្រូវបកស្រាយជូននៅចំណុចខាងក្រោម :

### ១. នីតិវិធីវិន័យចំពោះមន្ត្រីនគរបាលយុត្តិធម៌

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរត្រូវរាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អំពីកំហុសទាំងឡាយដែលប្រព្រឹត្តឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ដូច្នេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ ។ អគ្គព្រះរាជអាជ្ញាអមសាលាដំបូងត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តបន្ទាប់នៃនីតិវិធីវិន័យនេះ ។

### ២. ទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីនគរបាលយុត្តិធម៌

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអ្នកដាក់ទណ្ឌកម្មខាងវិន័យដល់មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើខុស ហើយបណ្តឹងអាជ្ញាគឺនៅតែអាចធ្វើបានចំពោះបទល្មើសដែលគាត់បានប្រព្រឹត្ត ។ នៅពេលដែលគាត់ប្រព្រឹត្តបទល្មើស យុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុកលើរឿងក្តីនោះ ត្រូវតែផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូល ទៅឱ្យយុត្តាធិការផ្សេងចាត់វិធានការវិញបាន ពីព្រោះដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គភាពសាមី ។ ពាក្យសុំដកសិទ្ធិនេះត្រូវធ្វើឡើយដោយព្រះរាជអាជ្ញា ។[4]

### ៣. ការហាមឃាត់មិនឱ្យបំពេញមុខងារ

ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌នោះមានសភាពធ្ងន់ធ្ងរ ដែលមានវិសមិតភាពជាមួយនឹងការបំពេញមុខងារ នោះគាត់មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម :

[4] មាត្រា ៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

១. ហាមជាបណ្តោះអាសន្ននូវការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ។

២. បញ្ឈប់មិនឱ្យបំពេញមុខងារជាស្ថាពរ ។

មុននឹងធ្វើការសម្រេចសេចក្តី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវកោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកនូវសេចក្តីសង្កេតរបស់មន្ត្រីនោះ ។ អ្នកដែលធ្វើខុសនោះអាចរកជំនួយពីមេធាវី ឬទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ។ សេចក្តីសម្រេចពីការហាមឃាត់ ត្រូវតែបញ្ជាក់សំអាងហេតុ ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ ។ សេចក្តីសម្រេចនេះអាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា ។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ អាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ មន្ត្រីនគរបាលយុត្តិធម៌រូបនោះ អាចដាក់ពាក្យប្តឹងតវ៉ាដោយមានសម្អាងហេតុ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើ ក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យប្តឹង ។ សេចក្តីសម្រេចនេះ មិនអាចប្តឹងតវ៉ាបានឡើយ ។ ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ា មន្ត្រីនគរបាលយុត្តិធម៌នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានឡើយ ។ គាត់អាចបំពេញមុខងារវិញបាន ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់ ។ កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានបំពេញ ដោយបំពានសេចក្តីសម្រេចពីការហាមឃាត់របស់ព្រះរាជអាជ្ញានោះ ត្រូវចាត់ទុកជាមោឃៈ ។[5]

## កថាខណ្ឌ ៤ ការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានចែងចាប់ពី មាត្រា ៦៧ ដល់ មាត្រា ៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ចង់ដឹងថាតើសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌មានការប្រព្រឹត្តទៅយ៉ាងដូចម្តេច ? ហើយមានវិសាលភាពកំរិតណា

[5] មាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

? ព្រមទាំងមានអញ្ញត្រកម្មចំពោះសមត្ថកិច្ចដែនដីនេះដែរឬទេ ? ម៉្យាងទៀតបើគាត់អនុវត្តខុសដែនសមត្ថកិច្ចនេះតើនឹងទៅជាយ៉ាងណា? ចម្លើយនឹងត្រូវបានបកស្រាយដូចខាងក្រោម :

### ១. សមត្ថកិច្ចដែនដី

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពរបស់ខ្លួនដែលត្រូវបានចាត់តាំងឱ្យទៅបំរើការងារ ។ នៅភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ ។ សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាល ដែលមន្ត្រីនគរបាលយុត្តិធម៌នោះ ត្រូវបានចាត់តាំងឱ្យទៅបំរើការងារ ។[6]

### ២. ការពន្លាតសមត្ថកិច្ចដែនដី

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ក្នុងករណីស៊ើបអង្កេតបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ។ ក្របខណ្ឌនៃការស៊ើបសួរជំនួស នៅក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចអនុញ្ញាត ឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី ។ ចៅក្រមដែលអនុញ្ញាត ត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ។[7]

### ៣. កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច

វិធាននៃសមត្ថកិច្ចខាងដែនដី គឺមានលក្ខណៈដាច់ខាត់ បើកាលណាមិនបានគោរពតាមនោះទេនោះកិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវចាត់ទុកជាមោឃៈ ។[8]

[6] មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧
[7] មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧
[8] មាត្រា ៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

## ផ្នែកទី ២ ភ្នាក់ងារនគរបាលយុត្តិធម៌

បុគ្គលមួយប្រភេទទៀតដែលយើងនឹងលើកយកមកសិក្សា គឺជាភ្នាក់ងារនគរបាលយុត្តិធម៌ ដែលយើងនឹងលើកយកនូវចំណុចសំខាន់ពី នណាជាភ្នាក់ងារនគរបាលយុត្តិធម៌ ? ត្រូវមានលក្ខខណ្ឌអ្វីខ្លះដើម្បីក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌ ? ហើយមុនចូលកាន់តំណែងជាភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវគោរពនូវនីតិវិធីច្បាប់ដែលបានចែងដូចម្តេច ? បើសិនណាការអនុវត្តមុខងាររបស់គាត់មានកំហុសតើនឹងមានចំណាត់ការអ្វីខ្លះចំពោះគាត់ ? ព្រមទាំង តើសមត្ថកិច្ចដែនដីរបស់គាត់មានវិសាលភាពនៅក្នុងទំហំណាដែរ ? នឹងមានបកស្រាយជូនដូចខាងក្រោម :

### កថាខណ្ឌ ១ លក្ខខណ្ឌដើម្បីទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

បើយើងពិនិត្យមើលទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាមានការបែងចែកបុគ្គលដែលមានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ចំនួន ២ (ពីរ) ប្រភេទ ដែលបុគ្គលទាំងនោះមានដូចខាងក្រោម :

#### ១. នគរបាលជាតិ

នគរបាលជាតិ គឺសំដៅលើបុគ្គលដែលមានចែងក្នុងចំណុច ទី ១ និង ទី ២ ក្នុងមាត្រា ៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលរួមមាន : (១) នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។ (២) ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ ។

#### ២. កងរាជអាវុធហត្ថ

នៅក្នុង ចំណុច ទី ២ និង ទី ៣ ក្នុងមាត្រា ៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺបានបញ្ជាក់ពីបុគ្គលមួយចំនួនដែលសំដៅលើ នាយទាហាននៃកងរាអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ និងមួយទៀត គឺ យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថដែលគាត់មិនមែនបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ។

ដូចនេះ យើងឃើញថាអ្នកទាំងអស់ដែលបានរៀបរាប់ជូនខាងលើ គឺមានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ។ នៅក្នុងវិស័យនគរបាលយុត្តិធម៌ នគរបាលជាតិ និងកងរាជអាវុធហត្ថត្រូវមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៧៦ (បេសកកម្មរបស់នគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលមានដូចជា គាត់ជាជំនួយការរបស់អំណាចតុលាការ និង មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ

បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ។ លើសពីនេះទៅទៀត ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេដែលមានគុណសម្បត្តិជានគបាលយុត្តិធម៌ ។ កិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ ក្នុងពេលបំពេញមុខងារជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។ អង្គភាពនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចថ្នាក់ជាតិ អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

**កថាខណ្ឌ ២ ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ជាការពិតណាស់ មុននិងភ្នាក់ងារនគរបាលយុត្តិធម៌ចូលកាន់ដំណែង និងអនុវត្តមុខងាររបស់ខ្លួន គាត់ត្រូវតែចាំបាច់ធ្វើសម្បថជាមុនសិន ដែលសម្បថនេះផងដែរ យើងឃើញមានចែងក្នុងមាត្រា ៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទីកន្លែងធ្វើសម្បថខុសគ្នា ពីទីកន្លែងធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌ ពោលគឺ ភ្នាក់ងារនគរបាលយុត្តិធម៌ ធ្វើសម្បថនៅចំពោះមុខសាលាដំបូង រីឯ មន្ត្រីនគរបាលយុត្តិធម៌ធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ ។ សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ នេះផងដែរ មិនចាំបាច់ធ្វើឡើងវិញនោះទេ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នៅពេលក្រោយទៀត ។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។[9]

**កថាខណ្ឌ ៣ កំហុសរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ពេលអនុវត្តមុខងារ**

ត្រង់ចំណុចនោះ ក៏មិនសូវខុសគ្នាពី មន្ត្រីនគរបាលយុត្តិធម៌ដែរ ពោលគឺបន្ទាប់ពី ធ្វើការតែងតាំង និងស្បថចូលកាន់ដំណែង ហើយអនុវត្តនូវកិច្ចការរបស់ខ្លួន ប្រសិនបើភ្នាក់ងារនគរបាលយុត្តិធម៌បានប្រព្រឹត្តកំហុស ក្នុងពេលអនុវត្តកិច្ចការនោះ សួរថាតើនឹងមាននីតិវិធីវិន័យយ៉ាងដូចម្តេច ? ហើយមានទណ្ឌកម្មយ៉ាងណាខ្លះលើរូបគាត់ ? បុគ្គល ឬស្ថាប័នណា ដែលមានសិទ្ធិដាក់ទណ្ឌកម្មនោះ ? ដំណោះស្រាយនឹងមានបញ្ជាក់ជូនដូចខាងក្រោម :

**១. នីតិវិធីខាងវិន័យចំពោះភ្នាក់ងារនគរបាលយុត្តិធម៌**

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ត្រូវតែឱ្យដំណឹងជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នូវរាល់កំហុសទាំងឡាយរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានប្រព្រឹត្ត ក្នុងពេលអនុវត្តមុខងាររបស់ ។ ដូច្នេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ

[9] គាត់ត្រូវស្បថថា "បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់"

រដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្ដើមដំណើរការនីតិវិធីវិន័យ ។ អគ្គព្រះរាជអាជ្ញាអមសាលាដំបូងត្រូវបានផ្ដល់ដំណឹងអំពីចំណាត់ការជាបន្តបន្ទាប់នៃនីតិវិធីវិន័យនេះ ។[10]

### ២. ទណ្ឌកម្មខាងវិន័យចំពោះភ្នាក់ងារនគរបាលយុត្តិធម៌

បើយើងពិនិត្យមើលមាត្រា ៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថា ទណ្ឌកម្មខាងវិន័យ គឺត្រូវបានធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដែលរាល់ការដាក់ទណ្ឌកម្មមិនមែនជាឧបសគ្គនៃការធ្វើបណ្ដឹងអាជ្ញាទេ មានន័យថា ប្រសិនបើភ្នាក់ងារនគរបាលយុត្តិធម៌គាត់ធ្វើខុស ប្រព្រឹត្តបទល្មើស គាត់នឹងត្រូវបានគេដាក់ទណ្ឌកម្មព្រមទាំងត្រូវបានគេប្ដឹងពីការប្រព្រឹត្តបទល្មើសនោះផងដែរ ។ កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើស នៅក្នុងការបំពេញមុខងាររបស់ខ្លួន តុលាការកំពូល អាចផ្ទេរអំណាចឱ្យទៅយុត្តាធិការផ្សេងចាត់វិធានការវិញបាន ដើម្បីជាប្រយោជន៍ដល់រដ្ឋបាលតុលាការ ។ ពាក្យសុំដកសិទ្ធិនេះ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ។[11]

### កថាខណ្ឌ ៤ ការកំណត់សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ មានសមត្ថកិច្ចក្នុងការពិនិត្យបទល្មើស និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់ខ្លួន ធ្វើការប្រមូលពត៌មាន ហើយធ្វើជារបាយការណ៍ដែលមានតម្លៃត្រឹមតែជាពត៌មានធម្មតាជូនទៅមន្ត្រីនគរបាលយុត្តិធម៌ ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ភ្នាក់ងារនគរបាលយុត្តិធម៌ជាអង្គនៃការគ្រប់គ្រង និងការអនុវត្តន៍ ។ ចំពោះបេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌គឺ យើងឃើញមានចែងក្នុង មាត្រា ៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបេសកកម្មទាំងនោះរួមមាន : ពិនិត្យបទល្មើសជាអាទិ៍ បទលហុ និង ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ ។ ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ ។ របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតា ។ ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ ពុំអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌ ។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះត្រូវចាត់ទុកជា មោឃៈ ។

ចំពោះបុគ្គលដែលមានសិទ្ធិតែងតាំងភ្នាក់ងារនគរបាលយុត្តិធម៌ គឺរដ្ឋមន្ត្រីដែលជាអាណាព្យាបាលនៃបុគ្គលនោះ មានន័យថា បើមកពីនគរបាលជាតិគឺ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រី

[10] មាត្រា ៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[11] មាត្រា ៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

ក្រសួងយុត្តិធម៌ ជាអ្នកមានសិទ្ធិអំណាចតែងតាំង ។ ប៉ុន្តែបើបុគ្គលនោះមកពី កងរាជអាវុធហត្ថ គឺរដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអ្នកមានសិទ្ធិអំណាចក្នុងការតែងតាំង ។

## ផ្នែកទី ៣ មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន

បុគ្គលចុងក្រោយគេនេះ ដែលទទួលបាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន គឺនឹងត្រូវបានយកមកសិក្សាលំអិតផងដែរ ។ ក្នុងផ្នែកនេះ យើងនឹងបង្ហាញឱ្យឃើញច្បាស់ ថាតើ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈទាំងអស់នោះទទួលបាននីតិសម្បទាយ៉ាងដូចម្តេច ? តាមរយៈអ្វី ? ទៅលើបទល្មើសអ្វី ? អាចអនុវត្តមុខងារទាំងនោះបានចាំបាច់ត្រូវសម្បថដែរឬទេ ? ហើយបើការអនុវត្តរបស់គាត់មានកំហុស ត្រូវមាននីតិវិធីវិន័យយ៉ាងដូចម្តេចចំពោះគាត់ ? ទណ្ឌកម្មយ៉ាងដូចម្តេច ? ដំណោះស្រាយនឹងត្រូវបានលើកយកមកបង្ហាញដូចខាងក្រោម :

### កថាខណ្ឌ ១ ការទទួលបាននីតិសម្បទា តាមរយៈច្បាប់ដោយឡែក

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដែលទទួលបាននីតិសម្បទាពិសេសសម្រាប់ត្រួតពិនិត្យបទល្មើសមួយចំនួន គឺមានផ្សេងៗគ្នាតាមរយៈច្បាប់ជាច្រើន ។ ដោយឡែក ដោយមិនសូវជាមានភាពចាំបាច់យើងសូមលើកយកតែការទទួលបាននីតិសម្បទា តាមរយៈតែច្បាប់ចំនួន ៣ តែប៉ុណ្ណោះ ដែលមានរៀបរាប់ដូចខាងក្រោម :

#### ១. តាមរយៈច្បាប់ស្តីពីគយ

នៅក្នុងចំណុចនេះផងដែរយើងឃើញថា មន្ត្រីគយ ក៏ទទួលបាននូវនីតិសម្បទាជានគរបាលយុត្តិធម៌ផងដែរ តាមរយៈច្បាប់ស្តីពីគយ ត្រង់មាត្រា ៥៨ ។ ក្នុងនោះផងដែរ មន្ត្រីគយដែលបានសច្ចាប្រណិធាន អាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានលុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ មន្ត្រីគយដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសគយតាមដែនសមត្ថកិច្ចរបស់ខ្លួន ។ នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ មន្ត្រីគយត្រូវមានលិខិតបញ្ជា

បេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ លើកលែងតែមានការណែនាំដោយឡែកពីនាយកទីចាត់ការគយ និងរដ្ឋាករ ។[12]

### ២. តាមរយៈច្បាប់ស្តីពីព្រៃឈើ

ជាការពិតណាស់ រដ្ឋបាលព្រៃឈើទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ តាមរយៈច្បាប់ស្តីពីព្រៃឈើ ដែលបានចែងក្នុងមាត្រា ៧៦ ថា រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ ។ ការស្រាវជ្រាវទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ រីឯមាត្រា ៧៧ វិញបានចែងបញ្ជាក់ពីការធ្វើប្រតិបត្តិការបេសកកម្មស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ។ មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធាន បំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន ។[13]

### ៣. តាមរយៈច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ

ក្នុងន័យនេះមានន័យថា អាជ្ញាធរមួយចំនួនត្រូវបានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងគោលដៅទប់ស្កាត់អំពើហិង្សានិងការពារជនរងគ្រោះ ។ ការផ្តល់នីតិសម្បទានេះបានកំណត់ក្នុងមាត្រា ១០ នៃច្បាប់នេះ ដែលចែងថា មន្ត្រីក្រសួងកិច្ចការនារី បំរើការងារលើវិស័យដែលកំណត់ដោយច្បាប់នេះ ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។[14]

---

[12] មាត្រា ៨៨ នៃច្បាប់ស្តីពីគយ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧

[13] មាត្រា ៧៦ និង ៧៧ នៃច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២

[14] មាត្រា ១០ នៃច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារអនីតិជន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

## កថាខណ្ឌ ២ ការតែងតាំង និងការធ្វើសម្បថ

បុគ្គលដែលទទួលបាននូវនីតិសម្បទាពិសេស យើងឃើញថា ការចូលកាន់ដំណែងរបស់ពួកគាត់ក៏មិនសូវជាខុសគ្នាទៅនឹង មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ប៉ុន្មានដែរ ពោលគឺអ្នកដែលមានសិទ្ធិអំណាចក្នុងការតែងតាំងគឺរដ្ឋមន្ត្រីក្រសួងសាមី និងក្រសួងយុត្តិធម៌ ដោយយោងតាមមាត្រា ៨២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងថា " បែបបទ និងនីតិវិធីផ្តល់នីតិសម្បទាត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងដែលពាក់ព័ន្ធ" ។ នេះមានន័យថា បើសិនជាភ្នាក់ងារសាធារណៈ និងមន្ត្រីរាជការនោះធ្វើការនៅក្រសួងរុក្ខាប្រមាញ់ និងនេសាទ ដូច្នេះ រដ្ឋមន្ត្រីក្រសួងរុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវតែងតាំងពួកគាត់ ។ ហើយការតែងតាំងដែលនោះ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចមួយដែលហៅថា "ប្រកាសរួម" រវាងក្រសួងទាំងពីរនោះ ។[15] ទទឹមនឹងនេះ ការដែលអាចបំពេញមុខងាររបស់ខ្លួនបានបានគឺ ចាំបាច់ត្រូវធ្វើសម្បថនៅមុខសាលាដំបូង ដែលមន្ត្រីរាជការ និងភ្នាក់ងារសារណៈដទៃនោះ ពួកគាត់ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ រីឯរូបមន្តនៃពាក្យសម្បថ ត្រូវប្រកាសដោយក្រសួងយុត្តិធម៌ ។[16]

## កថាខណ្ឌ ៣ កំហុសមន្ត្រីរាជការ និងភ្នាក់ងារដទៃទៀតពេលអនុវត្តមុខងារ

ក្នុងចំណុចនេះ យើងនឹងធ្វើការបកស្រាយនីតិវិធីចាត់ការចំពោះកំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារដទៃទៀតក្នុងពេលអនុវត្តមុខងាររបស់ខ្លួន ។ តើមាននីតិវិធីខាងវិន័យអ្វីខ្លះចំពោះកំហុសរបស់ពួកគាត់ ? ម៉្យាងវិញទៀត មានទណ្ឌកម្មខាងវិន័យយ៉ាងណាដែរចំពោះពួកគាត់ពេលមានកំហុស ? យើងនឹងរំលេចចេញឱ្យឃើញច្បាស់ដូចខាងក្រោម :

### ១. នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់ រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារសាធារណៈនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ ដំណឹងអំពីចំណាត់ការបន្តនៃវិន័យ ។

[15] ប្រកាសរួម មាននៅក្នុងឧបសម្ព័ន្ធ

[16] មាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

**២. ទណ្ឌកម្មខាងវិន័យ**

កថាខណ្ឌចុងក្រោយនៃមាត្រា ៨២ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត ។ បើយើងពិនិត្យឱ្យកាន់តែច្បាស់ទៅយើងឃើញថា មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះ គឺត្រូវបានច្បាប់នេះផ្ដល់នីតិសម្បទាក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះយើងអាចសន្និដ្ឋានបានថា នៅពេលដែលពួកគាត់ប្រព្រឹត្តកំហុសក្នុងពេលអនុវត្តមុខងារ គឺគេច្បាស់ជាយកបញ្ញត្តិដែលទាក់ទងទៅនឹងទណ្ឌកម្មចំពោះមន្ត្រីនគរបាលយុត្តិធម៌ មកអនុវត្តផងដែរ ដែលបញ្ញត្តិទាំងអស់នោះ មានចែងចាប់ពី មាត្រា ៦៤ ដល់ មាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ចប់ជំពូកទី ១**

# ជំពូកទី ២

# ក្របខណ្ឌគតិយុត្តនៃបេសកកម្មរបស់នគរបាលយុត្តិធម៌

ជាទូទៅ នៅពេលដែលមានអំពើល្មើសមួយបានកើតឡើងក្នុងសង្គម នោះជនរងគ្រោះ ឬតតិយជនណាផ្សេងអាចនឹងធ្វើការប្តឹងទៅបុគ្គល ឬស្ថាប័នដែលមានសមត្ថកិច្ចដើម្បីដោះស្រាយស្វែងរកយុត្តិធម៌ និងសំណងជម្ងឺចិត្តជូនបុគ្គលដែលរងគ្រោះនៃអំពើល្មើសនោះ ។ ជានិច្ចជាកាល ស្ថាប័នដែលដើរតួនាទីមុនគេបង្អស់ក្នុងការសម្របសម្រួលដល់ការធ្វើបណ្តឹងរបស់ប្រជាពលរដ្ឋនេះ គឺគេសង្កេតឃើញថាជា នគរបាលយុត្តិធម៌ ដែលនៅជិតលំនៅដ្ឋានរបស់ម្ចាស់បណ្តឹងនោះ ។ ប៉ុន្តែ នគរបាលយុត្តិធម៌ផ្ទាល់ ក៏អាចពិនិត្យស្វែងរកបទល្មើសដោយពុំចាំបាច់មានបណ្តឹងពីបុគ្គលណាមួយបានដែរ នៅពេលដែលគាត់ដឹងថាមានអំពើណាមួយកើតឡើងដោយខ្លួនគាត់ ។ បន្ទាប់ពីបានដឹងពីបទល្មើស ឬបានទទួលបណ្តឹងពីបុគ្គលណាមួយរួចហើយ នគរបាលយុត្តិធម៌ នឹងចាប់ផ្តើមនូវបេសកកម្មរបស់ខ្លួនបន្តទៀត ដើម្បីបន្តនីតិវិធីតាមច្បាប់ដែលបានកំណត់ ។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់តុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលនគរបាលយុត្តិធម៌ មានមុខងារ តួនាទី និងបេសកកម្មជាច្រើន នៅស្ទើរតែគ្រប់ដំណាក់កាលនៃនីតិវិធីចំពោះរឿងក្តីព្រហ្មទណ្ឌ ។ អាស្រ័យដូច្នេះហើយ នៅក្នុងជំពូកទី ២ នេះ យើងនឹងធ្វើការសិក្សាទៅលើចំណុចទាំងអស់នោះ ដែលយើងបែងចែកជា ៤ ផ្នែកធំៗ ដូចតទៅ :

## ផ្នែកទី ១ បេសកកម្មរបស់នគរបាលយុត្តិធម៌ក្នុងការពិនិត្យស្វែងរកបទល្មើស

ជាទូទៅ នគរបាលយុត្តិធម៌អាចធ្វើការពិនិត្យស្វែងរកបទល្មើសក្រោមទម្រង់ខុសៗគ្នា ជួនកាលដោយការផ្តួចផ្តើមផ្ទាល់របស់នគរបាលខ្លួនឯង និងជាញឹកញាប់បំផុតដោយការបរិហារពីជនរងគ្រោះហើយយ៉ាងកម្រដោយតតិយជនម្នាក់ដែលពាក់ព័ន្ធ ។ ស្ថិតក្នុងករណីនេះ យើងអាចទាញបានថា ការពិនិត្យស្វែងរកបទល្មើស គឺអាចធ្វើបានតាមរយៈ ពីរចំណុច ខាងក្រោមគឺ ការដឹងពីបទល្មើសដោយខ្លួនឯង និងការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង ។ ប៉ុន្តែ បើពិនិត្យឱ្យលម្អិតទៅយើងឃើញចំណុចមួយទៀត ដែលបានលាក់កំបាំង គឺការទទួលបណ្តឹងដោយចៃដន្យ ។ តើការពិនិត្យស្វែងរកបទល្មើសទាំងបីរបស់នគរបាលយុត្តិធម៌ មានការប្រព្រឹត្តទៅយ៉ាងដូចម្តេច ? យើងនឹងធ្វើការសិក្សាដូចខាងក្រោម :

**កថាខណ្ឌ ១ ការដឹងពីបទល្មើសដោយខ្លួនឯង**

ពាក្យថា ការដឹងពីបទល្មើសដោយខ្លួនឯង មានន័យថា នគរបាលយុត្តិធម៌ផ្ទាល់ដែលជាអ្នកឃើញជួបប្រទះ និងដឹងថាជាបទល្មើសដែលបានកើតឡើង ។ ស្ថិតក្នុងលក្ខខណ្ឌនេះ នគរបាលយុត្តិធម៌នឹងធ្វើកិច្ចការក្នុងការស្វែងរកបទល្មើសនោះដោយខ្លួនឯង ដោយមិនចាំបាច់មានការប្តឹងពីសំណាក់ប្រជាពលរដ្ឋ ឬភាគីជនណាមួយនោះទេ ។ នគរបាលយុត្តិធម៌អាចឈានទៅដល់ការចាប់ខ្លួនចារីកំពុងប្រព្រឹត្ត ឬត្រួតពិនិត្យអត្តសញ្ញាណដែលជាយថាហេតុអាចនាំទៅដល់ការកំណត់អត្ថិភាពនៃបទល្មើស ។[17]

**<u>ឧទាហរណ៍</u>** : ពេលដែលមន្ត្រីនគរបាលយុត្តិធម៌កំពុងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋនៅតាមទីប្រជុំជន ពេលនោះស្រាប់តែមានបទល្មើសកើតឡើង ដែលជនសង្ស័យបានលួចហោប៉ៅជនរងគ្រោះ ។ ឃើញដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌គឺគាត់ពិតជាមានសមត្ថកិច្ចក្នុងការឃាត់ខ្លួនជនសង្ស័យដែលកំពុងប្រព្រឹត្តបទល្មើសនោះបាន ដោយមិនចាំបាច់មានការប្តឹងពីជនរងគ្រោះ ឬភាគីជននោះទេ។

**កថាខណ្ឌ ២ ការទទួលបានពាក្យបណ្តឹង**

ការទទួលបានពាក្យបណ្តឹង គឺមានន័យថា នគរបាលយុត្តិធម៌បានទទួលពាក្យប្តឹងពីសំណាក់ប្រជាពលរដ្ឋ មកស្ថាប័ន ឬអង្គភាពរបស់ខ្លួនអំពីបទល្មើសណាមួយដែលបានកើតឡើងជាអាទិ៍ ដែលបណ្តឹងទាំងនោះត្រូវបានបែងចែកជា ២ (ពីរ) គឺ បណ្តឹងទាមទារ និងបណ្តឹងបរិហារ ។

**១. បណ្តឹងទាមទារ**

បណ្តឹងទាមទារ គឺសំដៅទៅលើបណ្តឹងរបស់ប្រជាពលរដ្ឋ ឬរបស់ជនរងគ្រោះនៅក្នុងបទល្មើសណាមួយនោះ គាត់ប្តឹងទៅស្ថាប័នមានសមត្ថកិច្ច គឺប្តឹងទៅនគរបាលយុត្តិធម៌តែម្តង ដើម្បីទាមទារឱ្យស្ថាប័នមានសមត្ថកិច្ចដោះស្រាយ ឬផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្ត និងទាមទារនូវសំណងការខូចខាត និងជម្ងឺចិត្តដែលបានប្រព្រឹត្តមកលើរូបគាត់ ។

**២. បណ្តឹងបរិហារ**

ពាក្យថាបណ្តឹងបរិហារ គឺសំដៅទៅលើបណ្តឹងវែកមុខបទល្មើស មានន័យថាបង្ហាញ ឬបកអាក្រាតនូវបទល្មើសដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ចគាត់ជាអ្នកមានសិទ្ធិក្នុងការត្រួតពិនិត្យ និងស្វែងរក

[17] សៀវភៅ **និតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល** (អំណោយស្ថានទូតបារាំង) ឆ្នាំ ២០០៩ ត្រង់ទំព័រ ៦៧

ភស្តុតាងនៅក្នុងបទល្មើសដើម្បីចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់ ។ បន្ថែមពីនេះទៅទៀត នៅក្នុងបណ្តឹងបរិហារអាចធ្វើឡើងដោយតតិយជនគឺថា ជនដែលគាត់ដើរ ឬបានដឹងពីបទល្មើសហ្នឹង ហើយគាត់ប្តឹងបរិហារទៅមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចនោះ ។ ឬក៏ជួនកាលបណ្តឹងបរិហារអាចធ្វើឡើងដោយមន្ត្រីសាធារណៈ ដែលច្បាប់យើងកំណត់រួចហើយនៅក្នុងមាត្រា ៤២ ថាមន្ត្រីសាធារណៈមានកាតព្វកិច្ចនៅក្នុងការធ្វើបណ្តឹងបរិហារប្រសិនជាគាត់បានដឹងអំពីបទល្មើសណាមួយ ។

យើងឃើញថា ការទទួលបណ្តឹង គឺអាចទទួលពីបុគ្គលមួយចំនួនដូចជា ទទួលពីសំណាក់ជនរងគ្រោះ គឺបុគ្គលដែលរងគ្រោះ ឬទទួលរងព្យសនកម្ម ដែលគាត់ផ្ទាល់ធ្វើបណ្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌ចាត់ការនូវកិច្ចការហ្នឹង។ ជួនកាលគាត់អាចទទួលបណ្តឹងតាមរយៈតតិយជនដូចបានបញ្ជាក់ជូនខាងលើ ហើយជួនកាលក៏អាចទទួលបានពាក្យបណ្តឹងតាមរយៈរបាយការណ៍របស់ភ្នាក់ងារនគរបាលយុត្តិធម៌ ដែលជាអ្នកជំនួយឱ្យមន្ត្រីនគរបាលយុត្តិធម៌ហ្នឹង។[18] ម៉្យាងវិញទៀត ការពិនិត្យស្វែងរកបទល្មើស ក៏អាចធ្វើឡើងបានតាមប្រភពពាក្យចចាមអារ៉ាមដែលឮមិនដាច់ថាបានកើតឡើងហើយគ្មានការស៊ើបអង្កេត ។

<u>**ឧទាហរណ៍**</u> : ដូចជា រឿងក្តីបំពុល ការទាស់មុខស្នន់ រឿងជួញដូរមនុស្ស ឬការធ្វើបាបអនីតិជន ជាដើម។

### ៣. ការទទួលបណ្តឹងដោយចៃដន្យ

បណ្តឹងមួយចំនួនអាចកើតឡើងដោយចៃដន្យ មានន័យថា នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតលើបទល្មើសមួយ ពេលនោះគាត់ក៏បានរកឃើញពីអត្ថិភាពនៃបទល្មើសមួយផ្សេងទៀតពីបទល្មើសដែលខ្លួនត្រូវបើកការស៊ើបអង្កេត ដែលស្ថានភាពនេះកើតឡើងញឹកញាប់បំផុតក្នុងពេលប្រតិបត្តិ ការឆែកឆេរលំនៅដ្ឋាន ឬការស្តាប់ចម្លើយ ។[19]

<u>**ឧទាហរណ៍**</u> : នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ មន្ត្រីនគរបាលយុត្តិធម៌បានធ្វើការឆែកឆេរលំនៅដ្ឋានរបស់ជនសង្ស័យម្នាក់ដែល ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសគ្រឿងញៀន ។ នៅពេលដែលធ្វើ

[18] ប្រសាសន៍របស់**ឯកឧត្តម ប៊ុន ហុន** អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[19] សៀវភៅ **និតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល** (អំណោយស្ថានទូតបារាំង) ឆ្នាំ ២០០៩ ត្រង់ទំព័រ ៧០

ការឆែរឆេរ មន្ត្រីនគរបាលយុត្តិធម៌ក៏បានរកឃើញនូវអាវុធខុសច្បាប់មួយចំនួន គឺ កាំភ្លើងម៉ាក អាការ ចំនួន ៥ (ប្រាំ) ដើម ។ ពេលនោះអត្ថិភាពនៃបទល្មើសមួយផ្សេងទៀតក៏ត្រូវបានកើតឡើង ហើយត្រូវបើកការស៊ើបអង្កេតលើបទល្មើសថ្មីនោះ ។

**កថាខណ្ឌ ៣ ការធ្វើកំណត់ហេតុទទួលពាក្យបណ្តឹង**

ការងារដំបូងបំផុតបន្ទាប់ពីទទួលបានរាល់ពាក្យបណ្តឹងទាំងឡាយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើនូវ កំណត់ហេតុនៃការទទួលពាក្យបណ្តឹង។ ក្នុងកំណត់ហេតុទទួលពាក្យបណ្តឹងនេះ គឺចាំបាច់ត្រូវតែបញ្ជាក់ពីនិទ្ទេសមួយចំនួនដូចជា៖

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង

-អំពើល្មើសដែលត្រូវបានគេប្តឹង

-ទាក់ទងនិងគុណភាពរបស់អ្នកទទួលពាក្យបណ្តឹងគឺឈ្មោះនិងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌។

ក្នុងករណីដែលអ្នកប្តឹងមិនចេះភាសាខ្មែរ មន្ត្រីនរគបាលយុត្តិធម៌អាចកោះហៅរកអ្នកបកប្រែម្នាក់ដែលត្រូវស្បថតាមជំនឿ ឬសាសនាថា ខ្លួននឹងបកប្រែភាសាឱ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍ ។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការបានឡើយ។[20] ដូច្នេះ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌យកអ្នកបកប្រែដែលមិនឯករាជ្យ ឬជាគ្នាឯង នោះនឹងនាំឱ្យមាននូវមោឃភាពកំណត់ហេតុ។

❖ **បញ្ជីទទួលពាក្យបណ្តឹង**

ដើម្បីធានានូវប្រសិទ្ធិភាព ដើម្បីឱ្យអាជ្ញាធរតុលាការ ជាពិសេសគឺព្រះរាជអាជ្ញាដែលមានតួនាទីសំខាន់ក្នុងការដឹកនាំ សម្របសម្រួលការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ គ្រប់អង្គភាពនគរបាល

[20] មាត្រា ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

យុត្តិធម៌ត្រូវតែមានបញ្ជីទទួលពាក្យបណ្ដឹងមួយ ។ នៅគ្រប់ពេលដែលមានការដាក់ពាក្យប្ដឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសដូចតទៅ៖

-អត្តសញ្ញាណរបស់អ្នកប្ដឹង

-កាលបរិច្ឆេទនៃការដាក់ពាក្យប្ដឹង

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្ដីពីការដាក់ពាក្យប្ដឹង

-ប្រភេទនៃអំពើល្មើស

-ចំណាត់ការលើបណ្ដឹង ថាតើបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ធ្វើការស៊ើបអង្កេតបឋមសិន ។[21]

**កថាខណ្ឌ ៤ ចំណាត់ការបន្ដពីការដាក់ពាក្យប្ដឹង**

បន្ទាប់ពីអនុវត្តនូវកិច្ចមួយចំនួនពេលទទួលពាក្យបណ្ដឹងហើយ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ច ត្រូវចាត់ការលើបណ្ដឹងនោះភ្លាមៗ ដែលត្រូវធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនពាក្យប្ដឹងនោះទៅព្រះរាជអាជ្ញា ពីព្រោះថាមានតែព្រះរាជអាជ្ញាទេដែលជាម្ចាស់នៃបណ្ដឹងអាជ្ញា[22] និងជាអ្នកដឹកនាំសម្របសម្រួលការងាររបស់មន្ត្រីនគរបាលយុត្តិធម៌។ មានករណីមួយចំនួនដែលនគរបាលយុត្តិធម៌មានសិទ្ធិអាចធ្វើការស៊ើបអង្កេតដោយឯកឯង ឬក៏សុំការណែនាំ ពីព្រះរាជអាជ្ញាជាមុនសិន ។ ប៉ុន្តែមានករណីបទឧក្រិដ្ឋ ដែលច្បាប់បានកំណត់ ឱ្យគាត់ចាំបាច់ត្រូវតែសុំការណែនាំពី ព្រះរាជអាជ្ញាគឺជាការចាំបាច់[23] ។ មួយវិញទៀត គឺ ក្នុងមាត្រា ៧៩ កថាខណ្ឌ ៣ បានកំណត់ឱ្យនគរបាលយុត្តិធម៌ពេលដែលទទួលពាក្យបណ្ដឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់សមហេតុផល គាត់ត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញា និងសុំការណែនាំ។ តែចំពោះករណីបណ្ដឹងទាមទារវិញ គឺនគរបាលយុត្តិធម៌គាត់មានជម្រើស។

[21] មាត្រា ៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[22] មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

[23] យោងតាមប្រសាសន៍របស់**ឯកឧត្តម ផូវ សំភី** អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្ដីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### កថាខណ្ឌ ៥ ការបំពានលើសកម្មភាពតុលាការ

ទោះក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់ពាក្យបណ្តឹងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបាននោះទេ ឬលាក់កំណត់ហេតុមិនបញ្ជូនទៅតុលាការ ឬលាក់បំបាំងភស្តុតាងដោយចេតនា ទោះបីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះក៏ដោយ ឬក៏មានការដកពាក្យបណ្តឹងក៏ដោយ ។[24] ពីព្រោះថា ជាគោលការណ៍ បណ្តឹងអាជ្ញា មិនអាចត្រូវបានរលត់ ដោយការសម្របសម្រួលទេ ។[25] ប្រសិនណាបើមន្ត្រីនគរបាលយុត្តិធម៌ បំពានវិធានទាំងនេះ គឺត្រូវចាត់ទុកជាសកម្មភាពមួយដែលបំពាននឹងសកម្មភាពរបស់តុលាការ បំពានលើអាជ្ញាធរតុលាការ នឹងត្រូវចាត់ទុកជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌទាក់ទងនឹងវិធានការស្រាវជ្រាវរកភស្តុតាង ដែលបទល្មើសនេះនឹងត្រូវផ្តន្ទាទោសពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) ទៅ ៦.០០០.០០ (ប្រាំមួយលាន) រៀល ។[26]

## ផ្នែកទី ២ បេសកកម្មរបស់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត

បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើស ត្រូវបានចែងយ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះយើងឃើញមានបែងចែកការស៊ើបអង្កេតជា ២ (ពីរ) ដែលទី ១ គឺ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងទី ២ គឺការស៊ើបអង្កេតបឋម ឬបទល្មើសមិនជាក់ស្តែង ។ ដោយយោងតាមមាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា អំណាចទាំងឡាយដែលចែងឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះ បំរើការក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាបឋម ។ ស្ថិតក្នុងករណីនេះ យើងអាចសន្និដ្ឋានបានថា ការស៊ើបអង្កេតទាំងពីរ ពិតជាមានភាពខុសគ្នាជាច្រើនផងដែរ ។ អាស្រ័យហេតុនេះ យើងនឹងលើកយកនូវចំណុចនីមួយៗ នៃបេសកកម្មក្នុងការស៊ើបអង្កេតទាំងពីរ មកបកស្រាយឱ្យបានក្បោះក្បាយដូចខាងក្រោម :

---

[24] មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[25] មាត្រា ២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[26] មាត្រា ៥៥៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**កថាខណ្ឌ ១ អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង**

នៅពេលមានបទល្មើសមួយបានកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ សំខាន់បំផុតត្រូវកំណត់ថា បទល្មើសនោះជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ។ ពីព្រោះថា បើយើងពិនិត្យមើលលើក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថា នគរបាលយុត្តិធម៌ទទួលបានអំណាចដ៏ធំធេងណាស់ ក្នុងការស៊ើបអង្កេតបទល្មើស បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដោយសម្អាងលើភាពបន្ទាន់នៃការធ្វើសកម្មភាព ដើម្បីបញ្ជាក់ពីភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ប្រមូលភស្តុតាងដែលបន្សល់ទុកនៅនឹងកន្លែងប្រព្រឹត្តបទល្មើស ព្រមទាំងដើម្បីចាប់ខ្លួនចារីសន្មត ។ ភាពបន្ទន់នៅតែមានកាលណាបទល្មើសមួយដែលត្រូវបានប្រព្រឹត្តរួចហើយ តែបានបន្តស្តែងចេញតាមរយៈធាតុសំខាន់ៗ ដូចជា ការស្រែកដេញចាប់របស់សាធារណៈជន ការរកឃើញវត្ថុដែលត្រូវបានលួច ស្លាកស្នាម ឬតម្រុយណាមួយជាដើម ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើកាលៈទេសៈមិនមែនជាបទល្មើសជាក់ស្តែងទេ ហើយគាត់ធ្វើការស៊ើបអង្កេតដោយប្រើអំណាចក្នុងករណីបទល្មើសជាក់ស្តែង នោះអ្វីដែលគាត់បានធ្វើទាំងអប្បាទ្មាន ត្រូវបានទុកជាអសាបង់ ព្រោះជាកម្មវត្ថុនៃការស្នើរសុំមោឃភាព ។ ស្ថិតក្នុងស្ថានភាពនេះ យើងនឹងធ្វើការសិក្សាស៊ីជម្រៅលើចំណុចនីមួយៗ ថាតើ អ្វីទៅជាបទល្មើសជាក់ស្តែង ? តើកិច្ចអ្វីខ្លះដែលមន្ត្រីនគរបាលយុត្តិធម៌ អនុវត្តក្នុងពេលមានបទល្មើសជាក់ស្តែងកើតឡើង ? ព្រមទាំងមានវិធានការអ្វីខ្លះបន្តបន្ទាប់ទៀត ? យើងនឹងធ្វើការបកស្រាយយ៉ាងក្បោះក្បាយដូចខាងក្រោម :

**១. និយមន័យនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង**

មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងបញ្ជាក់ពីករណីផ្សេងៗនៃបទល្មើសជាក់ស្តែងដែលតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបាន។ ដែលក្នុងមាត្រា ៨៦ នេះបានចែងថា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាម។

ត្រូវចាត់ទុកថាជា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង

-បុគ្គលដែលគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះ បានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

លក្ខខណ្ឌមួយទៀតក៏បានបញ្ជាក់ ក្នុងជាបទល្មើសជាក់ស្តែងផងដែរ ដែលបានកំណត់ក្នុងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងបញ្ជាក់ថា ត្រូវចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ ទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់ទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ” ។

<u>**ឧទាហរណ៍**</u>: លោក **កុសល** រស់នៅខេត្ត តាកែវ ហើយគាត់ មានផ្ទះមួយនៅ ខេត្ត ព្រះសីហនុ។ កាលពីអាទិត្យមុន គាត់បានទៅមើលផ្ទះរបស់គាត់ដែលទុកចោលនៅខេត្តព្រះសីហនុ នោះ ។ ពេលគាត់បើកទ្វាផ្ទះគាត់ ក៏ស្រាប់តែប្រទះឃើញសាកសពមួយដែលបានស្លាប់ក្នុងផ្ទះនោះមិនដឹងតាំងពីពេលណា។ ភ្លាមនោះ គាត់ក៏បានរាយការណ៍យ៉ាងរហ័ស ជូនទៅដល់ភ្នាក់ងារនគរបាលយុត្តិធម៌ដែលនៅក្បែរនោះ ។ បន្ទាប់មកទៀត ភ្នាក់ងារនគរបាលយុត្តិធម៌ បានរាយការយ៉ាងលឿនទៅកាន់ភ្នាក់ងារនគរបាលយុត្តិធម៌អំពីបញ្ហាដែលកើតមានឡើង ។ បន្ទាប់ពីទទួលបាលការរាយការណ៍ពីអង្គហេតុនោះហើយ មន្ត្រីនគរបាលយុត្តិក៏បានចុះទៅធ្វើការពិនិត្យ និងធ្វើការឆែកឆេរ ។

ក្នុងករណីនេះយើងឃើញថា អង្គហេតុមិនមែនជាបទល្មើសជាក់ស្តែងនោះទេនៅមុនដំបូង តែដោយសារតែបានគោរពនូវលក្ខខណ្ឌ នៃមាត្រា ៨៨ ពោលគឺ លោក **កុសល** ដែលជាអ្នកកាន់កាប់ទីកន្លែង បានសុំឱ្យភ្នាក់ងារនគរបាលយុត្តិធម៌មកពិនិត្យ ហើយភ្នាក់ងារនេះបានបំពេញនូវលក្ខខណ្ឌក្នុងវាក្យខណ្ឌចុងក្រោយនៃមាត្រា ៨៨ ។ នាំឱ្យ បទល្មើសនេះ បានកែប្រែក្លាយទៅជាបទល្មើសជាក់ស្តែងស្របតាមមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សរុបមក យើងអាចទាញបានថា លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតជាក់ស្តែងមាន ២ គឺ

-តាមរយៈបទល្មើសដែលមានចែងក្នុងមាត្រា ៨៦ និង

-តាមរយៈការចាត់ទុកដូចជាបទល្មើសដែលមានចែងក្នុងមាត្រា ៨៨។

ក្នុងករណីដែលមិនចូលក្នុងលក្ខខណ្ឌ ឬស្ថានភាពដែលមានចែងក្នុងមាត្រាទាំងពីរ ខាងលើទេ កាលណាមន្ត្រីនគរបាលយុត្តិធម៌គាត់ចាប់ផ្តើមធ្វើការស៊ើបអង្កេតជាករណីជាក់ស្តែង ដូចនេះនឹងធ្វើឱ្យមានបញ្ហាដល់កិច្ចនីតិវិធីនៃការស៊ើបអង្កេតរបស់គាត់ គឺមានន័យថា ជាករណីដែលមិនជាក់ស្តែង តែគាត់យកវិធាននៃករណីជាក់ស្តែងមកអនុវត្ត នោះនឹងធ្វើឱ្យកិច្ចស៊ើបអង្កេតរបស់គាត់ទទួលនូវមោឃភាពពីតុលាការ ហើយមិនអាចយកមកធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់បាននោះទេ ។

ដូច្នេះ ដើម្បីឱ្យមានភាពច្បាស់លាស់ យើងនឹងធ្វើការវិភាគឱ្យបានស៊ីជម្រៅអំពីករណីផ្សេងៗដែលមាននៅក្នុងបទល្មើសជាក់ស្តែង :

*ទីមួយ :* **បទល្មើសដែលកំពុងប្រព្រឹត្ត** គឺប្រាកដជានៅក្នុងសម្មតិកម្មដែលបទឧក្រិដ្ឋ ឬបទបជ្ជិមកំពុងត្រូវបានប្រព្រឹត្ត ។ ហើយចារីកំពុងប្រព្រត្តិបទល្មើសអកម្ម ឬអកម្ម ដែលការប្រព្រត្តិបទល្មើសអកម្មត្រូវបានមើលឃើញដោយផ្ទាល់។

<u>**ឧទាហរណ៍**</u> : ចារីត្រូវបានគេឃើញកំពុងបន្លំយករបស់អ្នកដទៃ នៅកន្លែងទីសាធារណៈមួយ។

ដូចនេះ វាគឺជាបទល្មើសជាក់ស្តែងដែលមិនអាចប្រកែកបាន ដែលនគរបាលយុត្តិធម៌មានវត្តមានផ្ទាល់នៅកន្លែងកើតហេតុពេលដែលកំពុងប្រព្រឹត្តអំពើដែលចោទប្រកាន់ ដូចនេះអនុញ្ញាតឱ្យបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែងដែលជាទូទៅមានលក្ខណៈសំគាល់ថា ចារីត្រូវបានគេចាប់ខ្លួនភ្លាមៗ ។ ប៉ុន្តែ ការប្រព្រឹត្តបទល្មើសនេះ ក៏អាចត្រូវកត់សម្គាល់ ដោយសារការមើលឃើញតម្រុយដែលអាចឱ្យគេជឿបានថាមានបទល្មើសកើតឡើង ។ ពីព្រោះថា មានបទល្មើសជាច្រើនដែលនៅពេលកំពុង ប្រព្រឹត្តមិនអាចលេចចេញសកម្មភាពល្មើសភ្លាមៗនោះទេ ។ <u>**ឧទាហរណ៍**</u> : ការកាន់កាប់អាវុធខុសច្បាប់ ការរក្សាទុកគ្រឿងញៀន ជាដើម ដែលយើងមិនអាចដឹងបានថាជាបទល្មើស ។ ស្ថានភាពជាក់ស្តែងលេចឡើង ហើយការស៊ើបអង្កេតករណីជាក់ស្តែងអាចត្រូវបានអនុវត្តលុះត្រាតែ មានតម្រុយស៊ីសង្វាក់នឹងចរិកលក្ខណៈនៃបទល្មើស ។

**បទល្មើសលាក់កំបាំង** ដូចជាបទល្មើសប្រព្រឹត្តក្នុងកន្លែងបិទជិតដែលមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចចូលបាន ដែលធ្វើឱ្យតម្រុយសត្យានុម័តមិនអាចត្រូវបានមើលឃើញ

**ឧទាហរណ៍** : មន្ទីរពិសោធន៍សម្ងួត ឬផលិតផលគ្រឿងញៀន ជាដើម ។ ដែលជាបឋមគាត់ត្រូវធ្វើការស៊ើបអង្កេតបឋមដើម្បី ស្វែងរកតម្រុយសត្យានុម័តដែលអនុញ្ញាតឱ្យគេបើកការស៊ើបអង្កេតជាក់ស្តែង ឬបើកការស៊ើបសួរ ។ ដូចនេះ ករណីជួញដូរគ្រឿងញៀន ក្នុងក្របខណ្ឌស៊ើបអង្កេតជាក់ស្តែង មន្ត្រីនគរបាលអាចធ្វើការឆែកឆេរក្នុងមន្ទីរពិសោធន៍ខុសច្បាប់ បន្ទាប់ពីប្រមូលបានតម្រុយស៊ីសង្វាក់ទៅនឹងចរិតលក្ខណៈនៃបទមជ្ឈិមក្នុងពេលតាមដាន ។ ក្នុងករណីគ្មានតម្រុយ ការសង្ស័យ ឬបណ្តឹងបរិហារអនាមិកណាមួយ ដែលខុសពី លក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ទុកថា មិនបានការ ។ ផ្ទុយទៅវិញ បណ្តឹងបរិហាររបស់ជនរងគ្រោះ គឺជាតម្រុយមួយដ៏សំខាន់ និងជាក់លាក់ ។[27]

*ទីពីរ* : **បទល្មើសដែលទើបនឹងប្រព្រឹត្តរួចភ្លាម** គឺអាចយល់បានថា ក្រោយពេលដែលប្រព្រឹត្តហើយភ្លាមៗតែម្តង ដូចជាគាត់បាញ់គេស្លាប់នៅហ្នឹងកន្លែងតែម្តង ដូចនេះពេលដែលបាញ់គេរួចហើយគឺបទល្មើសបានកើតមានឡើង ម៉្យាងទៀតគាត់បាញ់គេស្លាប់នៅហ្នឹងកន្លែងកើតហេតុ នេះចាត់ទុកថាជាស្ថានភាពដែលទើបតែប្រព្រឹត្តរួចភ្លាម ។

ការលំបាកកើតឡើងនៅពេលដែលក្រមនីតិវិធីព្រហ្មទណ្ឌ ចែងពីសញ្ញាណនៃការគិតរយៈវេលាចន្លោះពេលប្រព្រឹត្តបទល្មើស និងពេលរកឃើញបទល្មើសតែមិនបានបញ្ជាក់ថារយៈពេលនេះមានថេរៈវេលាប៉ុន្មាននោះឡើយ ។ ដូចនេះ អាចមានរយៈពេល ២៤ ម៉ោង តុលាការកំពូលជាអ្នកកំណត់លើចំណុចនេះ ។ ពាក្យបណ្តឹង ឬការត្រួតពិនិត្យបទល្មើស មិនគួរមានគម្លាតឆ្ងាយ ពីអង្គហេតុពេកនោះទេ ដើម្បីកុំឱ្យបាត់បង់បច្ចុប្បន្នភាពនៃរឿងហេតុនោះ ។

*ទីបី* : **ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រជឹង** តាមវចនានុក្រម **សម្តេចព្រះសង្ឃរាជ ជួន ណាត** បានបញ្ជាក់យ៉ាងច្បាស់ថាពាក្យ "ដេញប្រដាប់ចាប់ប្រភឹង" មានន័យសំដៅទៅដល់ការដេញយ៉ាងប្រកិតហើយចាប់បានជនល្មើសនោះតែម្តង ដូច្នេះស្ថានភាពនេះវាជាក់ស្តែងណាស់ និងបញ្ជាក់យ៉ាងច្បាស់ថាក្នុងករណីនេះគឺមិនអាចស្ថិតក្នុងស្ថានភាពដែលគាត់រត់ទៅឆ្ងាយ ហើយបាំងខ្លួនគាត់នោះទេ គឺយើងដេញយ៉ាងប្រកិតជាមួយជនល្មើស ហើយចាប់ជននោះបាននៅក្នុងស្ថានភាពនេះតែម្តង ។

[27] សៀវភៅ**និតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល** (អំណោយស្ថានទូតបារាំង) ឆ្នាំ ២០០៩ ត្រង់ទំព័រ ២៦

*ទីបួន* : **បុគ្គលដែលគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះ បានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស** នេះជាករណីដែលជនណាម្នាក់ត្រូវបានកត់សំគាល់ដោយនគរបាល ឬកងរាជអាវុធហត្ថថា បានប្រព្រឹត្តបទល្មើសថ្មីៗ ដោយសារតែតម្រុយ ឬវត្ថុតាងណាមួយ តែមិនបានឃើញការប្រព្រឹត្តបទល្មើសផ្ទាល់ភ្នែកនោះទេ ។

**<u>ឧទាហរណ៍</u>** : នៅក្នុងករណីមានបទល្មើសរំលោភសេពសន្ថវៈដែលមានការប្រើហិង្សា ដែលគេដឹងថាជនរងគ្រោះត្រូវបាន ជនល្មើសរំលោភបានសម្រេច ហើយមានការប្រើហិង្សាយ៉ាងធ្ងន់ធ្ងរ ដោយអាវុធដូចជា វាយជនរងគ្រោះដោយដំបងដែលបណ្តាលឱ្យបែកក្បាលហូរឈាម ។ ក្រោយពេលពិនិត្យរួច ហើយ នគរបាលយុត្តិធម៌ក៏ចាប់ផ្តើមការស៊ើបអង្កេតបន្តបន្ទាប់ ខណៈនោះនៅតាមដងវិថី គេឃើញមានបុរសម្នាក់ដែលស្ថិតក្នុងសភាពស្លន់ស្លោរ មានដំបងជាប់ជាមួយ ហើយមានការហែកអាវ និងមានប្រឡាក់ឈាម ព្រមទាំងមានស្នាមក្រចកនៅលើមុខ និងខ្លួនប្រាណជាច្រើនកន្លែង។ ដោយសារតែគាត់នៅក្បែរនោះផង ឃើញក្នុងស្ថានភាពបែបនេះ យើងអាចសន្និដ្ឋានដំបូងបានថា គាត់បានប្រព្រឹត្តបទល្មើស ដែលស្ថិតក្នុងប្រភេទបទល្មើសជាក់ស្តែង ។

ស្ថិតក្នុងស្ថានភាពបែបនេះ នគរបាលយុត្តិធម៌ ទទួលបាននូវអំណាចយ៉ាងធំធេង ក្នុងការបើកការស៊ើបអង្កេតជាក់ស្តែង ។ ទទឹមនឹងនេះ មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ពីរយៈពេលនៃការស៊ើបអង្កេតករណីជាក់ស្តែង ដែលមានរហូតដល់ទៅ ៧ (ប្រាំពីរ) ថ្ងៃឯណោះ គឺនៅពេលដែលការតាមដានស៊ើបអង្កេតនោះជាប់ឥតដាច់ ។ រយៈពេលប្រាំពីថ្ងៃនេះ មានន័យថា នៅពេលដែលបទល្មើសមួយបានកើតឡើង បន្ទាប់មកមន្ត្រីនគរបាលយុត្តិធម៌ត្រូវកំណត់ថាតើវាជាបទល្មើសជាក់ស្តែង ឬយ៉ាងណា ? ប្រសិនបើគាត់កំណត់ថាជាបទល្មើសជាក់ស្តែងហើយគាត់ត្រូវចាប់ផ្តើមធ្វើប្រតិបត្តិការដោយគ្មានដីកាអ្វីទាំងអស់ ដោយឥតដាច់រហូតទាល់តែផុត ប្រាំពីរ ថ្ងៃហើយនៅតែមិនអាចសម្រេចជាលទ្ធផល នៅថ្ងៃបន្ទាប់គឺ គេនឹងត្រូវផ្លាស់ប្តូរវាទៅជាការស៊ើបអង្កេតបឋមវិញ ។ ម៉្យាងវិញទៀត នៅក្នុងបទល្មើសជាក់ស្តែងនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា គឺឱ្យតែមានស្ថានភាពដូចបានបញ្ជាក់ជូនក្នុងមាត្រា ៨៦ និង ៨៨ នេះគ្រប់ជនទាំងអស់ដែលបានឃើញជនល្មើស គឺមានសិទ្ធិចាប់ខ្លួន ហើយនាំ

ខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។[28] ការចាប់ខ្លួននេះ មិនអាចចាត់ទុកថាជាការរំលោភលើសិទ្ធិបុគ្គលបានឡើយ ផ្ទុយទៅវិញបើសិនជាជននោះមិនបានប្រព្រឹត្តបទល្មើសជាក់ស្តែង ហើយគេបានចាប់ខ្លួនជននោះ គេនឹងអាចប្រឈមមុខក្នុងនាមជាបុគ្គល ឬមួយជាមន្ត្រី ក៏អាចប្រឈមមុខជាមួយនឹងការផ្តន្ទាទោស ដោយចោទប្រកាន់ពីករណីទាក់ទងនឹងការរំលោភលើសិទ្ធិបុគ្គលដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌជាធរមានដែរ ។

ក្រោយពីបានសិក្សាយ៉ាងស៊ីជម្រៅ អំពីនិយមន័យនៃបទល្មើសជាក់ស្តែងរួចហើយ ជាបន្ទាប់យើងនឹងបន្តធ្វើការសិក្សាទៅលើ កិច្ចទាំងឡាយនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង របស់នគរបាលយុត្តិធម៌ បន្តទៅទៀត ។

### ២. កិច្ចនានានៃការស៊ើបអង្កេតនៅក្នុងបទល្មើសជាក់ស្តែង

ទោះបីជាការស៊ើបអង្កេតត្រូវបានធ្វើឡើងក្រោមរូបភាពណាក៏ដោយ ទាំងបទល្មើសជាក់ស្តែង ការស៊ើបអង្កេត ឬដីកាចាត់ឱ្យស៊ើបសួរជំនួស កិច្ចស្រាវជ្រាវនានាដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ គឺមានលក្ខណៈដូចគ្នាទាំងអស់ ។ ក្នុងនោះ កិច្ចទាំងឡាយដែលទាក់ទងទៅនឹងបទល្មើសជាក់ស្តែងនេះ មានចែងចាប់ពីមាត្រា ៨៥ ដល់ មាត្រា ១១០ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

#### ២.១ វិធានការដំបូង

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធានាការពារថែរក្សាទុកតម្រុយនៃភស្តុតាងទាំងឡាយដែលអាចបាត់បង់ ។ ពួកគាត់អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅឆ្ងាយពីកន្លែងកើតបទល្មើស រហូតទាល់តែបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។ ប្រសិនបើយល់ឃើញថា មានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់ទីកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។ ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) ។ រាល់ការស្រាវជ្រាវពិនិត្យបទល្មើសទាំងឡាយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែ ធ្វើកំណត់ហេតុ ក្នុងការការពិនិត្យរបស់ខ្លួន ។

[28] មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ២.២ ការឆែកឆេរលំនៅដ្ឋាន

មន្ត្រីនគរបាលយុត្តិធម៌ អាចអនុវត្តការឆែកឆេរផ្ទះ និងអគារបាន លុះត្រាតែទទួលបានការផ្ទេរសិទ្ធិពីព្រះរាជអាជ្ញា ។ ការផ្ទេរសិទ្ធិនេះ អាចធ្វើឡើងដោយផ្ទាល់មាត់ ។ នៅពេលដែលនគរបាលយុត្តិធម៌ បានទទួលអំណាចសំខាន់របស់ខ្លួនអាចអនុវត្តការឆែកឆេរដោយចូលរួមពីអ្នកកាន់កាប់ទីកន្លែង ឬម្ចាស់ទីកន្លែង ឬបើសិនជាអ្នកកាន់កាប់ ឬម្ចាស់មិននៅទេ ការឆែកឆេរត្រូវធ្វើឡើងដោយមានវត្តមានសាក្សីពីរនាក់ ដែលចាត់តាំងដោយ មន្ត្រីនគរបាលយុត្តិធម៌ ។ ចំពោះនរគបាល ឬកងរាជអាវុធហត្ថ ដែលជាកងកំលាំងចូលរួមប្រតិបត្តិការក្នុងការឆែកឆេរនោះ មិនអាចធ្វើជាសាក្សីបានទេ ។

ការឆែកឆេរអាចធ្វើឡើងមិនមែនតែនៅក្នុងលំនៅដ្ឋានជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែក៏អាចធ្វើបានចំពោះ បណ្តាជនដែលទំនងជាបានចូលរួមក្នុងបទឧក្រិដ្ឋ ឬកាន់កាប់វត្ថុតាង ឬតម្រុយទាក់ទងនឹងអំពើដែលចោទប្រកាន់ ។ ការឆែកឆេរ ត្រូវតែធ្វើឡើងក្នុងម៉ោងស្របច្បាប់ គឺ ចន្លោះម៉ោង ៦ ព្រឹក ដល់ម៉ោង ១៨ ល្ងាច លើកលែងតែករណីពិសេសដូចខាងក្រោម:

-ករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង)

-ករណីមានសម្រែករកជំនួយពីអគារ ឬទីកន្លែងណាមួយ

-ករណីដែលឆែកឆេរនៅទីកន្លែង ពេលម៉ោងបើកចំហដល់សាធារណជន

<u>**ឧទាហរណ៍**</u> : ទីកន្លែងដែលបើកចំហរពេលយប់ដែលមានដូចជា បនល្បែង កន្លែងផឹកស៊ី ក្លឹបកំសាន្ត

បនពេស្យាចារ្យ ជាដើម ដែលគេអាចធ្វើការឆែកឆេរបាន ពីព្រោះថា វាបានបើកចំហរឱ្យសាធារណៈជននៅពេលយប់ ដែលខុសពីម៉ោង ៦ ព្រឹក ដល់ ៦ ល្ងាច ដូចនេះគេអាចធ្វើការឆែកឆេរដោយមិនគោរពលក្ខខណ្ឌនៃពេលវេលាបាន ។

-ទីតាំងផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន ។ នេះគឺជាវិធានពិសេសមួយក្នុងការឆែកឆេរពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលមិនចាំបាច់គោរពវិធានពេលវេលានោះទេ ។

ទាក់ទងនឹងការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុ ដែលរួមមាន :

-ការផ្ទេរសិទ្ធិរបស់ព្រះរាជអាជ្ញាសម្រាប់ការឆែកឆេរ ដោយបញ្ជាក់ពីកាលបរិច្ឆេទ និងពេលវេលានៃការផ្ទេរសិទ្ធិ ។

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ ម្ចាស់ទីតាំង ឬសាក្សីនីមួយៗ

-បញ្ជី និងការពិពណ៌នាពីវត្ថុដែលរឹបអូស និងទីតាំងរបស់វានៅពេលរកឃើញក្នុងបរិវេណផ្ទះ ។

**មន្ត្រីនគរបាលយុត្តិធម៌ មិនអាចអនុវត្តការឆែកឆេរបានទេ ទៅលើករណី កន្លែងពីរប្រភេទ :**

-*ទី១* : **ពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី** គឺមន្ត្រីនគរបាលយុត្តិធម៌ មិនអាចអនុវត្តការឆែកឆេរនៅការិយាល័យមេធាវី ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចអនុវត្តការឆែកឆេរនេះ នៅចំពោះមុខប្រធានគណៈមេធាវី ប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី ។ ចំណុចនេះគឺជាការការពារមួយ ចំពោះវិជ្ជាជីវៈខាងលើ ដែលមន្ត្រីនគរបាលយុត្តិធម៌មិនអាចបំពានបានឡើយ ។

-*ទី២* : **ពាក់ព័ន្ធនឹងវិជ្ជាជីវៈសារព័ត៌មាន** គឺមន្ត្រីនគរបាលយុត្តធម៌ មិនអាចធ្វើការឆែកឆេរនៅអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ ប្រសិនបើ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរមិនមានវត្តមាន ដើម្បីធានាថា ការឆែកឆេរ នឹងមិនប៉ះពាល់ដល់សេរីភាពសារព័ត៌មាន ឬពន្យាពេលការចុះផ្សាយដោយមិនបានត្រឹមត្រូវនោះទេ ។

ត្រង់ចំណុចនេះមានចំណោទសួរ ថាហេតុអ្វីបានជាចាំបាច់មានព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ចូលរួម នៅពេលធ្វើបេសកកម្មក្នុងការឆែកឆេរនៅក្នុងកន្លែង ទាំងពីរប្រភេទនេះ ? ពីព្រោះថា គាត់ទាំងពីរជាអ្នកធានារ៉ាប់រងក្នុងការឆែកឆេរក្លាយទៅជាការរំលោភបំពាន ដែលជះឥទ្ធិពលនាំឱ្យមានការយឺតយ៉ាវក្នុងការប្រកបវិជ្ជាជីវៈសេរី នូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន ។

<u>**ឧទាហរណ៍**</u> : ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ គាត់ឆែកឆេរដោយបំពាន ពោលគឺគាត់ទៅឆែកឆេរការិយាល័យមេធាវីដោយឯកឯង ។ ក្នុងករណីនេះ ការឆែកឆេរនោះត្រូវបានចាត់ទុកថាជាមោឃៈ បានន័យថា អ្វីដែលទទួលបាននៅក្នុងនីតិវិធីនោះគឺមិនយកជាការបានឡើយ ។

### ២.៣ ការមិនស្លាកបោះត្រាលើវត្ថុតាង

នៅក្នុងក្របខណ្ឌនៃការឆែកឆេរ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌រកឃើញនូវវត្ថុតាងណាមួយដែលគួរឱ្យសង្ស័យ ពួកគាត់មានសិទ្ធិអំណាចក្នុងការចាប់យកវត្ថុតាងនោះបាន ។ ក្រោយពេលដែលគាត់ចាប់យកវត្ថុតាងនោះមកហើយ គាត់ចាំបាច់ត្រូវវេចខ្ចប់ភស្តុតាងនោះទុក ។ នៅពេលចាប់យកវត្ថុតាងគាត់ត្រូវបង្ហាញវត្ថុដែលចាប់បាននោះដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួចគាត់ចាប់យកទៅវេចខ្ចប់ ដោយពេលវេចខ្ចប់ត្រូវធ្វើការបិទស្លាក និងបោះត្រា ដើម្បីរក្សាធានាថាមិនមានការលួចដូរអ្វីនោះឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យកដែលពិពណ៌នាពីវត្ថុតាង និងទីតាំងដែលរកវាឃើញ ។ កំណត់ហេតុចាប់យកត្រូវចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។ គាត់ត្រូវភ្ជាប់ជាមួយនូវកំណត់ហេតុនៃការឆែកឆេរមួយទៀតដែលបញ្ជាក់ឱ្យបានច្បាស់អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជអាជ្ញាគាត់បានផ្តល់ការអនុញ្ញាតឱ្យ ដែលអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

### ២.៤ កំណត់ហេតុស្តាប់ចម្លើយ និង ការបញ្ជាឱ្យចូលខ្លួន

ក្នុងក្របខណ្ឌនៃការស្តាប់ចម្លើយរបស់នគរបាលយុត្តិធម៌ បើសង្កេតមើលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើងឃើញមានគោលការណ៍ចំនួនពីរ ត្រូវបានយកមកអនុវត្តក្នុងការស្តាប់ចម្លើយ ដែលមានចែងក្នុងមាត្រា ៩៣ និងមាត្រា ៩៤ ។

*ទី១* : គ្រប់ការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិក្នុងការកោះហៅបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើសដើម្បីផ្តល់ពត៌មាន និងដកស្រង់ចម្លើយ ។ ដែលគាត់ត្រូវតែធ្វើកំណត់ហេតុគ្រប់ការស្តាប់ចម្លើយ ដែលកំណត់ហេតុនោះត្រូវបញ្ជាក់ពីការពិតនៃការឆ្លើយរបស់ជនដែលពាក់ព័ន្ធនោះ ហើយដែលគ្រប់កំណត់ហេតុនីមួយៗត្រូវតែមានចុះហត្ថលេខា ឬផ្តិតស្រាមដៃរបស់មន្ត្រីនគរបាលយុត្តិធម៌រួមទាំងជនដែលពាក់ព័ន្ធ ឬអ្នកដែលបានស្តាប់ចម្លើយ ។ កិច្ចមុនពេលផ្តិតមេដៃបុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗនូវខ្លឹមសារនៃកំណត់ហេតុ ។ បើកាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុដោយសរសេរថា "បានអានឱ្យស្តាប់ រួចហើយតែបុគ្គលនេះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមដៃទេ" ម្យ៉ាងទៀតរាល់កំហុស

ទាំងឡាយណាដែលមានការឆ្លតលុបក៏ត្រូវមានការចារនិងឯកភាពគ្នាដែរ ។ បើក្នុងករណីអ្នកដែលបានកោះហៅមកមិនចេះភាសាខ្មែរ នោះមន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលបានស្បថទៅតាមប្រពៃណី សាសនា និងជំនឿរបស់ខ្លួន ។ អ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។

*ទី២* : គ្រប់ការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិកោះហៅជនដែលមានផលប្រយោជន៍ដើម្បីមកបំភ្លឺ ឬផ្តល់ព័ត៌មានស្តីពីរឿងហេតុ ។ ក្នុងករណីដែលជននោះរឹងទទឹងមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ព្រោះបញ្ជានេះបានផ្តល់សិទ្ធិអំណាចឱ្យនគរបាលយុត្តិធម៌ក្នុងការកេណ្ឌកំលាំងសាធារណៈ ដើម្បីបង្ខំជននោះឱ្យចូលបង្ហាញខ្លួន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយព្រះរាជអាជ្ញាព្រមទាំងមានបោះត្រាផង ។ ដូច្នេះ កិច្ចទាំងឡាយណាដែលមិនគោរពតាមវិធានដែលមានកំណត់ក្នុងក្រមនីតិវិធីនេះ នឹងនាំឱ្យមានមោឃភាពនូវកំណត់ហេតុរបស់នគរបាលយុត្តិធម៌ក្នុងការស្តាប់ចម្លើយ ។[29]

### ២.៥ ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញថ្នាក់ជាតិដូចមានចែងក្នុងមាត្រា ១៦៣ នោះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។[30]

### ២.៦ ការឃាត់ខ្លួន

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាបានកំណត់ពីការឃាត់ខ្លួននៅក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងចាប់ពីមាត្រា ៩៦ ដល់ មាត្រា ១០២ ។ យើងនឹងធ្វើការសិក្សាទៅលើថាតើការឃាត់ខ្លួនជនណាម្នាក់ត្រូវមានលក្ខខណ្ឌអ្វីខ្លះ ? ហើយនគរបាលយុត្តិធម៌ត្រូវធ្វើដូចម្តេចដើម្បីឱ្យស្របតាមនីតិវិធី និងបទដ្ឋានគតិយុត្តដែលបានចែង ?

[29] សៀវភៅ **នគរបាលយុត្តិធម៌** រៀបរៀងដោយសាស្ត្រាចារ្យ **កៅស៊ីហា** អនុបណ្ឌិតច្បាប់ និងសាស្ត្រាចារ្យច្បាប់ ត្រង់ ទំព័រ ៥៥
[30] មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ២.៦.១ លក្ខខណ្ឌក្នុងការឃាត់ខ្លួន

ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលត្រូវបានសង្ស័យក្នុងការពាក់ព័ន្ធនឹងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានអង្គហេតុពាក់ព័ន្ធ បើសិនជាករណីខាងក្រោមកើតឡើង៖

-សាក្សីបដិសេធមិនផ្តល់ ព័ត៌មាន និង

-បានទទួលលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញាក្នុងការឃាត់ខ្លួនបុគ្គលនោះ។

ដូចនេះយើងអាចទាញបានថា បុគ្គលដែលអាចត្រូវបានឃាត់ខ្លួនមាន ពីរប្រភេទគឺ *ទី១* គឺជាជនដែលត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ។ *ទី២* គឺជាជនដែល មន្ត្រីនគរបាលយុត្តិធម៌ចង់បានព័ត៌មានពីគាត់ តែគាត់ប្រកែកមិនព្រមផ្តល់ព័ត៌មាន ។ នៅពេលដែលឃាត់ខ្លួនបុគ្គលណាមួយភ្លាមមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា គាត់មិនអាចឃាត់ខ្លួនបុគ្គណាម្នាក់ដោយមិនរាយការណ៍ ឬជូនដំណឹងទៅកាន់ព្រះរាជអាជ្ញានោះទេ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់រាល់ភស្តុតាងដែលតម្រូវឱ្យមានការឃាត់ខ្លួន ទៅកាន់ព្រះរាជអាជ្ញាផងដែរ ។

### ២.៦.២ រយៈពេលនៃការឃាត់ខ្លួន

រយៈពេលនៃការឃាត់ខ្លួនជាធម្មតា គឺ ៤៨ ម៉ោង ដែលរយៈពេលនេះត្រូវគិតចាប់ផ្តើមពីពេលដែលបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ត្រូវបានយកទៅដាក់មន្ទីរឃុំឃាំង ឬមកដល់ស្នាក់ការកងរាជអាវុធហត្ថ ឬនគរបាល ទោះបីជាមួយណាមុនក៏ដោយ ។ ដែលច្បាប់អនុញ្ញាតតែចំពោះបទឧក្រិដ្ឋហើយក្នុងលក្ខណថា បុគ្គលដែលបានឃាត់ខ្លួននោះ មានតម្រុយច្រើន ដែលបង្ហាញថាបុគ្គលនោះមានការពាក់ព័ន្ធនឹងបទឧក្រិដ្ឋ ។ ការឃាត់ខ្លួនអាចពន្យាពេលបាន មិនអាចលើសពី ២៤ ម៉ោងបាននោះទេដែលចាំបាច់មានការស្នើសុំការអនុញ្ញាតពីព្រះរាជអាជ្ញា ។ ជាទូទៅនៅពេលដែលមានការស្នើសុំ ព្រះរាជអាជ្ញានឹងធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ថា ការស្នើសុំមានមូលហេតុត្រឹមត្រូវសមហេតុផលដែរឬទេ ? ភាសារច្បាប់ គឺ ពិនិត្យមើលមូលកភាព ដែលមានន័យថា មើលទៅលើលក្ខណៈសមស្របដែរ ឬទេ ? ដែលមិនមែនជាការស្នើសុំពន្យាក្នុងគោលដៅទុច្ចរិត ចង់បំបិទសិទ្ធិសេរីភាពរបស់គេ ចង់ឱ្យគេភ័យខ្លាចដើម្បីសារភាព ពោលគឺសំខាន់មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតម្រុយច្បាស់លាស់ថា បុគ្គលនោះមាន

ពិរុទ្ធភាពពាក់ព័ន្ធនឹងបទល្មើសដែរ ទើបអាចសុំពន្យាពេលឃាត់ខ្លួនក្នុងគោលដៅយកចម្លើយបន្ថែមទៀត ឬចង់បានការស្វែងរកភស្តុតាងផ្សេងៗបន្ថែមទៀតរបស់ខ្លួន ។

ដូចនេះយើងពិនិត្យឃើញថា ការពន្យាពេលនៃការឃាត់ខ្លួនគឺត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចជា[31] :

-មានតម្រុយបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលឃាត់ខ្លួនជានីតិជនក្នុងបទឧក្រិដ្ឋ

-ការពន្យាពេលជាវិធានការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ

-ការអនុញ្ញាតដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។

បន្ទាប់ពីរយៈពេលនេះកន្លងផុតទៅ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែដោះលែងបុគ្គលនោះបើសិនជាមិនមានការអនុញ្ញាតត្រឹមត្រូវណាមួយពីអាជ្ញាធរតុលាការក្នុងការឃុំខ្លួនបន្តទេនោះ ។ ករណីបទមជ្ឈិមនៅពេលដែលភស្តុតាងបញ្ជាក់ថា ជនជាប់ឃុំឃាំងជាពិរុទ្ធជន នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើសំណើសុំពន្យាពេលឃាត់ខ្លួនបើវិធានការនេះចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យាពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើល និងសំរេចចិត្តលើការពន្យាពេលការឃាត់ខ្លួន ។ រាល់ការអនុញ្ញាតពន្យាពេលឃាត់ខ្លួននេះត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរ និងបញ្ចូលទៅក្នុងសំណុំរឿង ។

### ២.៦.៣ អនីតិជនដែលត្រូវបានឃាត់ខ្លួន

យើងបានសិក្សាហើយនៅក្នុងចំណុចពីមុនដែលនិយាយពីការឃាត់ខ្លួនជាលក្ខណៈទូទៅ ដែលវាសំដៅទៅលើបុគ្គលដែលត្រូវបានឃាត់ខ្លួនជា នីតិជន ។ ដោយឡែក ក្នុងចំណុចនេះវិញ យើងនឹងសិក្សាបន្ថែមទៅលើការឃាត់ខ្លួនបុគ្គលដែលជាអនីតិជនវិញម្តង ។ តើអនីតិជនអាចត្រូវបានឃាត់ខ្លួនដែរឬទេ ? តើគេអាចឃាត់ខ្លួនអនីតិជនបានក្នុងរយៈពេលប៉ុន្មាន ? អាចពន្យាបានដែរឬទេ ? យើងនឹងបកស្រាយដូចតទៅ :

[31] សៀវភៅ **នីតិវិធីព្រហ្មទណ្ឌ** លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** បោះពុម្ពឆ្នាំ ២០១៥ ត្រង់ទំព័រ ២០

ក្នុងករណីជនជាប់ឃុំជាអនីតិជន អាចធ្វើបានចំពោះតែអនីតិជននោះមានអាយុចាប់ពី ១៤ ឆ្នាំឡើងតែប៉ុណ្ណោះ។ ការពន្យាពេលការឃាត់ខ្លួនមិនត្រូវបានអនុញ្ញាតទេ ។ ជាទូទៅ អនីតិជនមិនអាចត្រូវបានឃាត់ខ្លួនមានរយៈពេលយូរដូចនីតិជនទេ ។ ចំពោះរយៈពេលនៃការឃាត់ខ្លួន គឺប្រែប្រួលទៅតាមប្រភេទនៃបទល្មើស[32] :

❖ **ចំពោះបទឧក្រិដ្ឋ :**

-អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ គឺ មិនហួសពី ៣៦ ម៉ោង ។

-អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ គឺ មិនហួសពី ៤៨ ម៉ោង ។

❖ **ចំពោះបទមជ្ឈិម :**

-អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ គឺ មិនហួសពី ២៤ ម៉ោង ។

-អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ គឺ មិនហួសពី ៣៦ ម៉ោង ។

ក្នុងចំណុចនេះ កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនពត៌មានតាមគ្រប់មធ្យោបាយដល់ ឪពុកម្តាយ អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។[33]

### ២.៦.៤ សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន

នៅក្នុងចំណុចនេះយើងនឹងសិក្សាថាតើបុគ្គលដែលត្រូវបានឃាត់ខ្លួនបានទទួលនូវសិទ្ធិ និងជំនួយអ្វីខ្លះនៅក្នុងពេល និងបន្ទាប់ពីការឃាត់ខ្លួន ? ដែលសិទ្ធិទាំងនេះយើងឃើញថាបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា ៩៨ និង មាត្រា ៩៩ ។

❖ **សិទ្ធិទទួលបានជំនួយរបស់មេធាវី**

[32] សៀវភៅ **នីតិវិធីព្រហ្មទណ្ឌ** លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** បោះពុម្ភឆ្នាំ ២០១៥ ត្រង់ទំព័រ ២០

[33] មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

បន្ទាប់ពីការឃាត់ខ្លួនរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ បុគ្គលដែលត្រូវបានឃាត់ខ្លួនមានសិទ្ធិសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិនក្នុងរឿងជាមួយ ។ ការជួបសន្ទនាគឺនៅកន្លែងឃាត់ខ្លួនដែលមានរយៈពេលសន្ទនាត្រឹមតែ ៣០ (សាមសិប) នាទី ហើយការសន្ទនានេះត្រូវបានធានាការសម្ងាត់ ។ ក្រោយពេលសន្ទនា ជនដែលបានមកជួបនោះត្រូវធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំនុំរឿង ។[34]

### ❖ សិទ្ធិទទួលបានជំនួយរបស់គ្រូពេទ្យ

មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាអាចសុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលត្រូវបានឃាត់ខ្លួនបានគ្រប់ពេលវេលា ដែលគ្រូពេទ្យត្រូវផ្ទៀងផ្ទាត់មើលថា តើស្ថានភាពនៃបុគ្គលដែលត្រូវបានឃាត់ខ្លួននោះសមស្របនឹងការឃាត់ខ្លួនដែរឬទេ ។ ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះពុំសមស្របនឹងការឃាត់ខ្លួននោះទេ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញា ។ គ្រូពេទ្យត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាព ។ ព្រះរាជអាជ្ញាចុះទៅកន្លែងកើតហេតុផ្ទាល់ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។[35]

### ២.៦.៥ បញ្ជីនៃការឃាត់ខ្លួន

ជាទូទៅ នៅក្នុងកន្លែងនីមួយៗរបស់នគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថដែលសម្រាប់ទទួលជនដែលត្រូវទទួលជនដែលត្រូវបានឃាត់ខ្លួន ត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ។ គ្រប់ការឃាត់ខ្លួនត្រូវមានចុះបញ្ជីដោយមានសេចក្តីដូចតទៅ[36] :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

---

[34] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[35] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[36] មាត្រា ១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលដែលត្រូវបានឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនៃការឃាត់ខ្លួននេះ ត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ ។

**២.៦.៦ កំណត់ហេតុសរុបនៃការឃាត់ខ្លួន**

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចចិត្តរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចចិត្តឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរអំពីសិទ្ធិជំនួយផ្នែកច្បាប់ដែលមានចែងក្នុងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងករណីចាំបាច់ទំនាក់ទំនងជាមួយបុគ្គលដែលត្រូវបានឃាត់ខ្លួនដែលមិនចេះខ្មែរ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ។ ទទឹមនឹងនេះ កិច្ចមួយដែលចាំបាច់ត្រូវតែធ្វើ គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដែលកំណត់ហេតុនេះត្រូវមានចុះសេចក្តីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់ មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុ នៃការឃាត់ខ្លួន

-កាលបរិច្ឆេទ និងម៉ោងដែលបុគ្គលឃាត់ខ្លួន ត្រូវបានឱ្យដំណឹងពីសិទ្ធិជំនួយផ្នែកច្បាប់ក្នុងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-ឈ្មោះអ្នកបកប្រែ ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនត្រូវបានឃាត់ខ្លួនក្រោយពីសាមីខ្លួនបានអានឬបើសាមីខ្លួនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ឬប្រើអ្នកបកប្រែបើសាមីខ្លួនមិនចេះភាសាខ្មែរ ។ បើសិនជាជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

### ២.៧ ការបញ្ជូនខ្លួន

យើងបានសិក្សាហើយថា រយៈពេលនៃការឃាត់ខ្លួនគឺអាចឈានទៅដល់ ៤៨ម៉ោង ហើយបើបទឧក្រិដ្ឋដែលគេយល់ឃើញថាមានតម្រុយអាចពន្យាពេលបាន ២៤ម៉ោងបន្ថែមទៀត តែនេះគឺគ្រាន់តែជារយៈពេលអតិប្បរមាប៉ុណ្ណោះទេ មិនមែនបានន័យថា ទាល់តែគ្រប់ ៤៨ម៉ោងទើបអាចបញ្ជូនខ្លួនគេទៅនោះទេ ។ ក្នុងន័យនេះ គឺមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនជនសង្ស័យតែ ៥ម៉ោង ឬតិចជាងនេះហើយគាត់បញ្ជូនទៅព្រះរាជអាជ្ញាក៏បានដែរ ព្រោះនៅពេលដែលផុតរយៈពេលនេះគាត់ត្រូវតែបញ្ជូនបុគ្គលនោះទៅព្រះរាជអាជ្ញាភ្លាមតែម្តង ។ ដូច្នេះមិនមែនមានន័យថាគ្រប់ការឃាត់ខ្លួនទាល់តែគ្រប់រយៈពេលនេះចាំគេបញ្ជូនគេទៅនោះទេ ។ ដោយមូលហេតុនេះ ពាក់ព័ន្ធនឹងការបញ្ជូនខ្លួន យើងត្រូវសិក្សាទៅលើ ២ ចំណុចដូចខាងក្រោមៈ

#### ២.៧.១ ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

ជាទូទៅ ពេលដែលផុតកំណត់រយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ។ ក្នុងករណីដែលគាត់យល់ឃើញថាមិនមានអ្វីធ្ងន់ធ្ងរនោះទេ ព្រះរាជអាជ្ញាអាចមិនបញ្ជូនបុគ្គលនោះទៅចៅក្រមស៊ើបសួរនោះទេ ដោយគាត់អាចបន្តនីតិវិធីរបស់គាត់ដោយដោះលែងបុគ្គលនោះឱ្យមានសេរីភាពឡើងវិញ ។ សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ថាតើត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ ឬដោះលែងឱ្យមានសេរីភាពវិញ ។[37]

#### ២.៧.២ រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវបានបញ្ជូនខ្លួនទៅព្រះរាជអាជ្ញានោះ បុគ្គលនោះត្រូវបានគេនាំខ្លួនភ្លាមដោយមន្ត្រីនគរបាលយុត្តិធម៌ទៅចំពោះមុខព្រះរាជអាជ្ញា ។ ប្រសិនបើការបង្ហាញខ្លួនមិនអាចធ្វើបានក្នុងថ្ងៃតែមួយដោយមូលហេតុពិសេស ដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ ព្រះរាជអាជ្ញាអាចផ្តល់រយៈពេលបន្ថែមបាន ។ តែការបង្ហាញខ្លួនក្នុងគ្រប់ករណីទាំងអស់ ត្រូវធ្វើឡើងក្នុងរយៈពេលមួយដ៏ឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះកំណត់ហេតុពីមូលហេតុនៃការយឺតយាវហើយប្រគល់ជូនព្រះរាជអាជ្ញា ។[38]

---

[37] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[38] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ៣. វិធានការទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង

នៅក្នុងចំណុចនេះផងដែរ យើងនឹងធ្វើការបង្ហាញពីវិធានមួយចំនួនសំរាប់មន្ត្រីនគរបាលយុត្តិធម៌ ដែលទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង ដែលមានចែងចាប់ពី មាត្រា ១០៥ ដល់ មាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ចង់ដឹងថា ពួកគាត់ត្រូវបានហាមឃាត់អ្វីខ្លះ ? ហើយរយៈពេលនៃការស៊ើបអង្កេតរបស់គាត់គឺប៉ុន្មាន ? បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតហើយ តើគាត់ត្រូវធ្វើដូចម្តេច ? ម៉្យាងវិញទៀត ប្រសិនបើគាត់មិនគោរពនូវវិធានច្បាប់មួយចំនួនដែលបានចែង តើកិច្ចការដែលគាត់បានធ្វើនឹងទៅជាយ៉ាងណា ? យើងនឹងបញ្ជាក់ឱ្យឃើញនៅក្នុងចំណុចខាងក្រោម :

#### ៣.១ ការហាមឃាត់មិនឱ្យស្តាប់ចម្លើយ

អលទ្ធភាពមួយដែលមានចែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ ត្រង់មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលហាមមិនឱ្យមន្ត្រីនគរបាលយុត្តិធម៌មានអំណាចស្តាប់ចម្លើយ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទបានឡើយ ។ ហើយរឹតតែមិនអាច បង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬតាមអិនធើណែតបាននោះទេ ។

#### ៣.២ ចិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង

ចិរវេលានេះនៃស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តជាប់ជានិច្ចនៅក្នុងចិរវេលានេះ ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ថាតើនឹងធ្វើយ៉ាងណាទៀតចំពោះសំនុំរឿងនេះ ? បន្ទាប់មកព្រះរាជអាជ្ញានឹងឆ្លើយតបថាគួរធ្វើបែបណាទៀតជាមិនខាន ។

#### ៣.៣ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។ កាលណាបុគ្គលណាមួយត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូននោះផងដែរ ។

កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌នោះត្រូវចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។ កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ។[39] **ឧទាហរណ៍** : យល់ព្រមឱ្យលុបពាក្យថា **គ** ដោយកែដាក់ថា **ឃ** វិញ និងចុះហត្ថលេខា ។

ដូចដែលបានដឹងហើយថា ជាគោលការណ៍កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។ ចៅក្រមធ្វើមូលវិចារណ៍ដោយសេរីលើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ។[40]

### ៣.៤ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

វិធាន និងទម្រង់ការដែលបានបញ្ញត្តិនៅមាត្រា :

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩១ (ការឆែកឆេរ)

-មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)

-មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)

-មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

-មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)

---

[39] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[40] មាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង) និង

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ មានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។

**កថាខណ្ឌ ២ អំណាចក្នុងការស៊ើបអង្កេតបឋម**

បន្ទាប់ពីបានសិក្សារួចមកហើយ នូវអំណាចរបស់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង ជាបន្តនៅក្នុងចំណុច ទី២ នេះយើងនឹងរៀបរាប់ពី អំណាចស៊ើបអង្កេតមួយទៀតដែលគេហៅថា ការស៊ើបអង្កេតបឋម ឬការស៊ើបអង្កេតបទល្មើសមិនជាក់ស្តែង ។ តើការស៊ើបអង្កេតបឋម ឬមិនជាក់ស្តែងនេះមានអត្ថន័យយ៉ាងណា ? ហើយនីតិវិធីនៃការស៊ើបអង្កេតនេះមានលក្ខណៈយ៉ាងណា ? យើងនឹងរំលេចឡើងឱ្យឃើញច្បាស់ដូចតទៅ :

**១. និយមន័យនៃការស៊ើបអង្កេតបឋម**

បើយើងពិនិត្យមើលទៅក្នុងក្រមនីតិវិធី គឺនីតិនិពន្ធមិនបានឱ្យនិយមន័យថាអ្វីជាការស៊ើបអង្កេតបឋមនោះទេ ។ ភាពបត់បែនដ៏ខ្លាំងនៃការស៊ើបអង្កេតនេះ ធ្វើឱ្យគេអាចនិយាយបានថា ការស៊ើបអង្កេតបឋម គឺជានីតិវិធីរួម ដែលប្រើប្រាស់ដោយមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីដែលគាត់មិនអាច ឬមិនចង់ប្រើប្រាស់នីតិវិធីស៊ើបអង្កេតករណីជាក់ស្តែង និងក្នុងករណីដែលគាត់មិនត្រូវបានចាត់ឱ្យស៊ើបសួរជំនួស ។ បទល្មើសទាំងអស់អាចជាកម្មវត្ថុនៃនីតិវិធីទាក់ទងនឹងរបៀបស៊ើបអង្កេតបឋម លើកលែងតែករណីដែលបទល្មើសទាំងនោះតម្រូវឱ្យមានការបើកការស៊ើបអង្កេតរបស់តុលាការ ដែលដឹកនាំដោយចៅក្រមស៊ើបសួរ ។ ការស៊ើបអង្កេតបឋម គឺជានីតិវិធីមួយដែលមានទម្រង់សាមញ្ញ ដែលវាបានផ្តល់ឱ្យអ្នកស៊ើបអង្កេតនូវអំណាចមួយដែលមានកម្រិត ។[41]

**២. កិច្ចនានាក្នុងការស៊ើបអង្កេតបឋម**

ឆ្លងមកដល់ចំណុចនេះ យើងនឹងលើកយកមកបង្ហាញនូវកិច្ចមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រតិបត្តិក្នុងបេសកកម្មក្នុងការស៊ើបអង្កេតបឋម ឬស៊ើបអង្កេតបទល្មើសមិនជាក់ស្តែង ។

[41] សៀវភៅ **នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល** (អំណោយស្ថានទូតបារាំង) ឆ្នាំ ២០០៩ ត្រង់ទំព័រ ៣១ ចំណុច ៣.១

ហេតុនេះមានសំណួរជាច្រើនបានលើកឡើងថា ការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌ត្រូវយកវិធានអ្វីខ្លះមកអនុវត្ត ? តើវាដូចគ្នានិងខុសគ្នាអ្វីខ្លះរវាងការស៊ើបអង្កេតទាំងពីរ ? ហើយការឆែកឆេរប្រព្រឹត្តទៅយ៉ាងដូចម្តេច ? ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌មិនគោរពវិធានដែលបានចែង តើការស៊ើបអង្កេតរបស់គាត់នឹងទៅជាយ៉ាងណា ? យើងនឹងធ្វើការពន្យល់ដូចតទៅ :

### ២.១ ការបើកការស៊ើបអង្កេតបឋម

គំណិតផ្តួចផ្តើមមានជាចំបងក្នុងមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ តាមការស៊ុំរបស់ព្រះរាជអាជ្ញា ។ ការស៊ើបអង្កេតបឋម អាចដំណើរការបាននៅក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមមិនជាក់ស្តែង ឬក៏ក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុតទៅ ពោលគឺ បើរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បានផុត នោះការស៊ើបអង្កេតបឋមនឹងយកមកអនុវត្តវិញម្តង ។

គួរកត់សំគាល់ថា មន្ត្រីនគរបាលយុត្តិធម៌អាចសម្រេចធ្វើការស៊ើបអង្កេតតាមទម្រង់នៃការស៊ើបអង្កេតបឋមជានិច្ច ទោះបីជាលក្ខខណ្ឌអនុវត្តនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានបំពេញក៏ដោយ ។ ប៉ុន្តែការសម្រេចនេះអាចរារាំង មន្ត្រីនគរបាលយុត្តិធម៌នូវអំណាចដែលអនុវត្តបានក្នុងការស៊ើបអង្កេតករណីជាក់ស្តែង ។ នេះមានន័យថា ប្រសិនបើគាត់ជ្រើសរើសយកការស៊ើបអង្កេតបឋម នោះគាត់មិនអាចវិលទៅរកនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែងវិញបានទេ ។[42]

### ២.២ វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

យើងអាចកត់សម្គាល់ឃើញថា អំណាចនិងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម មានលក្ខណៈមិនដូចគ្នាទៅនឹងអំណាចនិងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ។ វិធានដែលទាក់ទិននឹងការស៊ើបអង្កេតបឋមគឺមិនសូវខុសគ្នាពីវិធាននៃការស៊ើបអង្កេតករណីជាក់ស្តែងប៉ុន្មានទេ ព្រោះមាត្រា ១១២ នៃក្រមនីតិធីព្រហ្មទណ្ឌ បានអនុញ្ញាឱ្យយកនូវបញ្ញត្តិមួយចំនួនដើម្បីអនុវត្តក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមនេះ ដែលបញ្ញត្តិទាំងនោះរួមមាន :

---

[42] សៀវភៅ **និតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល** (អំណោយស្ថានទូតបារាំង) ឆ្នាំ ២០០៩ ត្រង់ទំព័រ ៣២

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍

-មាត្រា ១០៧ (ការបញ្ជូនដំណាត់ហេតុទៅព្រះរាជអាជ្ញា)

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) ។

### ២.៣ ការឆែកឆេរលំនៅដ្ឋាន និងឆែកឆេររូបរាងកាយ

បើយើងពិនិត្យមើលឱ្យស៊ីជម្រៅទៅយើងឃើញថា ការឆែកឆេរក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម ក៏មានភាពដូចគ្នាច្រើនទៅនឹងការឆែកឆេរនៃការស៊ើបអង្កេតករណីជាក់ស្តែង ប៉ុន្តែមានចំណុចមួយចំនួនវាមានភាពខុសគ្នាដែលជាលក្ខខណ្ឌចាំបាច់ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពក្នុងប្រត្តិបត្តិការឆែកឆេររបស់ខ្លួន ។ កាលណាការស៊ើបអង្កេតបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរនិងចាប់យកវត្ថុតាង ។ ការយល់ព្រមច្បាស់លាស់និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែងនោះ ។ ប៉ុន្តែបើអ្នកនោះមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកកាន់កាប់នោះមិនចេះអក្សរហើយយល់ព្រមឱ្យឆែកឆេរ ។ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចអាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ ក្នុងករណីអ្នកកាន់កាប់នោះអវត្តមាន ឬបដិសេធការឆែកឆេរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ។ ម្យ៉ាងវិញទៀត ការឆែកឆេរនេះត្រូវតែដឹកនាំផ្ទាល់ពីព្រះរាជអាជ្ញា ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ។ សាក្សីនេះ មិនអាចជានគរបាលយុត្តិធម៌ ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ ការឆែកឆេរ មិនអាចចាប់ផ្តើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាង និងបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។ គាត់ត្រូវបង្ហាញវត្ថុដែលបានចាប់យកដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើល រួចធ្វើកំណត់ហេតុស្តីពីការចាប់យកវត្ថុតាងដែលរួមមានបញ្ជីសារពើភណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យកវត្ថុតាងត្រូវចុះហត្ថលេខា ឬផ្តិតស្រាមមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។

ផ្ទុយទៅវិញ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ពុំបានអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីទេ ហើយមានការបំពានទៅលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌នោះអាចនឹងត្រូវផ្តន្ទាទោសពីបទ **រំលោភលើលំនៅដ្ឋាន** តាមមាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌដែលចែងថា អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ចូលទៅក្នុងលំនៅដ្ឋានរបស់អ្នកដទៃដោយគ្មានការយល់ព្រមពីម្ចាស់ផ្ទះនោះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ (ពីរ) លានរៀល ទៅ ៤ (បួន) លានរៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

## ២.៤ ការបញ្ជាឱ្យចូលខ្លួន និងការឃាត់ខ្លួនជនសង្ស័យ

យើងឃើញថា ការបញ្ជាឱ្យចូលខ្លួនក្នុងក្របខណ្ឌនេះ ក៏មានលក្ខណៈដូចគ្នាទៅនឹង ការបញ្ជាឱ្យចូលខ្លួនក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែងដែរ ។ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬអាចផ្តល់ពត៌មានស្តីពីរឿងហេតុ ។ បើសិនជាបុគ្គលដែលកោះហៅនោះរឹងទទឹងមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួន ដែលបញ្ជានេះត្រូវមានចុះអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រា ។ បញ្ជានេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។

រីឯ ការឃាត់ខ្លួនក្នុងចំណុចនេះវិញ គឺមានលក្ខណៈដូចគ្នាទៅនឹងការឃាត់ខ្លួនក្នុងការសើបអង្កេតបឋមផងដែរ ដែលត្រូវយកបញ្ញត្តិនៃជំពូកទី ៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួន មាតិការទី ២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែង ក្នុងគន្ថីទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្តដូចគ្នា ។ ដោយហេតុថា យើងបានធ្វើការបកស្រាយយ៉ាងលម្អិតរួចហើយ ដូច្នេះយើងសូមមិនលើកថាមកសិក្សាម្តងទៀតនោះទេ ។

## ២.៥ កំណត់ហេតុស្រង់ចម្លើយ និងមោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

បើយើងក្រឡេកមើលទៅក្នុងមាត្រា ១១៥ គឺបានបញ្ជាក់ពីកំណត់ហេតុស្តាប់ចម្លើយ ដែលរាល់ការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុ ដែលត្រូវដកស្រង់ឱ្យត្រឹមត្រូវតាមចម្លើយរបស់បុគ្គលដែលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ដែលបានស្បថស្របតាមជំនឿសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ ។ អ្នកបក

ប្រែនេះមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។

ដោយឡែក នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម គឺដាច់ខាតត្រូវតែគោរពនូវវិធានបញ្ញត្តិមួយចំនួន បើពុំដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ពោលគឺការស៊ើបអង្កេតនឹងទុកជាអសាបង់ ដែលវិធានទាំងនោះរួមមាន :

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទ៏)

-មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុឱ្យព្រះរាជអាជ្ញា)

-មាត្រា ១១៣ (ការឆែកឆេរ)

-មាត្រា ១១៩ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) ។

### ៣. ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលបានចាប់យក

ជាកិច្ចបន្ទាប់ យើងនឹងធ្វើការពន្យល់នូវចំណុចមួយទៀតដែលនិយាយពីការប្រគល់វត្ថុដែលបានចាប់យកឱ្យទៅម្ចាស់ដើមវិញ ។ តើវត្ថុប្រភេទអ្វីដែលអាចត្រូវបានប្រគល់ឱ្យម្ចាស់ដើមវិញ ? ហើយអ្នកណាមានសមត្ថកិច្ចក្នុងការបង្គាប់ឱ្យប្រគល់ ? ការប្រគល់នោះធ្វើឡើងយ៉ាងដូចម្តេច ? ដំណោះស្រាយនឹងត្រូវបានបកស្រាយដូចខាងក្រោម :

#### ៣.១ អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់

បន្ទាប់ពីពេលដែលចាប់យកវត្ថុតាងរួចមក ប្រសិនណាបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយបើកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រគល់វត្ថុដែលចាប់បាននោះទៅម្ចាស់ដើមវិញ តាមការបង្គាប់បញ្ជាពីព្រះរាជអាជ្ញា ។ ប៉ុន្តែចំពោះករណីដែលវត្ថុនោះមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចប្រគល់ឱ្យវិញបានទេ ។ វត្ថុទាំងនោះត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល ។

**ឧទាហរណ៍** : ក្នុងពេលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរបទល្មើសទទួលផលចោរកម្ម ដោយមានដីកាចាត់ឱ្យឆែកឆេរ និងដឹកនាំផ្ទាល់ពីព្រះរាជអាជ្ញា ដែលធ្វើឡើងនៅក្នុងលំនៅដ្ឋានរបស់ជនសង្ស័យ ពេលនោះគេក៏បានរកឃើញ ហើយចាប់យកវត្ថុតាងមួយចំនួន ដែលមានគ្រឿងញៀនជាច្រើន ហើយគេក៏ប្រទះឃើញ នូវកាំភ្លើងម៉ាក ឡុក (Lock) ចំនួន ៥ ដើម ព្រមទាំងគ្រាប់កាំភ្លើងចំនួន ៥០ គ្រាប់ ដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ ព្រមទាំងម៉ូតូមួយគ្រឿងដែលជាកម្មសិទ្ធិរបស់មិត្តភក្តិដែលបានផ្ញើរទុកនៅជនសង្ស័យនោះ មន្ត្រីនគរបាលយុត្តិធម៌ ក៏បានចាប់យកវត្ថុតាងទាំងអស់នោះ ។ ស្ថិតក្នុងករណីនេះ គេមិនអាចប្រគល់គ្រឿងញៀន កាំភ្លើង និងគ្រាប់កាំភ្លើងនោះទៅឱ្យម្ចាស់ដើមវិញបានជាដាច់ខាត ។ ផ្ទុយទៅវិញ ចំពោះ ម៉ូតូដែលជារបស់មិត្តភក្តិជនសង្ស័យដែលគាត់ជាជនសុចរិត មិនមានកំហុសមិនបានដឹងឮឬចូលរួមប្រព្រឹត្តបទល្មើសអ្វីទាល់តែសោះ គេអាចប្រគល់ឱ្យម្ចាស់ដើមវិញបាន ។

ក្នុងករណីដែលមន្ត្រីនគបាលយុត្តិធម៌មិនព្រមប្រគល់ឱ្យវិញទេ គេអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ។ ការណ៍នេះអាចធ្វើបានតែក្នុងដំណាក់កាលស៊ើបអង្កេតតែប៉ុណ្ណោះ ផ្ទុយទៅវិញព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ។ តែព្រះរាជអាជ្ញានៅតែមានសមត្ថកិច្ចកាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ។

### ៣.២ ការប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ

កាលណាតុលាការទទួលពាក្យបណ្តឹងដែលបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯង លើពាក្យសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំទាស់អ្វីជាប្រកដប្រជា ។[43]

## ផ្នែកទី ៣ បេសកម្មរបស់នគរបាលយុត្តិធម៌នៅពេលមានដីកាចាត់ឱ្យស៊ើបសួរជំនួស

បន្ទាប់ពីបានស្វែងយល់យ៉ាងស៊ីជម្រៅ ទៅលើអំណាចក្នុងការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ទាំងពីរករណីរួចមក នៅក្នុងចំណុចនេះយើងនឹងបង្ហាញឱ្យឃើញពីសិទ្ធិអំណាចមួយទៀតព្រមទាំងកាតព្វកិច្ច ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តនៅពេលដែលមានដីកាចាត់ឱ្យស៊ើបសួរជំនួស ពី

[43] មាត្រា ១២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

សំណាក់ចៅក្រមស៊ើបសួរ ។ តើអ្វីជាដីកាចាត់ឱ្យស៊ើបសួរជំនួស ? តើមូលហេតុអ្វីបានជាចាំបាច់ធ្វើការស៊ើបសួរជំនួស ? ហើយអំណាចអ្វីខ្លះដែលនគរបាលយុត្តិធម៌ទទួលបាននៅពេលដែលមានដីកាចាត់ឱ្យស៊ើបសួរជំនួស ? យើងនឹងធ្វើការបង្ហាញដូចខាងក្រោម :

**កថាខណ្ឌ ១ ដីកាចាត់ឱ្យស៊ើបសួរជំនួស**

ដីកាចាត់ឱ្យស៊ើបសួរជំនួស ជាដីកាមួយដែលចេញក្រោមទម្រង់ ជាប្រតិភូកម្មអាជ្ញាបញ្ជានៃអំណាចដែលជាញឹកញាប់បំផុតចៅក្រមស៊ើបសួរចេញឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត ឬទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ដែលពួកគាត់ត្រូវតែអនុវត្តការស្នើសុំអនុលោមតាមវិធាននានាដែលច្បាប់តម្រូវ ដើម្បីបំពេញកិច្ចស៊ើបសួរ ។ ជាទូទៅ ប្រតិភូ (អាណត្តិគាហក) ត្រូវបំពេញតែកិច្ចណាដែលមានចុះក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសប៉ុណ្ណោះ ។ ម្យ៉ាងទៀត កិច្ចមួយចំនួនមិនអាចត្រូវធ្វើប្រតិភូកម្មទៅមន្ត្រីនគរបាលយុត្តិធម៌នោះឡើយ ដូចជា ការចេញចម្លើយ, ការស្តាប់ចម្លើយជនត្រូវចោទ, សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ។ល។

ដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ដែលកិច្ចនោះត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់ ។ ដីកាចាត់ឱ្យស៊ើបសួរជំនួស មិនអាចមានលក្ខណៈជាទូទៅទេត្រូវណែនាំឱ្យបានច្បាស់លាស់ ។ ចៅក្រមស៊ើបសួរកំណត់ចិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ ចៅក្រមស៊ើសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា ។

**១. មូលហេតុនៃការស៊ើបសួរជំនួស**

ការដែលមន្ត្រីនគរបាលយុត្តិធម៌ អាចទទួលបានសិទ្ធិអំណាចក្នុងការស៊ើបសួរជំនួសចៅក្រមស៊ើបសួរ គឺយើងពិនិត្យឃើញថា ដោយសារតែចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចការចាំបាច់តែម្នាក់ឯងរហូត ដើម្បីដឹកនាំការស៊ើបសួរឱ្យបានល្អនោះឡើយ ព្រោះជួនកាលត្រូវជួបប្រទះនូវការលំបាកផ្នែកសម្ភារៈ ត្រូវធ្វើកាឆែកឆេរព្រមៗគ្នានៅកន្លែងជាច្រើន ដើម្បីឱ្យមានប្រសិទ្ធិភាពត្រូវបំពេញកិច្ចនៅតាមសមត្ថកិច្ចដែនដីឆ្ងាយៗពីគ្នា ម៉្យាងទៀតពីព្រោះថា មានការស្រាវជ្រាវជាច្រើនដែលត្រូវដឹកនាំ ហើយពុំមានពេលវេលា និងមធ្យោបាយធ្វើតែម្នាក់ឯងឡើយ ។ ហេតុដូច្នេះ ដើម្បីប្រសិទ្ធភាពការងារ ចៅក្រមស៊ើបសួរអាចធ្វើប្រតិភូកម្មមួយផ្នែកនៃអំណាចរបស់ខ្លួន ។ ដែលប្រតិភូកម្មអំណាចតាមរយៈដីកាចាត់

ឱ្យស៊ើបសួរជំនួសនេះមានចែងក្នុងមាត្រា ១៣១ និង មាត្រា ១៧៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**កថាខណ្ឌ ២ សិទ្ធិអំណាចមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស**

មាត្រា ៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា កាលណាការស៊ើបសួរបានចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរ ។ ដូចនេះចៅក្រមស៊ើបសួរទទួលបានអំណាចដឹកនាំការស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ ។ វាផ្ទុយទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង ឬការស៊ើបអង្កេតបឋមដែលនគរបាលយុត្តិធម៌ប្រើប្រាស់នូវអំណាចដែលប្រគល់ឱ្យខ្លួនដោយមាត្រា ៨៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬមាត្រា ១១១ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬអនុវត្តតាមសេចក្តីណែនាំ ។ ចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ អំណាចដែលត្រូវបានផ្ទេរឱ្យនគរបាលយុត្តិធម៌គឺមានកម្រិតដោយអនុវត្តតាមមាត្រា ១៧៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ របៀបស៊ើបអង្កេតនេះមានលក្ខណៈពិសេស ដោយគេមិនអាចធ្វើការស្រាវជ្រាវ ក្នុងពេលតែមួយលើរឿងហេតុតែមួយ តាមរបៀបស៊ើបអង្កេតផ្សេងទៀតឡើយ ។

**១. បុព្វសិទ្ធិមន្ត្រីនគរបាលយុត្តិធម៌**

ក្នុងដែនកំណត់នៃដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌អនុវត្តអំណាចមួយចំនួនរបស់ចៅក្រមស៊ើបសួរ (មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ ដែលមាត្រានេះផ្តល់អំណាចនានាដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលគាត់អនុវត្តអំណាចដែលមានចែងក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) ។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយតទល់នឹងជនត្រូវចោទ ហើយក៏មិនអាចស្តាប់ចម្លើយភាគីដើមបណ្តឹងរដ្ឋប្បវេណីបានដែរ ។ មន្ត្រីនគរបាលយុត្តិធម៌ស្តាប់តែបញ្ជាចៅក្រមអាណត្តិទាយកប៉ុណ្ណោះដែលខ្លួនត្រូវតែរាយការណ៍ជូនចៅក្រមអាណត្តិទាយកជាប់ជានិច្ច ហើយប្រាប់ដល់គាត់សូម្បីតែបញ្ហាបន្តិចបន្តួចក៏ដោយ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពរយៈពេលនៃការអនុវត្ត គាត់អាចនឹងទទួលជាយថាហេតុ នូវការពន្លាតសមត្ថកិច្ច តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសជាក់លាក់របស់ចៅក្រមស៊ើបសួរដែលមានចុះពីប្រភេទកិច្ចការទាំងឡាយដែលត្រូវបំពេញ ។

## ២. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការកោះហៅ និងស្តាប់ចម្លើយសាក្សី

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ។ មុននឹងឆ្លើយចំពោះសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថា និយាយតែការពិត ។ ប៉ុន្តែ សាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ)[44] ត្រូវបានលើកលែងមិនចាំបាច់ស្បថ ។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់បានធ្វើឱ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ ។ បុគ្គលដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឱ្យចូលខ្លួន ដោយមានចុះអត្តសញ្ញាណនៃសាក្សី ។ បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ បញ្ជាឱ្យចូលបង្ហាញខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំឱ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តលើកំណត់ហេតុស្តីពីការស្តាប់សម្លើយសាក្សី ។[45]

## ៣. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង

យើងពិនិត្យឃើញថា មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងដោយផ្តល់អំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង ដោយយកនូវបញ្ញត្តិនៃមាត្រា ៩១ (ការឆែកឆេរ) និងមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) មកអនុវត្ត ។ ប៉ុន្តែ ការអនុញ្ញាតដែលមានចែងនៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៩១ (ការឆែកឆេរ) ត្រូវតែផ្តល់ឱ្យដោយចៅក្រមស៊ើបសួរ ។

---

[44] មាត្រា ១៥៦ **សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ** : ១.ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ ២.កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ ៣.បង បងប្រុស ស្រីរបស់ជនត្រូវចោទ ៤.បង បងប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ ៥.ប្តី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ ៦.កុមារអាយុតិចជាង ១៤ ឆ្នាំ ។

[45] មាត្រា ១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ៤. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឃាត់ខ្លួន

ក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស គេត្រូវយកបញ្ញត្តិនៃមាត្រា ៩៦ (ការឃាត់ខ្លួន) ដល់មាត្រា ១០២ (កំណត់ហេតុសរុបនៃការឃាត់ខ្លួន) មកអនុវត្ត ។ ប៉ុន្តែ អំណាចដែលប្រគល់ឱ្យដោយមាត្រាទាំងនេះដល់ព្រះរាជអាជ្ញា ត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ ។ សម្រាប់ការអនុវត្តមាត្រា ១០៣ (ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន) និងមាត្រា ១០៤ (រយៈពេលនៃការបញ្ជូនខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលផុតកំណត់នៃការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវនាំជនដែលត្រូវបានឃាត់ខ្លួនទៅបង្ហាញ នៅចំពោះមុខចៅក្រមស៊ើបសួរ ។[46]

### ៥. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស្តាប់ទូរស័ព្ទ ជាអាទិ៍

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរស័ព្ទ ឬសារតាមអិនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឱ្យដោយចៅក្រមស៊ើបសួរ ដោយវក្យខណ្ឌទី ២ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ១៧២ (ការស្តាប់ទូរសព្ទ ជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងវក្យខណ្ឌទី ២ កថាខណ្ឌទី ១ នោះបានចែងថា ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការ ឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរស័ព្ទ ឬសារតាមអិនធើណែត ។ ព្រមទាំងកថាខណ្ឌទី ២ ដែលមានអត្ថន័យថា ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌យកសិទ្ធិអំណាចទាំងអស់នេះ មកប្រើប្រាស់ក្នុងបេសកកម្មរបស់ខ្លួន ។

ត្រង់ចំណុចនេះ យើងអាចសន្និដ្ឋានឃើញច្បាស់ថា អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមាននៅក្នុងការស្តាប់ចម្លើយក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស គឺវាមានភាពផ្ទុយគ្នាទៅនឹង ការស្តាប់ចម្លើយនៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ត្រង់មាត្រា ១០៥ និងក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម ត្រង់មាត្រា ១១២ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍) ដែលមាត្រានោះ បានចែងបញ្ជាក់ពី មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថត

[46] មាត្រា ១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

សំឡេងការសន្ទនាតាមទូរស័ព្ទឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬ សារតាមអិនធើណែត ។ នេះវាបានស្តែងចេញឱ្យឃើញច្បាស់ថា អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌មានភាពខុសគ្នា ហើយមានការប្រែប្រួលទៅតាមដំណាក់កាលនីមួយៗ នៃកិច្ចនីតិវិធីព្រហ្មទណ្ឌ ។

## កថាខណ្ឌ ៣ ភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីការបស់តុលាការ

ក្រោយពីបានសិក្សានូវអំណាចជាច្រើនរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត និងស៊ើបសួររួចមក ក្នុងចំណុចនេះយើងនឹងធ្វើការរៀបរាប់ពីបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីការបស់តុលាការ ។ តើមន្ត្រីនគរបាលយុត្តិធម៌ត្រូវរក្សាការសម្ងាត់នៃការស៊ើបសួររបស់គាត់ដែរឬទេ ? តើដីការបស់តុលាការអ្វីខ្លះដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្ត ? នឹងត្រូវបានបកស្រាយដូចខាងក្រោម :

### ១. ការរក្សាការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់ ។ យើងពិនិត្យឃើញថា បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ មានជាច្រើនដូចជា ចៅក្រម មេធាវី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ដែលអ្នកទាំងនេះដាច់ខាតត្រូវតែថៃរក្សាការសម្ងាត់វិជ្ជាជីវៈ ។ ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនបានឡើយ ។ ការបំពាននៃលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។[47]

### ២. ការចាប់បង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន

បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែចូលមកបង្ហាញខ្លួន បើសិនជាបុគ្គលនោះមិនចូលមកទេ នោះមានន័យថា គាត់រឹងទទឹង ដូច្នេះចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈ ដែលអាចមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ផងដែរ ដើម្បីបង្ខំសាក្សីនេះមកបង្ហាញខ្លួននៅមុខតុលាការ ។[48]

[47] មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[48] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ៣. ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន

នៅក្នុងមាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់យ៉ាងច្បាស់ពីកាតព្វកិច្ចមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា ក្នុងការជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ អំពីដីកាបង្គាប់ឱ្យចូលខ្លួន ។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅដើមដីកាដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ អំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន ។

__ឧទាហរណ៍__ : នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ យកដីកាបង្គាប់ឱ្យចូលខ្លួនទៅកាន់លំនៅដ្ឋានរបស់ជនត្រូវចោទ តែលំនៅដ្ឋាននោះគ្មាននណាម្នាក់ស្នាក់នៅឡើយ ។ ដូចនេះ វាគឺជាការលំបាកក្នុងការអនុវត្តបេសកកម្មដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរពីបញ្ហានេះ ។

គោលដៅនៃដីកាបង្គាប់ឱ្យចូលខ្លួននេះ គឺដើម្បីបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួនទៅមុខចៅក្រមស៊ើបសួរ ។[49]

### ៤. ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន

យោងតាមមាត្រា ១៩២ នៃក្រមនីតិវិធីបានកំណត់ថា ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ ។ ដើមដីកា ត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន ។ ដីកាបង្គាប់ឱ្យនាំខ្លួននេះផងដែរ គឺមានគោលដៅបង្គាប់ឱ្យកងកំលាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ។

### ៥. ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន

យោងតាមមាត្រា ១៩៩ បានចែងពីការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ដែលត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ ។ ដើមដីកា ត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រី

[49] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

នគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន ។ គោលដៅនៃដីកាបង្គាប់ឱ្យចាប់ខ្លួន គឺចេញក្នុងន័យបញ្ជាដល់ :

-កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន

-ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ ។

រាល់ការអនុវត្តដីកាទាំងពីរ ទាំងដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពវិធាននៃពេលវេលា ពោលគឺគាត់មិនអាចចូលទៅលំនៅឋានរបស់បុគ្គលដែលនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ ។

### ៦. ការអនុវត្តដីកាកោះហៅ ឬដីកាផ្សេងៗទៀត

គ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬ កងរាជអាវុធហត្ថ ដែលចៅក្រមស៊ើបសួរសុំឱ្យប្រគល់ដីកាកោះហៅ ឬ ដីកាផ្សេងៗទៀត ត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ ។ បុគ្គលអង្គភាព ឬអាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកាដល់សាមីខ្លួនដោយមានចំណាររបស់អ្នកទទួលបញ្ជាក់ថា បានទទួលទុកជាសម្គាល់ ។ ដីកាដែលមានចំណារទទួលនេះ ត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ។[50] យើងដឹងហើយថា មិនមែនគ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬកងរាជអាវុធហត្ថ ទាំងអស់សុទ្ធតែជានគរបាលយុត្តិធម៌នោះទេ តែដោយសារតែក្នុងបរិបទនេះយើងកំពុងតែសិក្សាពាក់ព័ន្ធនឹងបេសកកម្មរបស់នគរបាលយុត្តិធម៌ ដូច្នេះទើបយើងលើកយកពួកគាត់មកពិភាក្សា ។ ដែលយើងឃើញថា ចៅក្រមស៊ើបសួរ គាត់ក៏អាចបញ្ជាអ្នកដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរយុត្តិធម៌ ឱ្យអនុវត្តនូវការប្រគល់ដីកានេះបានដែរ ។

[50] មាត្រា ២៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

## ផ្នែកទី ៤ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅដំណាក់កាលជំនុំជម្រះ

ក្រៅពីបេសកកម្មនៅក្នុងការស៊ើបអង្កេត និងអនុវត្តដីការបស់តុលាការ នគរបាលយុត្តិធម៌ក៏មាននូវបេសកកម្មជាច្រើនទៀតផងដែរ ក្នុងការធ្វើជាជំនួយឱ្យអំណាចតុលាការនៅក្នុងពេលជំនុំជម្រះ ។ ក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌ ទាំងនៅក្នុងដំណាក់កាលជំនុំជម្រះ ដែលយើងបែងចែកជា ៣ ចំណុចតូចៗ ។ តើនគរបាលយុត្តិធម៌មានបេសកកម្មនៅសាលាជំនុំជម្រះក្តីណាខ្លះ ? ហើយមានការប្រព្រឹត្តទៅយ៉ាងដូចម្តេចក្នុងដំណាក់កាលសាលាជម្រះក្តីនីមួយៗ ? នឹងត្រូវបានបកស្រាយដូចតទៅ :

### កថាខណ្ឌ ១ បេសកកម្មនៅសាលាដំបូងរាជធានី-ខេត្ត

បើយើងពិនិត្យឱ្យបានច្បាស់ទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌ នៅដំណាក់កាលសាលាដំបូងរាជធានី-ខេត្ត យើងឃើញថា មានចែងចាប់ពីមាត្រា ២៨៧ ដល់ មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបេសកកម្មទាំងអស់នោះមានអត្ថន័យដូចទៅ :

#### ១. ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

យោងតាមអត្ថន័យនៃមាត្រា ៤៦៣ ដែលចែងពីការបញ្ជូនដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺអាចត្រូវបានជូនតាមរយៈបុគ្គលច្រើនប្រភេទ ដែលក្នុងនោះយើងឃើញមានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬអាជ្ញាធររដ្ឋបាល នោះមានន័យថា បើសិនជាគេបញ្ជូនតាមរយៈបុគ្គលណាមួយក្នុងចំណោមបុគ្គលទាំងនេះ មានន័យថាក៏មានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលរួមក្នុងបេសកកម្មនេះផងដែរ បន្ទាប់ពីព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលគាត់ត្រូវតែគោរពបញ្ជារបស់ព្រះរាជអាជ្ញា និងត្រូវបំពេញកិច្ចនេះដូចមានចែងក្នុងមាត្រា ៤៦០ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៦២ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាសាដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

#### ២. ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម

ផ្អែកតាមមាត្រា ៣០៣ ចែងពី (ការបង្ហាញខ្លួនភ្លាមរបស់ជនជាប់ចោទដោយមានកំលាំងអម) នឹងមាត្រា ៣០៤ ចែងពី (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបង្ហាញឱ្យដឹងថា ជនជាប់ចោទត្រូវខ្លួនដោយកងការពារ រហូតដល់សាមីខ្លួននៅមុខតុលាការដែលការបង្ហាញខ្លួននោះត្រូវប្រព្រឹត្តទៅនៅក្នុងថ្ងៃនោះតែម្តង ។ យើងពិនិត្យឃើញថា កងការពារ គឺអាចសំដៅទៅរកស្ថាប័ន

នគរបាលយុត្តិធម៌ ដែលមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកបំពេញបេសកកម្ម នេះនៅក្នុងការអមជនជាប់ចោទដើម្បីចូលបង្ហាញខ្លួនចំពោះមុខតុលាការ ឬចៅក្រមជំនុំជម្រះ ។

### ៣. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ

នៅក្នុងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកានោះ បានន័យថា គាត់ជាអ្នកនាំខ្លួនជនជាប់ចោទទៅកាន់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬក៏មណ្ឌលឃុំខ្លួន ឬពន្ធនាគារដើម្បីរក្សាទុកជាមុន រហូតដល់ពេលជននោះចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ។[51]

### ៤. ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនតាមរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន

មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងបញ្ជាក់ពី ករណីដែលតុលាការទទួលពាក្យបណ្ដឹងតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរីលើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ។ ព្រះរាជអាជ្ញាចាត់វិធានការចាំបាច់ដើម្បីឱ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួនត្រូវបានដឹកនាំទៅកាន់សវនាការដោយកម្លាំងសាធារណៈ ដែលអាចមានវត្តមានមន្ត្រីនគរបានយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលរួមក្នុងការនាំខ្លួននេះផងដែរ ។

### ៥. ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌

យោងតាមមាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ពីប្រធានសវនាការដែលគាត់ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។ ប្រធានសវនាការ អាចស្ដាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ។ ដូច្នេះយើងឃើញថា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក៏អាចធ្វើជាសាក្សីក្នុងពេលសវនាការនៅចំពោះមុខចៅក្រមជំនុំជម្រះ ដើម្បីជំនុំជម្រះលើរឿងក្ដីព្រហ្មទណ្ឌ ។

[51] មាត្រា ៣១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ៦. ការធានាសណ្តាប់ធ្នាប់នៃសវនាការ

នៅក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ពីការធានារ៉ាប់រងសណ្តាប់ធ្នាប់ក្នុងសវនាការដែលជាតួនាទីរបស់ ប្រធានសវនាការ ។ ប៉ុន្តែ ប្រធានសវនាការក៏អាចប្រើប្រាស់កម្លាំងសាធារណៈដែលអាចមាន នគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការធ្វើជាជំនួយឱ្យស្ថាប័នតុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ពោលគឺពួកគាត់មានតួនាទីក្នុងការការពារ ថែរក្សា សណ្តាប់ធ្នាប់ល្អនៃសវនាការ ។

### ៧. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក៏អាចប្រគល់ឱ្យផងដែរ ដល់ក្រលាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទផ្សេងទៀត ឬតាមរយៈអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ ។ ដូច្នេះ ប្រសិនបើតុលាការសម្រេចជូនដំណឹងតាមរយៈផ្លូវរដ្ឋបាល ឬអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ នោះមានន័យថាក៏សំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ ដែលគាត់ត្រូវតែបំពេញបេសកកម្មនេះតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ កិច្ចនេះត្រូវធ្វើដូចមានចែងនៅមាត្រា ៤៨៧ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចជូនដល់ភាគីដែលពាក់ព័ន្ធដោយអាជ្ញាសាលា) ដល់មាត្រា ៤៨៨ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ៨. ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

យើងពិនិត្យឃើញថា បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬនៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលសំដៅដល់អង្គភាពនគរបាលយុត្តិធម៌ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។ កាលណាបើអង្គភាពនគរបាលយុត្តិយុត្តិធម៌បានទទួលពាក្យប្តឹងទាស់នោះ គាត់ត្រូវតែបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។[52]

## កថាខណ្ឌ ២ បេសកកម្មនៅសាលាឧទ្ធរណ៍

នៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍នេះ យើងពិនិត្យឃើញមានបេសកកម្មរបស់នគរបាលយុត្តិធម៌មួយចំនួនដែលមានចែងក្នុងមាត្រា មួយចំនួនដូចជា មាត្រា ៣៨៨ (ការជូនដំណឹង និងដីកាកោះហៅចូល

[52] មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

សវនាការ) ដែលបានចង្អុលបង្ហាញឱ្យយកមាត្រាទាំងឡាយដូចមានចែងក្នុងមាតិកាទី ២ ស្តីពី «ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ» និងមាតិកាទី ៣ ស្តីពី «ដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ» នៃគន្ថីទី ៧ ស្តីពី «ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង» នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត ។ យើងនឹងធ្វើការសិក្សាទៅលើចំណុចនីមួយៗ ដែលមានវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ចូលរួមបេសកកម្មដូចខាងក្រោម :

### ១. ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ

ការធ្វើបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ គឺមិនមែនគ្រាន់តែធ្វើបាននៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានសម្រេចចេញដីកា ឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន ឬធ្វើនៅចំពោះមុខអគ្គព្រះរាជអាជ្ញានោះទេ តែក៏អាចធ្វើបានដែរនៅអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថដែលភាគច្រើនសំដៅទៅលើអង្គភាពនគរបាលយុត្តិធម៌ ។ នៅពេលដែលមានការប្តឹងបែបនេះជាលាយលក្ខណ៍អក្សរ ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែទទួលបណ្តឹងនោះទុកដើម្បីចាត់ការតាមនីតិវិធិបន្តទៀត ពោលគឺគាត់ត្រូវបញ្ជូនបណ្តឹងនោះភ្លាមទៅក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកាតាមមាត្រា ៤១០ នៃក្រមនីតិវិធិព្រហ្មទណ្ឌ ។

### ២. ការប្រគល់ដីកាកោះហៅ

ឆ្លងតាមមាត្រា ៤៧២ (របៀបផ្សេងៗនៃការប្រគល់ដីកាកោះ) យើងពិនិត្យឃើញថា នគរបាលយុត្តិធម៌ក៏មានបេសកកម្មផងដែរ ប្រសិនបើតុលាការប្រើនីតិវិធីប្រគល់តាមអង្គភាពនគរបាល កងរាជអាវុធហត្ថ ឬតាមផ្លូវរដ្ឋបាល ។ អ្នកទាំងអស់នេះត្រូវតែគោរពបញ្ជារបស់ព្រះរាជអាជ្ញា តាមការសុំឱ្យប្រគល់ដីកាកោះហៅនោះ ហើយត្រូវបំពេញកិច្ចនោះដូចមានចែងក្នុងមាត្រា ៥៦៩ (ការប្រគល់ដីកាដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៧១ (ការប្រគល់ចុងដីកាកោះហៅដោយអជ្ញាសាលា ដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## កថាខណ្ឌ ៣ បេសកកម្មនៅតុលាការកំពូល

បេសកកម្មរបស់នគរបាលយុត្តិធម៌ នៅដំណាក់កាលតុលាការកំពូលនេះយើងឃើញថា បានចែងតែមួយមាត្រា ប៉ុណ្ណោះក្នុងក្រមនីតិវិធិព្រហ្មទណ្ឌ នោះគឺមាត្រា ៤៣៣ (ការជូនដំណឹងអំពីកាលបរិច្ឆេទសវនាកាចំពោះគូភាគី) ។ នៅពេលដែលប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសាវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការ អគ្គព្រះរាជអាជ្ញាត្រូវឱ្យ

ដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគីនិងមេធាវី ។ ការឱ្យដំណឹងជនជាប់ចោទដែលជាប់ឃុំ ដល់ពិរុទ្ធជនដែលឃុំខ្លួន ឬដល់បុគ្គលដែលគេទាមទារនៅក្នុងរឿងបត្យាប័ន ត្រូវធ្វើឡើងតាមរបៀបដូចតទៅ : ដោយផ្ទាល់មាត់ ឬតាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។ រីឯការឱ្យដំណឹងដល់ពិរុទ្ធជន ឬជនជាប់ចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដល់មេធាវី ត្រូវធ្វើដូចតទៅ : ដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬ តាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។ កាលណាការឱ្យដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការឱ្យដំណឹងទៅលើសំនុំរឿង ។ ពិរុទ្ធជន ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬមេធាវី ចុះហត្ថលេខារបស់ខ្លួន ។ នៅក្នុងករណីដទៃទៀត ការឱ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថាបានទទួលសម្រាប់ទុកជាសម្គាល់ ។ តាមរយៈអត្ថន័យខាងលើ យើងឃើញថាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក៏មានបេសកកម្មក្នុងការទាក់ទងនឹងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការទៅដល់ភាគីផងដែរ ។

## ផ្នែកទី ៥ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក

ក្រៅពីបេសកកម្មនៅក្នុងដំណាក់កាលនីតិវិធីទាំងឡាយដែលបានរៀបរាប់ជូនខាងលើ បេសកកម្មរបស់នគរបាលយុត្តិធម៌ដទៃៗទៀតក៏មានផងដែរ ។ យើងនឹងសិក្សាទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌ នៅក្នុងដំណាក់កាលនីតិវិនៃនីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក ។ តើនគរបាលយុត្តិធម៌មានបេសកកម្មអ្វីក្នុងនីតិវិធីប្រតិបត្តិ ? ចុះបេសកកម្មក្នុងនីតិវិធីដោយឡែកវិញដូចម្តេចដែរ ? យើងនឹងធ្វើការបកស្រាយដូចខាងក្រោម :

### កថាខណ្ឌ ១ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ

នៅក្នុងដំណាក់កាលនេះ យើងពិនិត្យឃើញមានចែងចាប់ពីមាត្រា ៤៩៦ ដល់មាត្រា ៦៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហើយមាត្រាមួយចំនួនបានចែងពីបេសកកម្មរបស់នគរបាលយុត្តិធម៌ ដែលមានដូចជា :

#### ១. ការធានារ៉ាប់រងការអនុវត្តទោស

នៅក្នុងមាត្រា ៤៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ពីសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាក្នុងការសុំកងកម្លាំងសាធារណៈ ដែលមានដូចជា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាដើម ដើម្បីទៅបំពេញបេសកកម្មក្នុងការធានានូវការអនុវត្តទោស នៅពេលដែលមានសាលក្រម ឬសាលដីការបស់តុលាការឱ្យផ្តន្ទាទោសជនណាមួយ ។

### ២. ការស្នើសុំពិនិត្យបញ្ជី និងបង្ហាញជនជាប់ឃុំ

មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចក្នុងការពិនិត្យបញ្ជីជនជាប់ឃុំ ដែលអំណាចនេះត្រូវបានប្រគល់ដោយអាជ្ញាធរតុលាការ ពោលគឺគ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញបេសកកម្មនោះ ដែលបញ្ជីនោះត្រូវបានចុះនិទ្ទេសអំពីអត្តសញ្ញាណជនដែលត្រូវបានឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន និងកាលបរិច្ឆេទដោះលែង ។[53]

រីឯមាត្រា ៥០៨ បានបញ្ជាក់ឱ្យដឹងពីការដែលគ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញបេសកកម្ម តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

### ៣. ការជូនដំណឹង ការចាប់ខ្លួន និងឃុំខ្លួនទណ្ឌិតក្នុងករណីបង្ខំដល់រូបរាងកាយ

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិតដើម្បីបង់ប្រាក់នោះ ហើយជូនដំណឹងថាប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃទេ ។ ការឱ្យដំណឹងត្រូវធ្វើដោយ ផ្ទាល់មាត់ តាមផ្លូវតុលាការ តាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចំណុចនេះច្រើនតែសំដៅលើមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ។ ដូចនេះពួកគាត់ត្រូវមានបេសកកម្មក្នុងការជូនដំណឹងនេះ ។

ផ្ទុយទៅវិញ ប្រសិនបើផុតរយៈពេលកំណត់ ហើយទណ្ឌិតនៅតែមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណងរដ្ឋប្បវេណី នោះទេ ព្រះរាជអាជ្ញានឹងចេញបញ្ជាឱ្យបង្ខំ និងឃុំខ្លួនបាន ពីព្រោះថាការដែលមិនបង់ប្រាក់ទាំងនេះ គឺជាលក្ខខណ្ឌនៃការបង្ខំដល់រូបកាយ ដូចមានចែងក្នុងមាត្រា ៥២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តែដើម្បីសម្រេចកិច្ចការនេះ ព្រះរាជអាជ្ញាត្រូវសុំឱ្យកងកំលាំងសាធារណៈ ពោលគឺនគរបាលយុត្តិធម៌នេះឯងដែលទទួលបេសកកម្មក្នុងការចាប់ និងឃុំខ្លួនទណ្ឌិត តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ។ ដោយឡែក ព្រះរាជអាជ្ញាក៏អាចបង្អង់សេចក្តីសម្រេចនេះបានដែរ ដោយសារតែមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត ។[54]

---

[53] មាត្រា ៥០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[54] មាត្រា ៥២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

**កថាខណ្ឌ ២ បេសកកម្មនៅដំណាក់កាលនីតិវិធីដោយឡែក**

នៅក្នុងនីតិវិធីដោយឡែក យើងឃើញមានចែងចាប់ពីមាត្រា ៥៥៥ ដល់មាត្រា ៦០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តែមានចំណុចមួយដែលទាក់ទងទៅនឹងបេសកកម្មរបស់នគរបាលយុត្តិធម៌ផងដែរ គឺ ការរក្សាទុកនូវលិខិតនៃនីតិវិធី ពោលគឺ លិខិតនៃនីតិវិធីត្រូវបង្កើតឡើងវិញតាមលិខិតចម្លងដែលរក្សាទុកដោយអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ភាគី អ្នកជំនាញ ក្រឡាបញ្ជី ឬបុគ្គលផ្សេងទៀត ។ ដូច្នេះ យើងឃើញថា លិខិតនៃនីតិវិធី គឺត្រូវបានរក្សាទុកនៅកន្លែងជាច្រើនផ្សេងៗគ្នា ដែលនគរបាលយុត្តិធម៌ ក៏មានភារកិច្ចក្នុងការរក្សាទុកផងដែរ ។ ការរក្សាទុកនៅកន្លែងផ្សេងៗបែបនេះ គឺដើម្បីមានភាពងាយស្រួលក្នុងពេលបាត់បង់លិខិតចម្លង ដោយថាហេតុណាមួយ របស់បុគ្គលដែលទទួលបន្ទុករក្សាលិខិតនោះ ឬនិយាយសាមញ្ញគេហៅថា ចុងសន្លឹក ទើបខ្លួនអាចបង្កើតឡើងវិញនូវលិខិតចម្លងថ្មីទៅតាមលិខិតដែលរក្សាទុកនៅឯអង្គភាពរបស់ខ្លួនបាន ។

**ចប់ជំពូកទី ២**

# ជំពូកទី ៣

# បេសកកម្មរបស់នគរបាលយុត្តិធម៌នៅកន្លែងកើតហេតុ

នៅក្នុងប្រតិបត្តិការរបស់ខ្លួន នគរបាលយុត្តិធម៌ត្រូវការប្រើប្រាស់នូវវិធីសាស្ត្រជាច្រើន ព្រមទាំងបច្ចេកទេសដ៏ម៉ត់ចត់ ដើម្បីធ្វើឱ្យការស៊ើបអង្កេតរបស់ខ្លួនទទួលបានលទ្ធផលមួយដ៏ល្អប្រសើរនិងត្រឹមត្រូវ ។ ការបកស្រាយនូវចំណុចជាច្រើនដែលទាក់ទងទៅនឹងបេសកកម្មរបស់នគរបាលយុត្តិធម៌នៅជំពូកទី ២ គឺវាបានផ្តល់នូវពុទ្ធិយ៉ាងច្រើនដែលមានលក្ខណៈទ្រឹស្តី ដែលភាគច្រើនត្រូវបានរំលេចចេញពីអត្ថន័យនៃមាត្រាជាច្រើននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។ ដោយឡែកនៅក្នុងជំពូកទី ៣ នេះ យើងនឹងធ្វើការសិក្សាលម្អិតទៅលើ បេសកកម្មរបស់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសនៅកន្លែងកើតហេតុ ។ នៅក្នុងជំពូកនេះ យើងនឹងពិភាក្សាស្វែងយល់ទៅលើ ៣ ផ្នែកធំៗ ដូចតទៅ :

## ផ្នែកទី ១ បេសកកម្មទៅកាន់កន្លែងកើតហេតុ

នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅកាន់កន្លែងកើតហេតុ ។ យើងដឹងហើយថា មន្ត្រីនគរបាលយុត្តិធម៌ទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេតកន្លែងកើតហេតុ ។ តើគាត់ស៊ើបអង្កេតដើម្បីអ្វី ? ត្រូវធ្វើអ្វីខ្លះនៅកន្លែងកើតហេតុ ? យើងនឹងធ្វើការបកស្រាយដូចខាងក្រោម :

### កថាខណ្ឌ ១ គោលបំណងនៃការស៊ើបអង្កេតកន្លែងកើតហេតុ[55]

គោលបំណងនៃការស៊ើបអង្កេតកន្លែងកើតហេតុ គឺដើម្បីជួយឱ្យដឹងនូវបទល្មើសដែលបានកើតឡើង ប្រមូលភស្តុតាងសំខាន់ៗ និងកំណត់អត្តសញ្ញាណជនល្មើស ។ វាត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្នក្នុងការពិនិត្យស្ថានភាពនៅកន្លែងកើតហេតុ និងទទួលស្គាល់គ្រប់ភស្តុតាងរូបវន្តទាំងអស់ ដែលតម្រូវឱ្យអ្នកស៊ើបអង្កេតប្រើប្រាជ្ញារបស់គាត់និងលទ្ធភាពរកហេតុផល និងបទពិសោធន៍របស់គាត់ទៅ

[55] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៧៣

លើហេតុការណ៍នោះ ។ លទ្ធភាពក្នុងការទទួលស្គាល់ និងប្រមូលភស្តុតាងរូបវន្តដោយសុក្រឹតភាពគឺដើម្បីដោះស្រាយ និងចោទប្រកាន់លើបទល្មើសទាំងឡាយ ។ ក្នុងករណីជាច្រើនមន្ត្រីនគរបាលយុត្តិធម៌ ដែលការពារនិងឆែកឆេរកន្លែងកើតហេតុ ដើរតួនាទីយ៉ាងសំខាន់ក្នុងការវិភាគថាតើភស្តុតាងរូបវន្ត អាចត្រូវបានប្រើប្រាស់ក្នុងការដោះស្រាយ ឬចោទប្រកាន់នូវបទល្មើស ឬអត់ ។

**កថាខណ្ឌ ២ ដំណើរទៅកាន់កន្លែងកើតហេតុ**

ជាទូទៅ មន្ត្រីនគរបាលយុត្តិធម៌ធ្វើដំណើរទៅកន្លែងកើតហេតុ មិនមែនធ្វើដោយឥតគ្រោងទុកនោះឡើយ គឺត្រូវរៀបចំផែនការយ៉ាងម៉ត់ចត់ និងអនុវត្តតាមគោលការណ៍មួយចំនួនដូចជា :

កាលណាមន្ត្រីនគរបាលយុត្តិធម៌បានដឹងពីបទល្មើស ជាបឋមខ្លួនត្រូវតែពិនិត្យនូវភាពគួរឱ្យជឿជាក់បាននៃដំណឹងដែលទទួលបាន ពិតឬអត់ ហើយចាត់វិធានការ ដូចជា ថែរក្សាស្លាកស្នាមនឹងតម្រុយ វិធានការសង្គ្រោះបុគ្គល និងវិធានការសន្តិសុខចាំបាច់នានា ជាមុន ។ ដើម្បីបំពេញប្រតិបត្តិការនេះ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចធ្វើដំណើរទៅកាន់កន្លែងកើតហេតុ (យោងតាមមាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ និងបទល្មើសជាក់ស្តែង) ក្នុងលក្ខខណ្ឌដែលបទល្មើសនោះអាចត្រូវបានពិនិត្យឃើញជាក់ស្តែង ។ ភាពចាំបាច់នេះកើតឡើងស្ទើរតែគ្រប់ករណីនៃបទឧក្រិដ្ឋ ។ ការត្រួតពិនិត្យកត់ត្រាត្រូវតែធ្វើបើសិនជាការណ៍នេះអាច ជំរុញឱ្យឃើញជាក់ស្តែងនូវរឿងហេតុ តម្រុយ ឬស្លាកស្នាមដែលបន្សល់ទុកដោយចារី ។ នៅពេលមាន ដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ មានកាតព្វកិច្ចធ្វើដំណើរទៅកាន់ទីកន្លែង ដើម្បីពិនិត្យកត់ត្រា បើសិនជាបេសកកម្មនេះ មានចុះដីកា ។ រីឯ ក្នុងការស៊ើបអង្កេតបឋមវិញ ការធ្វើដំណើរទៅកាន់ទីកន្លែងមិនមានចែងក្នុងអត្ថបទជាក់លាក់មួយនោះទេ ប៉ុន្តែជាការសមហេតុផលដែលចាំបាច់ត្រូវធ្វើដំណើរទៅកាន់ទីកន្លែង គ្រប់ករណីដែលបទល្មើសត្រូវស៊ើបអង្កេត នោះគេអាចឱ្យគេកត់ត្រាជាក់ស្តែងបាន ។ មុនពេលធ្វើដំណើរទៅកាន់ទីកន្លែង ឬក្នុងពេលជាមួយគ្នា មន្ត្រីនគរបាលយុត្តិធម៌ត្រូវ[56] :

**រាយការជូន** :

-នាយកអង្គភាព

-ព្រះរាជអាជ្ញា (ជាយថាហេតុក្រោយពីការធ្វើដំណើរ)

[56] សៀវភៅ **និតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល** (អំណោយស្ថានទូតបារាំង) ឆ្នាំ ២០០៩ ត្រង់ទំព័រ ៧៣ ចំណុច ២.១

-អាជ្ញាធររដ្ឋបាលមួយចំនួន (អភិបាល...) ចំពោះសំនុំរឿងដែលមានផលវិបាកលើជីវិតជីវភាពសាធារណៈ គឺជាការទទួលខុសត្រូវរបស់នាយកអង្គភាព ។

**សុំ ឬបញ្ជាឱ្យសុំជំនួយទៅតាមប្រភេទនៃសំនុំរឿង :**

-ពីអ្នកបច្ចេកទេសអត្តសញ្ញាណតុលាការ

-អង្គភាពសង្គ្រោះ (គ្រូពេទ្យ អ្នកពន្លត់អគ្គីភ័យ...)

-អង្គភាពសន្តិសុខ (សារព័ន្ធផ្លូវ អគ្គីសនី យោធិននៃកងវិស្វកម្ម...)

**បង្កើតក្រុមការងារអន្តរាគមន៍មួយ**

មន្ត្រីនគរបាលយុត្តិធម៌ដែលបានទទួលបណ្តឹងមុនគេ ឬត្រូវចាត់តាំង បង្កើតក្រុមការងារអន្តរាគមន៍មួយដែលមានសមាសភាពជាមន្ត្រីរាជការម្នាក់ ឬច្រើននាក់ដើម្បីជាជំនួយ ក្នុងការស្នើសុំរបស់ខ្លួន (បរិវេនសុវត្ថិភាព ។ល។ ) ។

## កថាខណ្ឌ ៣ ប្រតិបត្តិការនៅកន្លែងកើតហេតុ

ការស៊ើបអង្កេតទាំងអស់ មិនមែនសុទ្ធតែអាចសន្និដ្ឋានបានមុនពីអ្វីដែលអាចកើតឡើងនោះទេ ដែលជាញឹកញាប់អ្នកស៊ើបអង្កេតត្រូវតែទៅកន្លែងកើតហេតុភ្លាមៗ ដោយពុំបានធ្វើផែនការអនុវត្តមុននោះទេ ។

### ១. ការចាត់ចែងបឋមនៅកន្លែងកើតហេតុ

គោលបំណងនៃការចាត់ចែងបឋម គឺដើម្បីស្វែងរក នូវវត្ថុតាងដែលអាចរកបានដែលទាក់ទងនឹងប្រតិបត្តិការនៅកន្លែងកើតហេតុ ហើយធ្វើការកំណត់អត្តសញ្ញាណជនល្មើស ។ នៅក្នុងការចាត់ចែងបឋមនេះ មន្ត្រីនគរបាលនៅមូលដ្ឋានដែលមានវត្តមាននៅកន្លែងកើតហេតុមុនគេបង្អស់ត្រូវ[57] :

-ធ្វើការសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះ

-ពិនិត្យថាតើមានបទល្មើស ឬអត់ ?

-ផ្តល់ពត៌មានដល់អង្គភាពស្ថាប័នពាក់ព័ន្ធ ដូចជា

[57]សៀវភៅ **អត្ថាធិប្បាយច្បាប់ ភស្តុតាង ក្នុងរឿងក្តីព្រហ្មទណ្ឌ** រៀបរៀងដោយ **លោកចៅក្រម ហ៊ីង ធីឫទ្ធិ** (ភាគ ២) ទំព័រ ៨៣ ដល់ ទំព័រ ៨៤

+នគរបាល (រាជធានី ខេត្ត ស្រុក ខណ្ឌ)

+នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង (យោងតាមប្រភេទរឿងហេតុ)

+ជូនដំណឹងទៅព្រះរាជអាជ្ញា

-ចាត់វិធានការការពារភស្តុតាង ពិសេសភស្តុតាងដែលងាយនឹងខូចខាត ឬបាត់បង់មុនមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រមកដល់

-ដៅព្រំដែន និងហ៊ុំព័ទ្ធកន្លែងកើតហេតុ កំណត់ច្រកចេញចូលកន្លែងកើតហេតុ

-បង្កើតគណៈកម្មការ ដើម្បីត្រួតពិនិត្យទីកន្លែងកើតហេតុ

-គណៈកម្មការនេះត្រូវពិភាក្សាដើម្បីបើកយុទ្ធនាការចូលកន្លែងកើតហេតុ

-បែងចែកឱ្យជំនាញណាចូលមុន ជំនាញណាចូលបន្ទាប់ ហើយជំនាញនីមួយៗធ្វើអ្វីខ្លះ ដើម្បីជៀសវាងកុំឱ្យកិច្ចប្រតិបត្តិការត្រួតពិនិត្យទីកន្លែងកើតហេតុ ក្លាយទៅជាការបំផ្លាញភស្តុតាង តាមរយៈការបែងចែកភារកិច្ចមិនបានច្បាស់លាស់ ។

**២. វិធានការសណ្តាប់ធ្នាប់សាធារណៈ**

ក្នុងប្រតិបត្តិការបំពេញបេសកកម្មរបស់ខ្លួននៅកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែអនុវត្តនូវវិធានការមួយចំនួននៅកន្លែងកើតហេតុក្នុងគោលដៅ ធ្វើឱ្យបេសកកម្មរបស់ខ្លួនទទួលបាននូវផលវិជ្ជមាន ។ វិធានការទាំងអស់នោះមានដូចជា :

**២.១ វិធានការបង្ការការពារ**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែផ្តល់អទិភាពដល់វិធានការការពារ ដូចជា ផ្តល់ការសង្គ្រោះដល់ជនរងគ្រោះ ជាមុនគេបង្អស់ ។ បើសិនជនរងគ្រោះនៅមានជីវិត ករណីជួយមនុស្សមានសារៈសំខាន់ជាងការស៊ើបអង្កេត ។ គាត់ត្រូវបញ្ជូនជនរងគ្រោះ ទៅគ្រឹះស្ថានព្យាបាលណាមួយជាបន្ទាន់ ។ ប៉ុន្តែ បើសិនជាការស៊ើបអង្កេតនេះមិនរារាំង ឬពន្យាពេលដល់ការព្យាបាលជនរងគ្រោះទេនោះ អ្នកស៊ើបអង្កេតត្រូវកត់ត្រានូវទីតាំង និង ជនរងគ្រោះព្រមទាំង អត្តសញ្ញាណ ត្រូវឱ្យមន្ត្រីរាជការម្នាក់ ឬពីរនាក់ ដើម្បីធ្វើជា

ជំនួយការដែលត្រូវ កត់ត្រាហេតុដែលមានប្រយោជន៍ ចម្លើយជនរងគ្រោះ និងជាយថាហេតុរឹបអូសសំលៀកបំពាក់ ដែលផ្តល់អត្ថប្រយោជន៍ដល់ការស៊ើបអង្កេត ។

### ២.២ វិធានការអន្តរាគមន៍នៅកន្លែងកើតហេតុ

នៅក្នុងការធ្វើអន្តរាគមន៍ទីកន្លែងនេះ អ្នកស៊ើបអង្កេតត្រូវធ្វើប្រតិបត្តិការដូចជា :

❖ **ការឡោមព័ទ្ធកន្លែងកើតហេតុ**

មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែឡោមព័ទ្ធទីកន្លែង និងបិទច្រកចេញដើម្បីការពារ និងថែរក្សាស្លាកស្នាម និងតម្រុយបន្សល់ទុក ព្រមទាំងរារាំងបុគ្គលគ្រប់រូបមិនឱ្យគេចខ្លួនដូចជាជនសង្ស័យ ឬសាក្សីមានប្រយោជន៍ ។ មន្ត្រីនគរបាលយុត្តិធម៌អាចរារាំងបុគ្គលគ្រប់រូបមិនឱ្យទៅឆ្ងាយពីកន្លែងកើតហេតុរហូតដល់ប្រតិបត្តិការរបស់ខ្លួនត្រូវបានបញ្ចប់ ។ ក្នុងពេលឡោមព័ទ្ធទីកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវ :

-រាប់ចំនួនអ្នកមានវត្តមាន

-ធ្វើអត្តសញ្ញាណកម្មអ្នកទាំងនោះ

-កត់ត្រាមូលហេតុ ឬអង្គហេតុនៃវត្តមានអ្នកទាំងនោះ

-ប្រមូលពួកគេដាក់ក្នុងកន្លែងមួយ ដូចជា ទីធ្លា ជណ្តើរ បន្ទប់ជាដើម ដែលមិនទាក់ទងនឹងទីកន្លែងដែលត្រូវពិនិត្យ ។

បុគ្គលសង្ស័យគ្រប់រូបនឹងត្រូវបានធ្វើអចលនកម្ម និងឆែកឆេររាងកាយយ៉ាងម៉ត់ចត់ ។ ត្រូវចាំថានៅពេលដែលមកដល់ទីកន្លែងកើតហេតុ អ្នកស៊ើបអង្កេតត្រូវស្វែងរកជនល្មើស និងសាក្សីឱ្យបានកាន់តែលឿនតាមដែលអាចធ្វើទៅបាន ។ យើងចាត់វិធានការលើពួកគេដោយសង្ខេបដូចខាងក្រោម[58] :

**ចំពោះជនល្មើស ឬជនសង្ស័យ** : ត្រូវដាក់ឱ្យនៅដាច់ដោយឡែក ធ្វើការឆែកឆេរ និងធានាសុវត្ថិភាពរបស់ជននេះ ។ មានន័យថា ជនល្មើសត្រូវដាក់ឱ្យដាច់ដោយឡែកពីកន្លែងកើតហេតុ ពីអ្នកដទៃ

[58] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៧៨

ជនរងគ្រោះ ឬអ្នកដែលនឹងធ្វើជាសាក្សីឱ្យបានរហ័ស ។ ឆែករកវត្ថុតាងអ្វីដែលស្ថិតនៅក្រោមកាន់កាប់របស់ជនល្មើស ឬឯកសារ ដែលគេនឹងអាចប្រើដើម្បីជួយក្នុងការរត់គេចខ្លួន ឬអាវុធដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ខ្លួនរបស់ពួកគេ និងអ្នកដទៃ ។ ពួកគេត្រូវបានធានាសុវត្ថិភាពទៅតាមហេតុការណ៍នៃបទល្មើស ។ ប្រសិនបើមិនអាចគ្រប់គ្រងជនសង្ស័យបានទេ មន្ត្រីនគរបាល ជនរងគ្រោះ ឬសាក្សីអាចមានគ្រោះថ្នាក់ ។

**ចំពោះសាក្សី** : ត្រូវធ្វើកំណត់ហេតុ ដាក់សាក្សីឱ្យនៅឆ្ងាយពីគេ ឬអាចធ្វើការឃាត់ខ្លួន ។ ជាធម្មតា បើមានវត្តមានសាក្សីនៅកន្លែងកើតហេតុ មន្ត្រីនគរបាលធ្វើការសម្ភាសន៍ ពួកគាត់នៅទីនោះប្រសិនបើស្ថានភាពអំណោយផល ។ ប៉ុន្តែប្រសិនបើស្ថានភាពមិនអំណោយផលទេនោះ ត្រូវយកពួកគេទៅប៉ុស្ត៍នគរបាល ។ ពេលខ្លះវាមានការចាំបាច់ដើម្បីយកពត៌មានខ្លះៗ ដើម្បីភ្ជាប់វាជាមួយសំនុំរឿងរបស់គាត់ ។ ក្នុងករណីជាញឹកញាប់ គឺសាក្សីតែងតែអះអាងថា មិនបានឃើញ ឮ និងនិយាយអ្វីទាំងអស់ នេះពីព្រោះតែគាត់ខ្លាចមានបញ្ហាសុវត្ថិភាពដល់គាត់នៅពេលបន្ទាប់ ។ ប៉ុន្តែការដែលទទួលបានពត៌មានពីសាក្សីគឺវាមានសារៈសំខាន់ដំបូងសំរាប់នាំទៅរកការទទួលបាន នូវផលវិជ្ជមានក្នុងការស៊ើបអង្កេតរបស់ខ្លួន ។ ប៉ុន្តែ ត្រូវតែឃាត់ខ្លួនសាក្សី បើមានការរឹងទទឹងណាមួយ ព្រោះការឃាត់ខ្លួននេះនឹងធ្វើឱ្យមន្ត្រីនគរបាលទទួលបាននូវភាពលម្អិតលើរឿងហេតុ ដើម្បីធ្វើជាភស្តុតាងប្រឆាំងនឹងជនសង្ស័យ ។ ម្យ៉ាងវិញទៀត ត្រូវហាម បុគ្គលដ៏ទៃដែលគ្មានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ដូចជា អ្នកចង់ដឹងចង់ឮ អ្នកកាសែត នគរបាលដែលមិនបានចូលរួមក្នុងការស៊ើបអង្កេតជាដើម មិនត្រូវឱ្យចូលក្នុងទីកន្លែងកើតហេតុជាដាច់ខាត ។

### ៣. ការពិនិត្យកន្លែងកើតហេតុ និងទីកន្លែងជុំវិញ

តាមលក្ខណៈទូទៅ អ្នកបច្ចេកទេសអត្តសញ្ញាណតុលាការ ជាអ្នកអន្តរាគមន៍ដំបូងបង្អស់ក្នុងគ្រប់សំនុំរឿងសំខាន់ៗ ។ ពីព្រោះ មុននឹងបង្ហាញភស្តុតាងផ្សេងៗទៀត ចាំបាច់ត្រូវរក្សាសភាពដើមទីកន្លែងដោយការថតរូប ។ ត្រូវការពារវាកុំឱ្យមានការបំផ្លាញណាមួយពីសំណាក់មនុស្ស និងករណីធម្មជាតិជាដើម ។

<u>**ឧទាហរណ៍**</u> : គេត្រូវយកក្រណាត់គ្របលើសាកសពដែលត្រូវបានរំលោភ ឬធ្វើឃាត ដើម្បីការពារពីធាតុអាកាស ឬពីធូលីហ៊ុយមកលើជាយថាហេតុ ។ ម្យ៉ាងវិញទៀត ក៏ត្រូវគ្របការពារស្នាមម្រៀមដៃស្លាកស្នាម ឱ្យបានត្រឹមត្រូវ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវ**គោលការណ៍នៃការស្រាវជ្រាវទាំង ៨ (ប្រាំបី)** ចំណុចនៅកន្លែងកើតហេតុ ដែលមានដូចជា[59] :

-ពិចារណា គូសបន្ទាត់កន្លែងកើតហេតុដោយពុំធ្វើឱ្យប៉ះពាល់កន្លែងកើតហេតុ (ហ៊ុំព័ទ្ធកន្លែងកើតហេតុ)

-ថតរូបកន្លែងកើតហេតុដោយពុំមានការប៉ះពាល់អ្វីទាំងអស់

-ឆែកឆេរកន្លែងកើតហេតុ

-ថតរូបវត្ថុតាងនីមួយៗនៅពេលដែលរកឃើញ

-ពិនិត្យស្នាមម្រាមដៃវត្ថុតាងនីមួយៗនៅពេលដែលរកឃើញ

-ពិនិត្យ DNA វត្ថុតាងនីមួយៗនៅពេលដែលរកឃើញ

-ប្រមូល និងដាក់ឈ្មោះវត្ថុតាងនៅពេលដែលរកឃើញ

-អនុវត្តកន្លែងកើតហេតុដទៃ ដូចគ្នាទៅនឹងកន្លែងកើតហេតុទីមួយដែរ ។

### កថាខណ្ឌ ៤ តួនាទី និងការទទួលខុសត្រូវនៅកន្លែងកើតហេតុ

ដូចដែលបានរៀបរាប់ជូនខាងលើ ដែលមន្ត្រីនគរបាល ត្រូវបែងចែកគណៈកម្មការនីមួយៗ ដែលទទួលតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ខុសៗគ្នា ហើយក្នុងនោះមានបែងដូចជា :

#### ១. មន្ត្រីភាន់ភាប់បញ្ជីកត់ត្រានៅកន្លែងកើតហេតុ

ជាទូទៅ បើសិនជាវត្ថុមានមនុស្សកាន់តែតិចនៅកន្លែងកើតហេតុ នោះគ្រោះថ្នាក់ទំនងកាន់តែតិចដែរ មានន័យថាកន្លែងកើតហេតុនឹងមិនមានហានីភ័យខ្ពស់ក្នុងការបំផ្លាញតម្រុយ ។ ជាការចាំបាច់ត្រូវធ្វើការ ហ៊ុំព័ទ្ធកន្លែងកើតហេតុ ចាក់សោរទ្វារ រ៉ូតវាំងនន ឬប៉ារ៉ាស ។ល។ ដើម្បីសម្រួលដល់បេសកកម្មការងាររបស់ខ្លួន និងការពារកន្លែងកើតហេតុជៀសវាងបាត់បង់តម្រុយ ឬភស្តុតាងណាមួយជាយថាហេតុ។

[59] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៨១

ជាការចាំបាច់ ត្រូវតែមានអ្នកកាន់កាប់សៀវភៅបញ្ជីកត់ត្រានៅកន្លែងកើតហេតុ ក្នុងការកត់ត្រាពេលវេលា និងសេចក្តីលម្អិតរាល់ព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទិននឹងកន្លែងកើតហេតុ ។ អ្នកកាន់កាប់បញ្ជីនេះ ត្រូវបានគេណែនាំឱ្យនៅយាមកន្លែងកើតហេតុ ហើយកត់ត្រាលម្អិតអំពីមនុស្សទាំងឡាយដែលចេញចូលកន្លែងកើតហេតុ ។ សៀវភៅបញ្ជីនេះត្រូវធ្វើយ៉ាងត្រឹមត្រូវ ព្រោះថាវាអាចត្រូវបានតុលាការពិនិត្យ ពិច័យនៅពេលក្រោយ ។ គេត្រូវកត់ត្រាព័ត៌មានមួយចំនួនដូចជា :

-ឈ្មោះមន្ត្រីនគរបាល

-ម៉ោងចេញចូលកន្លែងកើតហេតុ និង

-មូលហេតុដែលពួកគេចូលទៅទីនោះ ។

អ្នកស៊ើបអង្កេតដទៃទៀត និងមន្ត្រីនគរបាល រួមមាន មន្ត្រីនគរបាលជាន់ខ្ពស់ដែលមិនមានភារកិច្ចនៅកន្លែងកើតហេតុ និងអ្នកដែលចង់ចូលមើលកន្លែងកើតហេតុ មិនត្រូវបានអនុញ្ញាតឱ្យចូលមើលឡើយ ។ អ្នកកាន់កាប់សៀវភៅបញ្ជី មានភារកិច្ចត្រួតពិនិត្យអ្នកដែលអាចចូលកន្លែងកើតហេតុបានដូច្នេះហើយគាត់ត្រូវតែអង្គុយនៅចំណុចច្រកចេញចូល កន្លែងកើតហេតុ ដែលគេហៅថា "ច្រកចេញចូលតែមួយ" ។[60]

### ២. មន្ត្រីថតរូប ឬថតវីដេអូនៅកន្លែងកើតហេតុ

អ្នកស៊ើបអង្កេត ដាច់ខាតត្រូវតែថតរូប ឬវីដេអូ នៅកន្លែងកើតហេតុ ដែលរួមមានទិដ្ឋភាពពីខាងមុខ ពីខាងក្រោយ និងពីចំហៀងនៃកន្លែងកើតហេតុ ។ មន្ត្រីនគរបាលម្នាក់ត្រូវបានចាត់តាំងជាអ្នកថតរូប ហើយមិនត្រូវធ្វើឱ្យម៉ាស៊ីនថត ឬម៉ាស៊ីនវីដេអូ ខូច ឬថតមិនកើតនោះទេ ព្រោះថារូបភាព ឬវីដេអូមានសារៈសំខាន់ណាស់ សំរាប់ការស៊ើបអង្កេត ហើយវាអាចជាភស្តុតាងដ៏សំខាន់សម្រាប់បង្ហាញចំពោះមុខតុលាការបានទៀតផង ជាពិសេសវាបានបង្ហាញពីអ្វីដែលអ្នកកត់ត្រាមិនបានកត់ត្រាចូលក្នុងបញ្ជីរបាយការណ៍ ហើយល្អជាងគំនូសប្លង់ដោយដៃ ឬកំណត់ហេតុជាដើម ។ គេត្រូវរក្សាបញ្ជីរូបថត

[60] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៨២

ដែលថតបានទាំងអស់ និងសេចក្ដីបរិយាយខ្លីៗដើម្បីកុំឱ្យពិបាកកំណត់អត្តសញ្ញាណភស្តុតាងណាមួយនៅក្នុងដំណាក់កាលបន្តបន្ទាប់មកទៀត ។[61]

### ៣. មន្ត្រីគំនូសប្លង់កន្លែងកើតហេតុ

ដើម្បីកត់ត្រាអំពីស្ថានភាពនៅកន្លែងកើតហេតុ និងកំណត់ទីតាំងស្ថានភាពនៃវត្ថុតាង គេត្រូវគូសគំនូសប្លង់ទីតាំងកើតហេតុ បើទោះបីជាបានថតរូបរួចហើយក៏ដោយ ព្រោះវាអាចនឹងរលប់មុនពេលយកវាទៅប្រើប្រាស់ ឬថៃដន្យត្រូវបាត់ ឬខូចជាដើម ។ ទទឹមនឹងនេះដែរ វាអាចចាំបាច់ដល់ការនិយាយយោងដល់ទីតាំងនៃវត្ថុតាង ឬស្ថានភាពនៃទីតាំងកើតហេតុនោះ ។ បញ្ហានេះអាចធ្វើទៅបាន ដោយនិយាយយោងដល់គំនូសប្លង់ដោយដៃ ។[62] ទោះបីជាបានធ្វើគំនូសប្លង់នៅកន្លែងកើតហេតុក៏ដោយ ក៏រាល់ការវាស់វែងទាំងអស់ត្រូវតែដាក់សញ្ញាសំគាល់ឱ្យបានត្រឹមត្រូវ ដើម្បីកំណត់ទីតាំងពិតប្រាកដនៃវត្ថុតាង គ្រឿងសង្ហារឹម ទ្វារ បង្អួច និងវត្ថុផ្សេងៗទៀតដែរ ។

### ៤. មន្ត្រីឆែកឆេរ និងរឹបអូស

ចំពោះមន្ត្រីដែលជាអ្នកឆែកឆេរ និងរឹបអូស វាអាស្រ័យទៅលើទីកន្លែងកើតហេតុនីមួយៗ និងមន្ត្រីដែលមានភារកិច្ចចូលក្នុងកន្លែងកើតហេតុ និងស្រាវជ្រាវរកវត្ថុតាង ។ មន្ត្រីគ្រប់រូបដែលចូលទៅកាន់កន្លែងកើតហេតុ គឺចាំបាច់ត្រូវពាក់ស្រោមដៃ ពាក់ម៉ាស និងមានស្រោម ឬថង់ច្រកពីលើស្បែកជើង ។ ឈ្មោះមន្ត្រីទាំងអស់ដែលចូលទៅក្នុងកន្លែងកើតហេតុ ត្រូវបានកត់ចូលក្នុងសៀវភៅបញ្ជីកន្លែងកើតហេតុដោយមានបញ្ជាក់ពីពេលម៉ោង និងមូលហេតុ ច្បាស់លាស់ ដែលពួកគេចូលទៅទីនោះ ។ ការស្រាវជ្រាវរបស់ពួកគាត់គឺត្រូវបានធ្វើដោយម៉ត់ចត់ និងពេញលេញក្នុងការស្វែងរកតម្រុយ ឬវត្ថុតាង ។ វត្ថុតាងដែលត្រូវបានរកឃើញនៅកន្លែងកើតហេតុនោះ គឺវាមានតម្លៃជាង ភស្តុតាងដទៃៗទាំងអស់ដែលវាអាចបង្ហាញប្រាប់ថាការស្រាវជ្រាវអាចមានទំហំធំប៉ុណ្ណា ។ ជាទូទៅការស្រាវជ្រាវ គេមិនធ្វើការប្រញាប់ប្រញាល់នោះទេ ពោលគេត្រូវចាប់ផ្ដើមវាមួយៗ ពីចំណុចមួយទៅចំណុចមួយទៀត ។

**<u>ឧទាហរណ៍</u>** : ចំណុចដំបូងដូចជា ទ្វារ ច្រកទ្វា បង្អួច កន្លែងដែលមានពន្លឺ ។ល។ និងចំណុចដែលទ្រនិចនាឡិកាចង្អុល ។ គេធ្វើដូច្នេះពីបន្ទប់មួយទៅបន្ទប់មួយ ពីខាងក្រៅទៅខាងក្នុង ពិនិត្យលើកំរាលឥដ្ឋ

[61] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៨៣

[62] គំរូនៃគំនូសប្លង់កន្លែងកើតហេតុ មាននៅក្នុងឧបសម្ព័ន្ធ

ជញ្ជាំង បង្អួច ទ្វារ ពិដាន ទូរដាក់សំលៀកបំពាក់ជាដើម ជាពិសេស ធុងសម្រាម ។ រាល់ការប្រមូលបានភស្តុតាងរូបវន្តគេយករក្សាទុកមិនខ្វល់ថាវត្ថុតាងនោះ ធំ ឬតូចពេក សំខាន់ ឬមិនសូវ ច្បាស់ ឬមិនច្បាស់នោះទេ ។ ដោយសារតែការស៊ើបអង្កេតស្រាវជ្រាវគេធ្វើតាមលក្ខណៈវិទ្យាសាស្ត្រ ដែលគេប្រើម៉ាស៊ីនមីក្រូទស្សន៍ ស្រាវជ្រាវទៅលើព័ត៌មានដែលបង្ហាញដោយម៉ាស៊ីននេះដូចជា :

**-ភស្តុតាង និងវត្ថុសម្ងាត់** : អាវុធ, ទូរស័ព្ទ, កុំព្យូទ័រ ,ម៉ាស៊ីនថតរូប, រូបថត, ឯកសារ ។ល។

**-ភស្តុតាងកោសល្យវិច្ច័យ** : ស្នាមម្រាមដៃ, ស្នាមដានជើង, ដានឈាម ស្នាមឈាម ស្នាមប្រឡាក់ឈាមលើក្រណាត់, ទឹកកាម, ទឹកមាត់, សសៃអំបោះ ។ល។

នៅពេលបានកំណត់អត្តសញ្ញាណវត្ថុទាំងអស់នេះរួចហើយ ត្រូវដាក់សញ្ញាសម្គាល់នៅជាប់នឹងវត្ថុនីមួយៗ ប្រសិនជាមាន ហើយបន្ទាប់មកត្រូវថតរូបវត្ថុនោះផ្ទាល់នៅទីនោះតែម្តង ។ ប្រសិនជាគ្មានសញ្ញាលេខសំគាល់ទេ ក៏ត្រូវតែថតរូបវត្ថុនីមួយៗនៅនឹងកន្លែងនោះផងដែរ ហើយកត់ត្រា វត្ថុ និងទីតាំងរបស់វានៅក្នុងគំនូសប្លង់ដោយដៃ ។

<u>**កំណត់សម្គាល់**</u> : នៅពេលថតរូបស្នាមដានជើង ត្រូវដាក់បន្ទាត់មួយដើម្បីបង្ហាញពីប្រវែងបណ្តោយ និងបន្ទាត់មួយទៀត ដើម្បីបង្ហាញពីប្រវែងទទឹងរបស់ស្នាមដានជើងនោះ រួចហើយត្រូវថតរូបជិតចំពីលើ ដើម្បីឱ្យច្បាស់ពី ប្រវែងរបស់វា ។ ត្រូវយកក្រយៅដៃ និងក្រណាត់អំបោះ DNA ពីវត្ថុតាងដែលអាចមានភស្តុតាង មុនពេលធ្វើការវេចខ្ចប់ ។[63]

### ៥. មន្ត្រីគ្រប់គ្រងវត្ថុតាង

នៅមុនពេលធ្វើការរឹបអូសភស្តុតាងណាមួយពីកន្លែងកើតហេតុ ជានិច្ចជាកាលគេចាំបាច់ត្រូវមានមន្ត្រីម្នាក់គ្រប់គ្រងវត្ថុតាង ។ ការទទួលខុសត្រូវតែមួយគត់គឺការទទួលយកវត្ថុតាង ហើយបន្ទាប់មកត្រូវគ្រប់គ្រង វត្ថុតាងដែលបានរឹបអូសនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតទាំងមូល ។ មន្ត្រីរូបនេះត្រូវសរសេរឈ្មោះ កាលបរិច្ឆេទ និងចុះហត្ថលេខារបស់ខ្លួននៅលើស្លាកសញ្ញាសំគាល់វត្ថុតាង នៅពេលដែលគាត់ទទួលយកវត្ថុតាងនោះ ហើយត្រូវរក្សាទុកវត្ថុតាងទាំងអស់នោះនៅជាមួយគាត់ រហូតដល់គាត់ប្រគល់វាឱ្យទៅប៉ុស្តិ៍នគរបាល ហើយបន្ទាប់មកត្រូវរក្សាទុកយ៉ាងម៉ត់ចត់ និងមានសុវត្ថិភាព ។ នៅ

[63] គំរូរូបថតដានស្បែកជើង និង គំរូរូបស្នាមម្រាមដៃ មាននៅក្នុងឧបសម្ព័ន្ធ

ពេលដែលគេត្រូវការវត្ថុតាងទាំងនោះយកទៅធ្វើវិភាគ ជាអាទិ៍ នៅកន្លែងកោសល្យវិច្ច័យ ឬបានស្នើដោយអ្នកជំនាញបច្ចេកទេសណាមួយ វាគឺជាភារកិច្ចរបស់មន្ត្រីគ្រប់គ្រងវត្ថុតាង ក្នុងការសម្របសម្រួលការងារនេះដែលជានិច្ចជាកាលត្រូវតែធានាកិច្ចដំណើរការគ្រប់គ្រងវត្ថុនីមួយៗឱ្យបានពេញលេញ ។ មន្ត្រីគ្រប់គ្រងវត្ថុតាង ត្រូវតែរក្សាទំនាក់ទំនងឱ្យបានទៀងទាត់ជាមួយមន្ត្រីស៊ើបអង្កេតដែលគាត់អាចនឹងប្រាប់ពីការធ្វើវិភាគវត្ថុតាងចាំបាច់មួយចំនួន ។ ប្រសិនបើជាព្រះរាជអាជ្ញា ឬមេធាវីណាម្នាក់ចង់ពិនិត្យមើលវត្ថុតាងណាមួយ វាគឺជាការទទួលខុសត្រូវមួយទៀតរបស់មន្ត្រីគ្រប់គ្រងវត្ថុតាងនោះក្នុងការសម្របសម្រួលការងារនេះ ។ នៅពេលដែលករណីនេះត្រូវបានបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះ វាក៏ជាការទទួលខុសត្រូវទៀតរបស់មន្ត្រីគ្រប់គ្រងវត្ថុតាង ក្នុងការធានាថារាល់វត្ថុតាងចាំបាច់ទាំងអស់ត្រូវបានបញ្ជូនទៅតុលាការ ។[64]

## ផ្នែកទី ២ បច្ចេកទេសក្នុងការប្រមូល និងរក្សាទុកវត្ថុតាង

រាល់ការប្រមូលវត្ថុតាងទាំងអស់ ត្រូវតែវេចខ្ចប់ ដឹកជញ្ជូន និងរក្សាទុក តាមសភាពដើមរបស់វា មិនត្រូវផ្លាស់ប្តូរ ឬប្រែប្រួលវាទៅជាវត្ថុផ្សេងទេរហូតដល់អ្នកជំនាញត្រួតពិនិត្យ ឬរហូតត្រូវបានគេបង្ហាញវានៅក្នុងតុលាការ ។ ភស្តុតាងទាំងអស់ត្រូវតែជាប់ពាក់ព័ន្ធនឹងកន្លែងកើតហេតុតាមរយៈ រូបថត គំនូសប្លង់ដោយដៃ ដ្យាក្រាម ការពិពណ៌នាជាលាយលក្ខណ៍អក្សរ និងសក្ខីកម្មផ្ទាល់មាត់ ។ ការធ្វើបែបនេះ គឺជាដំណាក់កាលដំបូងក្នុងការប្រមូលភស្តុតាងប្រកបដោយវិជ្ជាជីវៈ ដែលផ្តល់ផលវិជ្ជមានដល់ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ។

### កថាខណ្ឌ ១ ការប្រមូលវត្ថុតាងជាសំលៀកបំពាក់

បំណែកក្រណាត់ពីសំលៀកបំពាក់ អាចមានទូទៅនៅកន្លែងកើតហេតុ វាអាចជារបស់ជនល្មើស ឬជនរងគ្រោះជាអ្នកបន្សល់ទុក ហើយវាមិនត្រឹមតែអាចជួយក្នុងការកំណត់អត្តសញ្ញាណមនុស្សតាមរយៈភិនភាគរបស់វាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចមានតម្លៃជាភស្តុតាងកោសល្យវិច្ច័យបានទៀតផង ។ នៅពេលរកឃើញវានៅកន្លែងកើតហេតុ ត្រូវដាក់លេខសំគាល់ហើយថតរូប ។ ប្រសិនបើយល់ថាចាំបាច់ត្រូវកត់ចំណាំទីតាំងចំៗ ដោយធ្វើការវាស់វែងវត្ថុនោះពីជ្រុងម្ខាងទៅជ្រុងម្ខាងទៀតនៃកន្លែងកើតហេតុ ដែលអាចឱ្យដឹងពីទីតាំងវត្ថុនោះពិតប្រាកដ ។ ត្រូវបញ្ជាក់ថា ទីតាំងវត្ថុតាងនោះត្រូវកត់

[64] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ គ្រង់ ទំព័រ ៨៥

ចំណាំក្នុងគំនូសបប្លង់ដោយដៃ មុននឹងយកវាចេញពីកន្លែងកើតហេតុ ។ បន្ទាប់មកមន្ត្រីរឹបអូសត្រូវឆ្កឹះយក សំលៀកបំពាក់ចេញដោយប្រើដន្នៀសប្រើហើយបោះចោល ប្រសិនបើមាន ឬ ដោយការចាប់ច្បិចយក វត្ថុនោះដោយដៃធ្វើយ៉ាងណាឱ្យការប៉ះពាល់មានតិចតួចបំផុតតាមដែលអាចធ្វើបាន រួចហើយដាក់វាចូលក្នុងថង់ក្រដាស់មួយសម្រាប់ដាក់ភស្តុតាង ។ រាល់សំលៀកបំពាក់ ឬសម្ភារៈត្រូវតែធ្វើការវេចខ្ចប់តែដោយក្រដាសប៉ុណ្ណោះ ដោយសារតែវាអាចឱ្យអុកហ្ស៊ីហ្សែនអាចចេញចូលថង់បានដែលធានាឱ្យសម្ភារៈនោះមិនដុះផ្សិត ។ រាល់ថង់ក្រដាសត្រូវតែបានធ្វើការវេចខ្ចប់ក្នុងលក្ខណៈវិជ្ជាជីវៈ ដើម្បីរក្សារូបរាងភស្តុតាង ។ ម៉្យាវិញទៀត ការវេចខ្ចប់ត្រូវតែឱ្យបានជិតដែលគ្មានអ្វីអាចចេញចូលថង់ក្រដាសនោះបាន ។ វិធីអនុវត្តដែលល្អបំផុតក្នុងការធ្វើបែបនេះ មានដូចជា :

-បត់ជ្រុងទាំងពីរផ្នែកខាងលើនៃថង់ ក្នុងមុំ ៤៥ អង្សារ

-បន្តបត់ថង់ផ្នែកខាងលើឱ្យត្រឹមត្រូវតាមជ្រុងបត់

-បត់វាពីលើមួយជាន់ទៀតបន្ទាប់មកត្រូវបិទស្កុតតាមជ្រុងនីមួយៗនៃថង់ផ្នែកខាងលើ ដើម្បីធ្វើឱ្យប្រាកដថា មិនមានចន្លោះប្រហោង

-បន្ទាប់មកត្រូវបន្តបិទស្កុតពីលើស្នាមបត់នោះទាំងមូល

-ត្រូវបិទស្កុតពីលើថង់ក្រដាសឱ្យបានត្រឹមត្រូវ

-ចុងក្រោយ ត្រូវសសេរបំពេញលើស្លាកសញ្ញាសម្គាល់វត្ថុតាង ដូចបានបរិយាយខាងលើ មុននឹងប្រគល់ឱ្យមន្ត្រីគ្រប់គ្រងវត្ថុតាង ។[65] វត្ថុតាងដែលចាប់បាន ត្រូវតែទុកនៅកន្លែងដែលមានសីតុណ្ហភាពត្រជាក់មធ្យម ស្ងួត និងដោយម៉ត់ចត់ មុននឹងប្រគល់វាទៅឱ្យប៉ុស្តិ៍នគរបាល ។

<u>**កំណត់សម្គាល់**</u> : នៅពេលធ្វើការរឹបអូសសំលៀកបំពាក់ពីជនសង្ស័យ ឬជនរងគ្រោះណាម្នាក់ ត្រូវធ្វើការវេចខ្ចប់វា តាមរបៀបដូចគ្នា ហើយត្រូវសរសេរបំពេញលើស្លាកសញ្ញាសំគាល់វត្ថុតាង ។ រីឯវត្ថុគ្រប់ប្រភេទដែលមិនមែនជាសាច់ក្រណាត់ ត្រូវធ្វើការវេចខ្ចប់ក្នុងថង់ផ្លាស្ទិកមួយដែលនៅលើមាត់ថង់នោះមានខ្សែរឆ្នូតអាចបិទបានប្រសិនជាមាន ។

[65] គម្រូនៃការវេចខ្ចប់ មាននៅក្នុងឧបសម្ព័ន្ធ

**កថាខណ្ឌ ២ ការប្រមូលវត្ថុតាងជាឯកសារ**

វត្ថុតាងជាឯកសារ គឺជាភស្តុតាងមួយប្រភេទដែលត្រូវបានបង្ហាញនៅពេលសវនាការក្នុងទម្រង់ជាសំនុំឯកសារ ។ វត្ថុតាងប្រភេទនេះ មិនមែនសំដៅតែទៅលើ វិក័យប័ត្រ កិច្ចសន្យា ឬមតកសាសន៍ជាដើមនោះទេ តាមពិតទៅ គឺរាប់បញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលតាមរយៈនោះ ព័ត៌មានអាចត្រូវបានគេរក្សាទុក ។ រូបថត ការថតសំលេង ខ្សែភាពយន្ត អ៊ីម៉ែល ជាអក្សរទាំងអស់ នេះសុទ្ធតែជាទម្រង់នៃភស្តុតាងឯកសារ ។ សំនុំឯកសារទាំងឡាយដែលបានរកឃើញនៅកន្លែងកើតហេតុ ត្រូវតែយកទៅពិនិត្យ ហើយប្រសិនបើយល់ថាវាមានការជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតនោះ ត្រូវធ្វើការរឹបអូសវាទុកធ្វើជាវត្ថុតាង ។ ជាពិសេសត្រូវស្វែងរក ឯកសារទាំងឡាយដែលទាក់ទងនឹង :

-កិច្ចសន្យាហិរញ្ញវត្ថុ

-ឯកសារអត្តសញ្ញាណ (លិខិតឆ្លងដែន សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ។ល។)

-លិខិតធ្វើដំណើរ (ទិដ្ឋាការ សំបុត្រ ប័ណ្ណលើកដាក់ទំនិញ ប័ណ្ណសំគាល់វ៉ាលី ។ល។)

-កិច្ចសន្យាជួល ឬលិខិតភតិសន្យានៃទីតាំង ឬរថយន្ត ។

-ការគ្រប់គ្រងសេវាអាជីវកម្ម (បញ្ជីវាយមុខសេវា និងបញ្ជីតំលៃ តារាងទិន្នន័យផ្សេងៗ ។ល។)

ជារឿយៗ ដែលត្រូវធ្វើការថតចំឡងឯកសារដែលបានរឹបអូសសម្រាប់ប្រើការ ហើយទុកឯកសារដើមឱ្យបានគង់វង្សនៅក្នុងថង់មួយមានស្អុតបិទ តែត្រូវចាំថា ត្រូវតែពាក់ស្រោមដៃនៅពេលចាប់កាន់ឯកសារទាំងនោះ ប្រសិនជាត្រូវការយកឯកសារនោះទៅពិនិត្យស្នាមក្រយៅដៃ ។ ក្នុងករណីនេះ ក៏ត្រូវធ្វើដូចករណីមុន គឺត្រូវដាក់វត្ថុនោះក្នុងថង់មួយ ហើយចាប់ភ្ជាប់ស្លាកសញ្ញាសម្គាល់វត្ថុតាងពីលើវា ប៉ុន្តែមិនទាន់បិទមាត់ថង់ ត្រូវរង់ចាំរហូតទាល់តែបានថតចំឡងរួចរាល់សិន ។ ប្រសិនជាមាន ត្រូវដាក់វត្ថុតាងនៅក្នុងថង់ផ្លាស្ទិកមួយដោយសារនេះវានឹងអាចឱ្យមន្ត្រីនគរបាល ឬព្រះរាជអាជ្ញា ពិនិត្យឯកសារនោះនៅថ្ងៃខាងមុខ ដោយមិនចាំបាច់ហែក ឬបកស្អុតនោះចេញឡើយ ។

## កថាខណ្ឌ ៣ ការប្រមូលវត្ថុតាងជាអេឡិចត្រូនិក

បច្ចេកវិទ្យាព័ត៌មាន តែងមានការវិវត្តន៍ជានិច្ច ហើយបច្ចេកវិទ្យានេះ ដើរតួនាទីរឹតតែសំខាន់ខ្លាំងឡើងថែមទៀត ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សទូទៅលើពិភពលោក ។ បច្ចុប្បន្ន គេអាចរក្សាទុកព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងឧបករណ៍អេឡិចត្រូនិកដែលមានទំហំធំ ។ ពួកឧក្រិដ្ឋជនក៏បាននឹងកំពុងតែកេងយកផលប្រយោជន៍ ពីការជឿនលឿនផ្នែកវិទ្យាសាស្ត្រនេះផងដែរ ។ ពួកឧក្រិដ្ឋជន ជានិច្ចជាកាល ប្រើប្រាស់ទូរស័ព្ទចល័ត កុំព្យូទ័រព្យូទ័រ ឧបករណ៍ធ្វើផែនការអេឡិចត្រូនិក និងឧបករណ៍ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដើម្បីរក្សាទុកទិន្នន័យ ក្នុងការប្រព្រឹត្តសកម្មភាពល្មើសរបស់ពួកគេ ។ ដូច្នេះ មន្ត្រីនគរបាលដែលធ្វើការស៊ើបអង្កេតនោះអាចធ្វើការរឹបអូស វត្ថុតាងអេឡិចត្រូនិកទាំងនោះពីជនសង្ស័យ ឬពីកន្លែងកើតហេតុឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយមិនត្រូវអនុញ្ញាតឱ្យជនសង្ស័យនោះប្រើប្រាស់វត្ថុតាងទាំងនោះទេ ។ វត្ថុតាងអេឡិចត្រូនិក គឺជាភស្តុតាងមួយមានតម្លៃហើយគួរតែបានចាត់ទុកវាដូចគ្នានឹងភស្តុតាងកោសល្យវិច្ច័យដែរ ដោយថែរក្សាទុកយ៉ាងយកចិត្តទុកដាក់ ។

របៀបនៃការប្រមូល និងរក្សាទុក រក្សារូបរាងដើមរបស់វា គឺអាចជាការងារមួយដែលពិបាកស្មុគ្រស្មាញ ប៉ុន្តែបើអាចរក្សាទុកវាឱ្យបានត្រឹមត្រូវ វានឹងក្លាយជាភស្តុតាងមួយដ៏រឹងមាំប្រឆាំងនឹងជនសង្ស័យ ។ ត្រូវរក្សាទុកវត្ថុតាងនោះ នៅក្នុងបន្ទប់មួយដែលមានសីតុណ្ហភាពមធ្យម ដោយមិនត្រូវស្ថិតក្នុងភាពសើមខ្លាំង និងនៅឆ្ងាយពីទំនាញមេដែក ដូចជាវិទ្យុទាក់ទងជាដើម ។

## កថាខណ្ឌ ៤ ការប្រមូលវត្ថុតាងជាវត្ថុដែលមុតស្រួច

វត្ថុមុតស្រួចមួយចំនួនដូចជា កាំបិត ម្ជុល ឬដបបែកនៅកន្លែងកើតហេតុជាប្រភពមួយដ៏ល្អ សំរាប់ស្វែងរកក្រយៅដៃ និងភស្តុតាង ឌី អិន អេ ។ វាក៏អាចបង្កគ្រោះថ្នាក់ផងដែរដល់មន្ត្រីនគរបាលដែលចាប់កាន់វត្ថុនោះដោយសារតែវាមានចុងមុតស្រួច ។ គេមិនអាចដាក់វត្ថុបែបនេះដោយផ្ទាល់ ចូលទៅក្នុងថង់ផ្លាស្ទិកបានទេ ព្រោះវាអាចចាក់ទម្លាយតូទថង់បាន ដូចនេះគេត្រូវដាក់វាចូលក្នុងដបប្លាស្ទិករឹងជាមុន មុននឹងដាក់វាចូលទៅក្នុងថង់ផ្លាស្ទិកសម្រាប់ដាក់វត្ថុតាង ។ តែគេត្រូវបិទដបនោះមុននឹងដាក់វាទៅក្នុងថង់ផ្លាស្ទិក ។ ហើយបន្ទាប់មកធ្វើដូចការរៀបរាប់ខាងមុនៗ គឺសរសេរបំពេញជាភាសាខ្មែរលើស្លាកសញ្ញាសំគាល់វត្ថុតាង ហើយបិទលើថង់ផ្លាស្ទិកនោះមុនប្រគល់ឱ្យមន្ត្រីគ្រប់គ្រងវត្ថុតាង ។

ប្រសិនបើវត្ថុមុតស្រួចនោះ មានផ្ទុកភស្តុតាង ឌី អិន អេ ត្រូវរក្សាវាទុកនៅកន្លែងមួយដែលស្ងួត ដើម្បីរក្សាភស្តុតាងនោះ ពេលខ្លះគេរក្សាវាទុកនៅក្នុងទូទឹកកក ។[66]

**កថាខណ្ឌ ៥ ការប្រមូលវត្ថុតាងជាស្លាកស្នាមផ្សេងៗ**

ជាញឹកញាប់ គេតែងតែរកឃើញនូវស្លាកស្នាម ដូចជា កង់ឡាន ម៉ូតូ ស្នាមស្បែកជើង ឬស្នាមក្រយៅដៃ ក្រយៅជើង ជាដើម នៅកន្លែងកើតហេតុ ។ ដូចច្នេះ ចំពោះស្នាមស្បែកជើង គេត្រូវថតរូបពិស្តារ លើស្នាមជិតទាំងនោះនីមួយៗដើម្បីធ្វើការ ។ គេត្រូវដាក់បន្ទាត់ពីរនៅចំហៀង និងនៅខាងខ្នងនៃស្នាមជានស្បែកជើងដើម្បីវាស់ទំហំស្នាមជានជើងនោះ ហើយជានិច្ចជាកាលត្រូវថតជិតមុខចំពីលើស្នាមដើម្បីឱ្យមើលឃើញច្បាស់ពីទំហំស្នាមជានស្បែកជើងទាំងនោះ ។ នៅពេលភិនភាគត្រូវបានថតត្រឹមត្រូវហើយ ជានិច្ចជាកាលគេពិនិត្យពិច្ច័យទៅលើស្នាមពុម្ពជាលម្អិតបន្ថែមទៀត ដើម្បីឱ្យចេញជារូបរាង និងធ្វើការប្រៀបធៀបឱ្យកាន់តែច្បាស់ ។

**កថាខណ្ឌ ៦ ការប្រមូលភស្តុតាងជាស្នាមម្រាមដៃ**

ស្នាមម្រាមដៃ និងបាតដៃនៅកន្លែងកើតហេតុ គឺជាវត្ថុតាងដ៏មានតម្លៃបំផុត ក្នុងការសន្និដ្ឋានរបស់អ្នកជំនាញ ដែលអាចជួយការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឈានទៅរកនូវលទ្ធផលមួយយ៉ាងឆាប់រហ័សក្នុងការកំណត់អត្តសញ្ញាណជនល្មើស និងជនដែលពាក់ព័ន្ធនៅកន្លែងកើតហេតុ ។

ជានិច្ចជាកាលតែងតែមានចម្ងល់ពីស្នាមម្រាមដៃនេះ ថាហេតុអ្វីបានជាអាចមានស្នាមម្រាមដៃកើតឡើង ? តាមលក្ខណៈធម្មជាតិខ្នាំងដៃម្រាមដៃ ត្រូវបានចេញជាទម្រង់នៅពេលទារកនៅក្នុងស្បូន ។ ខ្នាំងដៃចាប់ផ្តើមវិវត្តលើមេដៃនិងម្រាមដៃ ។ គោលបំណងនៃខ្នាំងដៃ គឺដើម្បីឱ្យម្រាមដៃចាប់កាន់យកវត្ថុអ្វីមួយបានយ៉ាងរឹងមាំជៀសវាងការរបូត ។ ខ្នាំងដៃអាចធ្វើឱ្យម្រាមដៃចាប់យកនូវវត្ថុបាន ។ ខ្នាំងដាំកកិតលើម្រាមដៃរបស់ពួកគេទោះតិច ឬច្រើន ។ ម្រាមដៃទាំងអស់មានការបង្កើតនិងរៀបចំតែមួយប៉ុណ្ណោះលើគម្រូ និងលក្ខណៈនៃខ្នាំដៃ ។ ខ្លាំងដៃមានចង្អូរដែលញើសហូរ ។ ញើសផ្សំជាមួយនឹងប្រេងលើដងខ្លួន និងធូលីបង្កើតជាស្នាមម្រាមដៃលើផ្ទៃរលោង ។

អ្នកជំនាញខាងស្នាមម្រាមដៃប្រើប្រាស់ម្សៅ និងសារធាតុគីមីដើម្បីធ្វើឱ្យមើលឃើញនូវស្នាមម្រាមដៃទាំងនោះ ។ ភាពដែលអាចមើលឃើញនេះអាស្រ័យលើផ្ទៃដែលពួកគេប៉ះពាល់ ប៉ុន្តែអ្នក

[66] គម្រូនៃការវេចខ្ចប់វត្ថុមុតស្រួច មាននៅក្នុងឧបសម្ព័ន្ធ

ជំនាញស្នាមម្រាមដៃអាចបង្កើនការទាញយកស្នាមម្រាមដៃពីផ្ទៃជាច្រើន ។ រយៈពេលនៃស្នាមម្រាមដៃគឺស្ទើរតែពុំអាចកំណត់បាន ដែលជាញឹកញាប់ ចុងចោទតែងនិយាយថា ពួកគេនៅកន្លែងកើត ហើយបានបន្សល់ទុកស្នាមម្រាមដៃ មុនពេលអំពើល្មើសកើតឡើង ។

ស្នាមម្រាមដៃ អាចត្រូវបានរកឃើញស្ទើរតែគ្រប់ទីតាំងនៅកន្លែងកើតហេតុ ។ ស្នាមទាំងនោះអាចរកឃើញ នៅលើកែវព័រសាឡែន ដប កន្លែងដុសខាត់ លាបថ្នាំ ឬផ្ទៃរលោងផ្សេងៗទៀត បង្កាន់ដៃទ្វារ កន្លែងកុងតាក់ភ្លើង ឌីវីឌី ឬស៊ីឌី គ្រឿងបរិក្ខារលោង និងក្រដាសជាដើម ។ល។ ស្នាមម្រាមដៃនេះអាចមានប្រភេទខុសៗគ្នា ដែលរួមមានដូចជា :

**-ស្នាមម្រាមដៃប្លាស្ទិក** : កើតចេញនៅពេលដែលម្រាមដៃ ប៉ះ ឬចុចលើវត្ថុប្លាស្ទិកនោះ ហើយបង្កើតបានជាស្លាកស្នាមអវិជ្ជមានមួយរបស់ការកកិតនេះ ដែលវត្ថុទាំងនោះមានដូចជា វត្ថុដែលទើបលាបពណ៌ សារធាតុរលាយ ឬទន់នៅពេលដែលកាន់ក្នុងដៃ ឬស្អិត ប្រេង ជ័រ កៅស៊ូ និងដីឥដ្ឋ ។ល។

**-ស្នាមម្រាមដៃដែលកើតឡើងពីសារធាតុខាងក្រៅ** : ស្នាមធូលីកើតឡើងនៅពេលដែលម្រាមដៃប៉ះលើស្រទាប់ធូលីនោះ និងធូលីមួយចំនួនដែលជាប់នឹងដៃស្រាប់ ។

**-ស្នាមម្រាមដៃដែលកើតចេញពីសរីរាង្គក្នុងខ្លួន** : ប្រេង ញើស និងក្អែល របស់មនុស្ស ដែលវាមាននៅលើដៃ ហើយបង្កើតបានជាស្នាមម្រាមដៃ នៅពេលដៃប៉ះនឹងផ្ទៃណាមួយ ។

**-ស្នាមម្រាមដៃដែលមើលពុំឃើញ** : គឺយើងមិនអាចមើលវាឃើញដោយភ្នែកទទេនោះទេ ដែលគេត្រូវធ្វើការកែប្រែ វាទើបអាចមើលឃើញ ។ ជានិច្ចជាកាល គេប្រើម្សៅដែលជាវិធីសាស្ត្រដ៏ល្អបំផុត ។ សារធាតុដែលគេប្រើនោះ គឺធ្វើឱ្យស្នាមត្រូវបានមើលឃើញយ៉ាងច្បាស់ ។ ជម្រើសនៃម្សៅ អាស្រ័យដោយផ្អែកទៅលើប្រភេទនៃផ្ទៃ ដែលស្នាមត្រូវបានរកឃើញ និងផ្នែកនៃស្នាមដែលត្រូវថែរក្សា ។ ប្រភេទដែលត្រូវបានប្រើប្រាស់ គឺកំណត់ដោយព័ណនៃបាត និងលក្ខណៈនៃផ្ទៃ ។ ខាងក្រោមនេះគឺជា

❖ **វិធីសាស្ត្រក្នុងការកែប្រែស្នាមម្រាមដៃមើលពុំឃើញដោយប្រើម្សៅ** :

ដំបូងគេយកច្រាស់ជ្រលក់ស្រាលៗចូលជ្រៅទៅក្នុងម្សៅ រួចហើយយកម្រាមដៃគោះជម្រុសម្រៅជាប់ច្រាស់នោះចោលខ្លះ ទុកតែម្រៅតិចតួចបំផុតនៅលើច្រាស់ប៉ុណ្ណោះ ។ បន្ទាប់មកត្រូវយកច្រាស់ទៅ បបោសថើៗពីលើកញ្ចក់ជារាងខ្សែកោង ។ កំទេចម្សៅនឹងជាប់គ្រប់ទីកន្លែងលើផ្នែកញ្ចក់នោះ នៅ

កន្លែងដែលមានប្រេង ឬធូលីដី ។ ប្រសិនជាមានលេចចេញស្នាមក្រយៅដៃនៅលើបន្ទះកញ្ចក់នោះ វានឹងអាចឱ្យឃើញច្បាស់ ច្រើន ឬតិច នៅលើនោះ ។

នៅពេលដែលបានកំណត់ស្នាមក្រយៅដៃរួចហើយ អ្នកស៊ើបអង្កេតត្រូវសម្រេចថាតើត្រូវទៅធ្វើតេសវានៅកន្លែងកើតហេតុ ឬត្រូវបញ្ជូនវាទៅមន្ទីរពិសោធន៍ធ្វើកោសល្យវិច្ច័យ ។ ប្រសិនបើគេត្រូវតែរកវាឱ្យឃើញភ្លាមៗ អ្នកស៊ើបអង្កេតត្រូវប្រើបន្ទះស្អិតដើម្បីផ្តិតយកវាចេញពីលើផ្ទៃរាប ។ គេអាចធ្វើដូចនេះ ដោយដាក់ខ្សែបន្ទះស្អិតពីលើដានកំបាំងទុកឱ្យម្រៅជិតជាប់បន្ទះស្អិតដើម្បីឱ្យលេចចេញជាដានស្នាមក្រយៅដៃ ។ បន្ទាប់មក ត្រូវយកបន្ទះស្អិតនោះដាក់ពីលើបន្ទះក្រដាសពណ៌សមួយសន្លឹកដែលគេអាចយកវាទៅធ្វើការកែច្នៃ បន្ថែមទៀត ។

❖ **វិធីសាស្ត្រយកស្នាមក្រយៅដៃដែលមើលពុំឃើញ** :

នៅពេលធ្វើការពង្រីកនិងថតរូបក្រយៅដៃរួចហើយ គេអាចប្រើបច្ចេកទេសមួយចំនួនដើម្បីយកស្នាមក្រយៅដៃ ដើម្បីយកទៅរក្សាទុកនិងធ្វើការវិភាគតទៅទៀត ។ វិធីសាស្ត្រក្នុងការយករួមមាន ការយកដោយបន្ទះកញ្ចក់ផ្តិតស្នាមក្រយៅដៃ ការយកជាកៅស៊ូ និងការយកតាមក្រដាសផ្លាស្ទិកភ្លឺជាដើម ។

ការយកដោយបន្ទះកញ្ចក់ផ្តិតម្សៅស្នាមក្រយៅដៃ អាចលេចចេញឱ្យឃើញនៅផ្ទៃខាងក្រោយដែលមានពណ៌ផ្សេងៗគ្នាជាច្រើន ដែលអាចមើលឃើញស្នាមក្រយៅដៃដែលបានពង្រីកដោយប្រើម្សៅពណ៌ផ្សេងៗគ្នា ។ គេយកបន្ទះមួយទៅដាក់ពីលើស្នាមក្រយៅដៃ រួចសង្កត់វាឱ្យស្មើដៃ ។ បន្ទាប់មកត្រូវលើកបន្ទះកញ្ចក់នោះដែលមានជាប់ស្នាមដានព្រាលៗពីលើ ហើយត្រូវរក្សាការពារវាកុំឱ្យប្រឡាក់ធូលីដី ឬមានស្នាមគូសឆូត ។ ការប្រើដងរ៉ូឡូ ពេលខ្លះក៏អាចជួយឱ្យមានភាពមត់រលោងនិងគ្មានពពុះបានដែរ ។ រូបភាពក្រយៅដៃ អាចលេចចេញជារូបរាងឱ្យឃើញច្បាស់ ។ អ្នកកាន់បន្ទះកញ្ចក់នោះមិនត្រូវឱ្យស្នាមក្រយៅដៃរបស់ខ្លួនជាប់នឹងបន្ទះកញ្ចក់នោះឡើយ ។ ប្រការដែលសំខាន់ មិនត្រូវឱ្យមានពពុះខ្យល់ជាប់នឹងផ្ទៃខាងក្រោម នៃបន្ទះកញ្ចក់នោះឡើយ ដែលវាអាចធ្វើឱ្យខូចតម្លៃនៃស្នាមក្រយៅដៃ និងធ្វើឱ្យស្នាមក្រយៅដៃមើលមិនឃើញច្បាស់ ។ ត្រូវជ្រើសរើសយកបន្ទះកញ្ចក់ណាដែលភ្លឺថ្លា ដែលអាចរំលេចពណ៌ច្បាស់ ។

បន្ទាប់ពីយកបានចប់សព្វគ្រប់ហើយ គេត្រូវធ្វើការគូសចំណាំអំពីភិនភាគផ្សេងគ្នាទាក់ទងនឹងប្រភេទនៃវត្ថុតាងនៃភស្តុតាងរូបវ័ន្ត ដែលគេគូសចំណាំផ្នែកខាងខ្នងនៃប័ណ្ណជាមួយនឹងលេខវត្ថុតាង

ដោយមានបញ្ជាក់ពីហត្ថលេខាសង្ខេបរបស់មន្ត្រីដែលផ្តិតយកស្នាមក្រយៅដៃ ឈ្មោះ កាលបរិច្ឆេទ និងទីតាំង ។

**កថាខណ្ឌ ៧ ការប្រមូលភស្តុតាងជា ឌី អ៊ិន អេ** (DNA)

នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាលម្អិត ថាតើអ្វីជា ឌី អ៊ិន អេ ? ហើយគេធ្វើការប្រមូលវាដោយវិធីណាខ្លះ ?

**១. សញ្ញាណទូទៅនៃ ឌី អ៊ិន អេ** (DNA)

អ្វីទៅជា ឌី អ៊ិន អេ (DNA) ? ឌី អ៊ិន អេ ឬអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិន គឺជាធាតុដំបូងនៃស្បែនទាំងមូលរបស់មនុស្សដែលត្រូវបានបង្កើតឡើង ។ ជាងនេះទៅទៀត ឌី អ៊ិន អេ របស់មនុស្សម្នាក់គឺដូចគ្នារបស់កោសិកានីមួយៗ ។ ឧទាហរណ : ឌី អ៊ិន អេ នៅក្នុងឈាមរបស់មនុស្សប្រុសម្នាក់ គឺដូចគ្នានឹង ឌី អ៊ិន អេ នៅកោសិកាស្បែក ទឹកកាម និងទឹកមាត់របស់គាត់ ។ ឌី អ៊ិន អេ គឺជាវត្ថុតាងដ៏មានឥទ្ធិពលពីព្រោះមនុស្សម្នាក់ៗ គឺមាន ឌី អ៊ិន អេ ខុសៗគ្នាលើកលែងករណីភ្លោះ ។ ដោយសារតែភាពខុសគ្នានេះ ឌី អ៊ិន អេ ដែលបានប្រមូលពីកន្លែងកើតហេតុ អាចទាក់ទងនឹងជនសង្ស័យជាមួយនឹងភស្តុតាង ឬដោះលែងជនសង្ស័យ ដែលដូចនឹងការប្រើប្រាស់ស្នាមម្រាមដៃដែរ ។ គេកំណត់នូវជនរងគ្រោះបានតាមរយៈ ឌី អ៊ិន អេ ដែលបានពីសាច់ញាតិ សូម្បីតែនៅពេលដែលខ្លួនប្រាណពុំទាន់បានរកឃើញក៏ដោយ ។ តាមនីតិវិធីតុលាការ ឌី អ៊ិន អេ ដែលមានគុណប្រយោជន៍នេះ អាចត្រូវបានរកឃើញលើភស្តុតាងដែលមានអាយុកាលរាប់ទស្សវត្សន៍ ។ ប៉ុន្តែ អាចមានកត្តាមួយចំនួនដែលអាចជះឥទ្ធិពលដល់ ឌី អ៊ិន អេ ដែលនៅកន្លែងកើតហេតុ ដែលរួមមានកត្តាបរិស្ថាន ឧទាហរណ៍ : កម្តៅ ពន្លឺព្រះអាទិត្យ សំណើម បាក់តេរី ជាដើម ។ ដូច្នេះមិនមែនភស្តុតាងទាំងអស់សុទ្ធតែអាចប្រើប្រាស់បាននោះទេ ។ ជាងនេះទៅទៀត ដូចជាស្នាមម្រាមដៃ ដែលការធ្វើតេសលើ ឌី អិន អេ មិនអាចប្រាប់មន្ត្រីថា នៅពេលណាដែលជនសង្ស័យ នៅកន្លែងកើតហេតុបាន ឬរយៈពេលប៉ុន្មាននោះទេ ។

ឌី អ៊ិន អេ អាចត្រូវបានរកឃើញលើខ្លួនមនុស្សដូចជា ក្នុងឈាម ទឹកកាម កោសិកាស្បែក ក្រដាសជូតមាត់ សរីរាង្គ សាច់ដុំ កោសិកាខួរក្បាល ធ្មេញ ឬសក់ ទឹកមាត់ សំបោរ និងទឹកនោមជាដើម ។ល។ ម្យ៉ាងវិញទៀត ភស្តុតាង ឌី អិន អេ ស្ទើរតែអាចប្រមូលបានពីគ្រប់ទីកន្លែង ដែលវាបានជួយដោះស្រាយករណីជាច្រើន នៅពេលដែលអ្នកស៊ើបអង្កេតបានប្រមូលភស្តុតាងពីប្រភពទំនើប ពោលគឺប្រភពវេជ្ជសាស្ត្រ ។

<u>**ឧទាហរណ៍**</u> :

-អំពើឃាតកម្ម អាចត្រូវបានកំណត់យ៉ាងច្បាស់ នឹងត្រូវបានដោះស្រាយ នៅពេលដែលជនសង្ស័យត្រូវបានយកពីទឹកមាត់នៅក្នុងពុម្ភធ្មេញ ដែលត្រូវគ្នានឹង ឌី អ៊ិន អេ ដែលបានយកពីស្នាមខាំជនរងរបស់ជនរងគ្រោះ ។

-ជនល្មើសត្រូវបានចោទប្រកាន់ពីការបង្ខំរួមភេទ នៅពេលដែល ឌី អ៊ិន អេ របស់ជនសង្ស័យត្រូវគ្នា នឹង ឌី អ៊ិន អេ ដែលប្រមូលបានពីប្រដាប់ភេទជនរងគ្រោះ៦ម៉ោងក្រោយពីកើតហេតុ ។

ករណីជាច្រើន ត្រូវបានដោះស្រាយដោយការវិភាគ ឌី អ៊ិន អេ ទឹកមាត់លើ ចាន បារី ដប និងកោសិកាស្បែកដែលបានពីដែកកេះអុចបារី ជាដើម ។ល។ កោសិកាតែពីរ បី ប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់ប្រមូលព័ត៌មាន ឌី អ៊ិន អេ ដ៏មានប្រយោជន៍ ដើម្បីជួយដោះស្រាយករណីក្នុងការស៊ើបអង្កេតទាំងឡាយ ។ បញ្ជីខាងក្រោម កំណត់នូវភស្តុតាងទូទៅមួយចំនួន ដែលគេអាចត្រូវការដើម្បីប្រមូលកន្លែងដែលអាចប្រមូល ឌី អ៊ិន អេ លើភស្តុតាង ប្រភពវេជ្ជសាស្ត្រដែលផ្ទុកកោសិកា ។[67]

**២. ការប្រមូល និងថែរក្សា ឌី អ៊ិន អេ** (DNA)

ជានិច្ចជាកាល អ្នកពិសោធន៍ រួមជាមួយមន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកអនុវត្តនូវបេសកកម្មទាំងនេះ ក្នុងការកំណត់ភស្តុតាង និងមានភាពងាយស្រួលក្នុងការឈានទៅដល់ការកំណត់អទិភាពនៃបទល្មើស ។ វិធីសាស្ត្រនៃការប្រមូលទាំងនោះរួមមាន :

-គេត្រូវពាក់ស្រោមដៃ និងម៉ាសបិទមុខ ប្រើសំឡីចាប់យកសំណាកឈាម ឬសំណាក ឌី អិន អេ ប្រភេទផ្សេងទៀត

-ប្រសិនបើស្នាមប្រឡាក់នោះស្ងួត គេត្រូវប្រើទឹកស្តេរីល បន្តិចពីលើស្នាមប្រឡាក់នោះដើម្បីផ្សើមវា និងដើម្បីឱ្យដានស្នាមប្រឡាក់នោះត្រឡប់មកវិញ

-នៅពេលដែលស្នាមប្រឡាក់បានស្ងួតនៅលើសំឡីជូត ត្រូវដាក់សំឡីជូតនោះចូលទៅក្នុងដបប្រអប់បិទជិតមួយ

---

[67] បញ្ជីកំណត់រកឌី អ៊ិន អេ មាននៅក្នុងឧបសម្ព័ន្ធ

-បន្ទាប់មក ត្រូវដាក់វត្ថុតាងដែលនៅក្នុងប្រអប់នោះទៅក្នុងថង់ផ្លាស្ទិចដាក់ភស្តុតាង

-ដើម្បីបិទមាត់ថង់ផ្លាស្ទិចសម្រាប់ដាក់ភស្តុតាង ត្រូវគូសតាមបណ្តោយផ្នែកខាងលើមាត់ថង់

-បិទមាត់ថង់ដាក់ភស្តុតាង ដោយបត់ថង់ផ្នែកខាងលើ ចំពីលើខាងក្រោមបន្ទាត់ដែលមានជាតិស្អិត

-ដោយសារស្លាកសញ្ញាសម្គាល់វត្ថុតាងត្រូវបានសរសេរជាភាសាអង់គ្លេស ត្រូវសរសេរបំពេញស្លាកសញ្ញាសម្គាល់វត្ថុតាងដែលមានជាតិស្អិតជាភាសាខ្មែរ ហើយបកបិទពីលើថង់ដាក់វត្ថុតាង ហើយចុងក្រោយប្រគល់វាឱ្យមន្ត្រីគ្រប់គ្រងវត្ថុតាង ។ ការរក្សាទុកបន្ទាប់ពីការរើបអូស រាល់វត្ថុតាងទាំងអស់ដែលមានសារធាតុ ឌី អ៊ិន អេ ត្រូវតែរក្សាទុកឱ្យបានត្រឹមត្រូវនៅក្នុងទូទឹកកកមួយ នៅពេលប្រគល់ទៅប៉ុស្តិ៍នគរបាល ។ ការប៉ះពាល់ដោយផ្ទាល់ទៅនឹងពន្លឺនិងអាកាសធាតុក្តៅ អាចនឹងធ្វើឱ្យខូចសារធាតុភស្តុតាងនោះ ដូច្នេះគេជៀសវាងការដាក់ភស្តុតាងប្រភេទនេះ នៅកន្លែងដែលមានអាកាសធាតុក្តៅ ដូចជានៅក្នុងបន្ទប់ ឬក្នុងរថយន្តដែលគ្មានម៉ាស៊ីនត្រជាក់ជាដើម ព្រោះវានឹងអាចស្ងួតដោយសារកំដៅ ។ ត្រូវរក្សាទុកវត្ថុតាងនោះនៅកន្លែងមួយដែលមានអាកាសធាតុត្រជាក់ស្ងួត ដែលជាមធ្យោបាយដ៏ល្អបំផុតក្នុងការរក្សាទុកភស្តុតាងបែបបនេះមុនបញ្ជូនវាទៅមន្ទីរពិសោធន៍ ។

❖ **ប្រការគួរយល់ដឹងដើម្បីជៀសវាងការធ្វើឱ្យខូចភស្តុតាង ឌី អិន អេ** :

-ពាក់ស្រោមដៃ និងប្តូរវាឱ្យបានញឹកញាប់

-ពាក់ម៉ាស់បិទមុខ

-ប្រើសម្ភារៈតែម្តងរួចបោះចោល ឬសម្អាតវាមុនពេល និងក្រោយពេលប៉ះពាល់សំណាកនីមួយៗ

-ជៀសវាងប៉ះពាល់កន្លែងដែលគិតថាមាន ឌី អិន អេ

-ជៀសវាងការនិយាយច្រើន កណ្តាស់ និងក្អកលើភស្តុតាង

-ជៀសវាងការប៉ះមុខ ច្រមុះ និងមាត់ខ្លួនឯង នៅពេលប្រមូល និងវេចខ្ចប់ភស្តុតាង

-សម្ងួតភស្តុតាងក្នុងខ្យល់មុនពេលវេចខ្ចប់

-ដឹកជញ្ជូន និងរក្សាទុកឱ្យបានត្រឹមត្រូវ ។

ប្រសិនបើស្នាមឈាមវាស្ងួតនៅលើសំលៀកបំពាក់ស្ងួត ត្រូវទុកវានៅក្នុងថង់ក្រដាសពណ៌ត្នោត និងដាក់សញ្ញានៅលើថង់នោះ ។

ប្រសិនបើវត្ថុតាងនោះគេឃើញ ជាដំណក់ទឹកកាមដែលមាននៅលើស្រោមអនាម័យ ដែលគេបានប្រើនៅពេលប្រព្រឹត្តបទល្មើស គេត្រូវដាក់វាទៅក្នុងដបស្តែរីលដាក់វត្ថុតាងមួយ ដែលអាចឱ្យខ្យល់ស្ងួត មុននឹងធ្វើការវេចខ្ចប់ដាក់ក្នុងថង់ផ្លាស្ទិក ។ ការធ្វើដូច្នេះ គឺវាអាចរក្សារូបរាងពិតប្រាកដរបស់វត្ថុតាងនោះ ហើយគេបិទគម្របដប បន្ទប់មកត្រូវយកបង់ស្អិត ឬស្កុតបិទរុំជុំវិញផ្ទៃគម្របដបទាំងមូល ដើម្បីធានាថា វានៅជាប់មិនរបូត ហើយវត្ថុធាតុរាវមិនអាចជ្រាប ឬហូរចេញបាន ។ ហើយធ្វើដូចមុនដែរ គឺដាក់ចូលទៅក្នុងថង់ផ្លាស្ទិកដាក់វត្ថុតាង និងសរសេរបំពេញជាភាសារខ្មែរលើស្លាកសញ្ញាសំគាល់វត្ថុតាង រួចហើយបិទវាភ្ជាប់ពីចំហៀងថង់ មុននិងប្រគល់ឱ្យមន្ត្រីគ្រប់គ្រងភស្តុតាង ។[68]

## កថាខណ្ឌ ៨ ការបិទកន្លែងកើតហេតុ[69]

ការបិទកន្លែងកើតហេតុត្រូវបានគេបែងចែកជា ពីរ គឺ ការបិទកន្លែងកើតហេតុជាស្ថាពរ និង ការបិតកន្លែងកើតហេតុជាបណ្តោះអាសន្ន ។

### ១. ការបិទកន្លែងកើតហេតុជាស្ថាពរ

ការបិទកន្លែងកើតហេតុជាស្ថាពរ គឺការបិទកន្លែងកើតហេតុដោយបញ្ចប់ការពិនិត្យកន្លែងកើតហេតុដែលគណៈកម្មការយល់ឃើញថា បានពិនិត្យ និងធ្វើត្រឹមត្រូវគ្រប់តាមបែបបទនីតិវិធីរួចហើយ ក៏ប៉ុន្តែ កន្លែងកើតហេតុនេះនៅតែមានសុពលភាពសម្រាប់ការស្រាវជ្រាវចំពោះមន្ត្រីនគរបាលយុត្តិធម៌ ។ ហើយការបិទកន្លែងកើតហេតុនេះ មិនចាំបាច់ដាក់កម្លាំងការពារឱ្យមានសន្តិសុខ សុវត្ថិភាពទៀតទេ ។

[68] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ ចាប់ពី ទំព័រ ១១៧ ដល់ ទំព័រ ១២៥

[69] សៀវភៅ **អត្ថាធិប្បាយច្បាប់ ភស្តុតាង ក្នុងរឿងក្តីព្រហ្មទណ្ឌ** រៀបរៀងដោយ **លោកចៅក្រម ហ៊ីង ធីឫទ្ធិ** (ភាគ ២) ទំព័រ ៩២

### ២. ការបិទកន្លែងកើតហេតុជាបណ្តោះអាសន្ន

ការបិតកន្លែងកើតហេតុជាបណ្តោះអាសន្ន គឺជាការបិទកន្លែងកើតហេតុមួយរយៈពេល ហើយក្នុងរយៈពេលនៃការបិទនេះ គណៈកម្មការពិនិត្យស្រាវជ្រាវកន្លែងកើតហេតុមានសិទ្ធិធ្វើ រហូតដល់ចប់ ។ នីតិវិធីនៃការបិទកន្លែងកើតហេតុជាក់ស្តែងដូចជា ការបិទផ្លុំបេ និងការដាក់កម្លាំងការពារជាដើម ។

#### ២.១ ការបិទផ្លុំបេ

ការបិទផ្លុំបេនៅកន្លែងកើតហេតុណាដែលកើតមានឡើងនៅក្នុងបន្ទប់ដូចជា នៅក្នុងការិយាល័យ ផ្ទះ ឃ្លាំង សណ្ឋាគារ ។ល។ ហើយសមាជិកគណៈកម្មការពិនិត្យកន្លែងកើតហេតុយល់ឃើញថា អាចបិទផ្លុំបេបាននៅលើទ្វារចេញចូល បង្អួច ជាដើម ។ នៅពេលបិទ សមាជិកគណៈកម្មការពិនិត្យកន្លែងកើតហេតុទាំងអស់ចាំបាច់ត្រូវចុះហត្ថលេខានៅលើផ្លុំបេ ។

#### ២.២ ការដាក់កម្លាំងការពារ

ការដាក់កម្លាំងការពារកន្លែងកើតហេតុឱ្យមានសន្តិសុខ សុវត្ថិភាពនៅកន្លែងកើតហេតុណាដែលគណៈកម្មការពិនិត្យកន្លែងកើតហេតុយល់ថា កន្លែងកើតហេតុនោះមានទីធ្លាធំទូលាយដូចជា ទីសាធារណៈ សួនច្បាររមណីដ្ឋាន ផ្លូវថ្នល់ កន្លែងរាំកំសាន្ត ពេលមានប្រារព្ធពីធីផ្សេងៗ ។ល។ កន្លែងកើតហេតុត្រូវបន្តការគ្រប់គ្រងរហូតដល់មន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រមកដល់ ។ បើមន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រពុំទាន់មកដល់ទេ ការត្រួតពិនិត្យកន្លែងកើតហេតុមិនអាចបញ្ចប់ជាផ្លូវការបាននោះទេ ។

### កថាខណ្ឌ ៩ ការគ្រប់គ្រងកំណត់ហេតុ

កំណត់ហេតុដែលបានដាក់ឱ្យពិនិត្យនៅកន្លែងកើតហេតុមានដូចជា[70] :

-កំណត់ហេតុពិនិត្យកន្លែងកើតហេតុ (កត់ត្រាអំពីសកម្មភាពបទល្មើស និងស្លាកស្នាមវត្ថុតាង)

-កំណត់ហេតុរូបថត (តារាងរូបថតកន្លែងកើតហេតុ)

-គំនូសប្លង់កន្លែងកើតហេតុ

-កំណត់ហេតុដកហូតវត្ថុតាង (រាល់វត្ថុតាងដែលជាប់ពាក់ព័ន្ធដល់សកម្មភាពល្មើស ឬវត្ថុសម្ភារៈដែលមានជាប់ស្លាកស្នាម ឬមធ្យោបាយប្រព្រឹត្តបទល្មើស)

[70] សៀវភៅ **អត្ថាធិប្បាយច្បាប់ ភស្តុតាង ក្នុងរឿងក្តីព្រហ្មទណ្ឌ** រៀបរៀងដោយ **លោកចៅក្រម ហ៊ីង ធីឬទ្ធិ** (ភាគ ២) ទំព័រ ៨៦

-កំណត់ហេតុសាកសួរបំភ្លឺ (ព័ត៌មានពីសាក្សីនៅជុំវិញកន្លែងកើតហេតុ មុនកើតហេតុក្រោយពេលកើតហេតុ និងភ្ជាប់ដោយសាលាកប័ត្រ ភិនភាគមុខសញ្ញា)

-កំណត់ហេតុប្រគល់ទទួល (កំណត់ហេតុធ្វើឡើងក្រោយពេលបញ្ចប់ពិនិត្យកន្លែងកើតហេតុ)

-របាយការណ៍បូកសរុប វាយតម្លៃករណីរឿងបម្រើឱ្យការស៊ើបអង្កេត (របាយការណ៍នេះ ធ្វើឡើងដោយប្រធានគ្រប់គ្រងកន្លែងកើតហេតុ ចូលរួមវាយតម្លៃសន្និដ្ឋានដោយសមាជិកគណៈកម្មការពិនិត្យស្រាវជ្រាវកន្លែងកើតហេតុ) ។

ក្រោយពេលប្រតិបត្តិការពិនិត្យកន្លែងកើតហេតុបានបញ្ចប់ បន្ទាប់មកគណៈកម្មការពិនិត្យកន្លែងកើតហេតុត្រូវបានកោះប្រជុំភ្លាមៗនៅកន្លែងកើតហេតុ ដើម្បីបូកសរុបវាយតម្លៃសន្និដ្ឋានជំហានដំបូង គឺ :

-ករណីរឿងហេតុកើតឡើងបណ្តាលមកពីរឿងអ្វីខ្លះ ?

-សកម្មភាពបទល្មើសធ្ងន់ធ្ងរ ឬស្រាល ហើយប៉ះពាល់អ្វីខ្លះ ?

-ជនល្មើសដែលចូលរួមសកម្មភាពប្រព្រឹត្តមានចំនួនប៉ុន្មាននាក់ ?

-វាយតម្លៃព័ត៌មានជុំវិញកន្លែងកើតហេតុសមស្របតាមរឿងហេតុដែលកើតឡើងដែរឬទេ ?

-សម្ភារៈ វត្ថុតាងដែលបានដកហូតនៅកន្លែងកើតហេតុមានអ្វីខ្លះ ? ត្រូវពិនិត្យ និងកត់ត្រាលម្អិតនៅក្នុងកំណត់ហេតុ

-ការឃាត់ខ្លួនជនសង្ស័យ និងចម្លើយរបស់ជននោះភ្លាមៗនៅកន្លែងកើតហេតុស៊ីសង្វាក់នឹងព័ត៌មានប្រមូលបាននៅកន្លែងកើតហេតុ (សាក្សី) និងភស្តុតាងទាំងឡាយដែលប្រមូលបានពីកន្លែងកើតហេតុដែរ ឬទេ ?

-វាយតម្លៃលើការបាត់បង់ និងខូចខាតដូចជា អាយុជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិ

-ត្រួតពិនិត្យមើលការងារទាំងអស់ឡើងវិញម្តងទៀតតើធ្វើបានត្រឹមត្រូវតាមនីតិវិធីដែរឬទេ ? តើអាចបញ្ចប់ការពិនិត្យកន្លែងកើតហេតុបានឬអត់ ?

## ផ្នែកទី ៣ បេសកកម្មក្នុងការស្វែងរកជនល្មើស

ពាក់ព័ន្ធនឹងផ្នែកចុងក្រោយនេះ យើងនឹងធ្វើការសិក្សាទៅលើ បេសកកម្មក្នុងការស្វែងរកជនល្មើសតាមវិធីសាស្ត្រផ្សេងៗ ដូចខាងក្រោម :

### កថាខណ្ឌ ១ ការស្វែងរកតាមរយៈការសម្ភាសន៍សាក្សី និងជនរងគ្រោះ

ការសម្ភាសន៍ គឺជាជំនាញស៊ើបអង្កេតមួយដែលមិនអាចមើលរំលងដោយមន្ត្រីនគរបាលយុត្តិធម៌នៅលើពិភពលោក ។ ករណីជាច្រើនមន្ត្រីស៊ើបអង្កេត ដែលមានកាតព្វកិច្ចលើករណីនោះពួកគាត់ត្រូវបានតម្រូវឱ្យទៅជួបជនរងគ្រោះ និងសាក្សីដើម្បីទទួលបានចម្លើយកាន់តែប្រសើរឡើងជាងអ្នកដែលនៅពេលប្រព្រឹត្តបទល្មើសកើតឡើង ។ ជាញឹកញាប់ការសម្ភាសន៍ គឺជាផ្នែកមួយនៅក្នុងការស៊ើបអង្កេត ។ បើទោះបីជាមានវត្ថុតាងមួយចំនួនអាចបង្ហាញផ្លូវដល់អ្នកស៊ើបអង្កេត តែក្នុងករណីជាច្រើនភស្តុតាងបែបនេះគឺពុំអាចរកបាននោះទេ ។ ដូច្នេះ មន្ត្រីនគរបាលត្រូវតែពឹងផ្អែកលើចម្លើយ ជនរងគ្រោះ និងសាក្សី ។

### កថាខណ្ឌ ២ ការស្វែងរកតាមរយៈការសួរចម្លើយជនសង្ស័យ

ការសួរចម្លើយ គឺជាការចោទសំណួរទៅលើជនសង្ស័យដែលថាបានប្រព្រឹត្តបទល្មើសណាមួយដែលខ្លួនស្ទាក់ស្ទើរ ឬមិនចង់សារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្ត ។ ឬម៉្យាងទៀត ជាការសន្ទនាដោយគ្រោងទុកមួយដើម្បីរាវរកការពិតស្តីពីបទល្មើស ឬហេតុការណ៍ពីជនសង្ស័យ ។

គោលបំណងនៃការសួរចម្លើយ គឺដើម្បីទទួលបានចម្លើយសារភាពរបស់ជនសង្ស័យ និងវែកមុខជនដែលពាក់ព័ន្ធក្នុងអំពើល្មើស ។ មន្ត្រីនគរបាលដែលជាអ្នកស៊ើបអង្កេតនោះ មិនត្រូវចេះតែទទួលយកចម្លើយសារភាពផ្តេសផ្តាសនោះទេ ចម្លើយសារភាពត្រូវតែលម្អិត គ្មានការផ្លាស់ប្តូរហើយស៊ីសង្វាក់ព្រមទាំងបំពេញបន្ថែមលើភស្តុតាង និងសច្ចាធារណ៍ដែលប្រមូលបានជាមុននៅពេលស៊ើបអង្កេត ។ ការដឹកនាំការសួរចម្លើយ ត្រូវទាមទារឱ្យគោរពនូវវិធានមួយចំនួនមិនត្រឹមតែក្នុងពេលប្រតិបត្តិការប៉ុណ្ណោះទេ ថែមទាំងមុនពេលប្រតិបត្តិការផងដែរ ។

### កថាខណ្ឌ ៣ ការស្វែងរកតាមរយៈការស្ទង់មតិតាមផ្ទះ

ការស្ទង់មតិតាមផ្ទះគឺវាមានតម្លៃ វាជាវិធីសាស្ត្រស៊ើបអង្កេតយ៉ាងសំខាន់ដែលនឹងមានប្រយោជន៍ម្តងហើយម្តងទៀត ដែលជាដំណើរស៊ើបអង្កេតចេញពីផ្ទះមួយទៅផ្ទះមួយ ដែលនៅក្បែរទីកន្លែងកើត

ហេតុ ដើម្បីស្វែងរកសាក្សី ។ ដែលជួនកាលសាក្សីមានការស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មដោយស្ម័គ្រចិត្ត ហើយបើមិនធ្វើដូចនេះមន្ត្រីនគរបាលនឹងមិនទទួលបានភស្តុតាងទាំងនោះទេ បើគាត់មិនស្វែងរកទេនោះ ។[71]

## កថាខណ្ឌ ២ ការការពារសាក្សី

សាក្សី គឺជាបុគ្គលដ៏សំខាន់មួយ ក្នុងការធ្វើឱ្យការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវលទ្ធផលយ៉ាងឆាប់រហ័សនិងមានប្រសិទ្ធភាព ។ ដូចនេះ មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចផងដែរលើការការពារសាក្សី ។ យើងនឹងធ្វើការសិក្សាពីមូលហេតុនៃការការពារ និងវិធានការការពារនៅចំណុចខាងក្រោម :

### ១. មូលហេតុនៃការការពារសាក្សី

មន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្ម មួយទៀត គឺការពារសាក្សីនៃបទឧក្រិដ្ឋ ។ ហេតុអ្វីបានជាគេចាំបាច់ត្រូវការពារសាក្សី ? មានមូលហេតុជាច្រើនដែរគេចាំបាច់ត្រូវការពារសាក្សី ៖

**-ដើម្បីការពារអាយុជីវិត និងសុខមាលភាពរបស់សាក្សីផ្ទាល់** : សាក្សីអាចជាគោលដៅរបស់ឧក្រិដ្ឋជន ។ បុគ្គលទាំងឡាយដែលជិតស្និទ្ធជាមួយសាក្សីក្នុងបទឧក្រិដ្ឋ ក៏អាចប្រឈមនឹងហានិភ័យផងដែររាប់ទាំងសមាជិកគ្រួសារ មិត្តភ័ក្ត និងសហការីរបស់គាត់ជាដើម ។

**-ដើម្បីជំនួយដល់ការស៊ើបអង្កេត** : នៅក្នុងកំឡុងពេលស៊ើបអង្កេត សាក្សីពិតជាមានសារសំខាន់ណាស់ក្នុងការប្រមូលភស្តុតាងទាក់ទងនឹងបទឧក្រិដ្ឋមួយ និងបុគ្គលទាំងឡាយដែលទទួលខុសត្រូវក្នុងបទឧក្រិដ្ឋនេះ ។ សាក្សីអាចផ្តល់ជាតម្រុយ ដែលអាចជួយដល់ការស៊ើបអង្កេត និងការផ្តន្ទាទោសបទឧក្រិដ្ឋជនណាម្នាក់ ឬមួយក្រុមជាយថាហេតុ ។ ជួនកាលសក្ខីកម្មរបស់សាក្សី គឺជាភស្តុតាងដ៏សំខាន់បំផុតផងដែរ ក្នុងការប្រឆាំងតទល់នឹងចុងចោទក្នុងពេឡសវនាការ ។

**-ដើម្បីរក្សាសេចក្តីសុចរិតនៃការជំនុំជម្រះក្តី** : ប្រសិនបើជាចុងចោទ និងឧក្រិដ្ឋជនផ្សេងទៀត ត្រូវបានគេអនុញ្ញាតឱ្យធ្វើការបំភិតបំភ័យ ឬធ្វើទុក្ខបុកម្នេញដល់សាក្សី ដូច្នេះសេចក្តីសុចរិតនៃការជំនុំជម្រះក្តីនឹងត្រូវអន្តរាយជាក់ជាមិនខានឡើយ ។ សំណុំរឿងទាំងមូលរបស់ព្រះរាជអាជ្ញា អាចនឹងទទួល

[71] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ គ្រង់ ទំព័រ ៧៩

រងឥទ្ធិពលណាមួយ ប្រសិនបើសាក្សីសំខាន់ៗរបស់គាត់មិនអាចផ្តល់សក្ខីកម្មដូចដែលបានគ្រោងទុកនោះទេ ។ ជួនកាល ករណីខ្លះ អាចនឹងត្រូវបានលើកលែងការចោទប្រកាន់ ដោយគ្រាន់តែមានការបំភិតបំភ័យសាក្សី ។

**-ដើម្បីទប់ស្កាត់បទឧក្រិដ្ឋមិនឱ្យមានកើតតទៅទៀត** ៖ សាក្សីជួយដោយផ្ទាល់ ឬដោយប្រយោលក្នុងការនាំខ្លួនឧក្រិដ្ឋជនមកតុលាការដើម្បីកាត់ទោសទៅតាមច្បាប់ ដើម្បីបង្ការទប់ស្កាត់បទឧក្រិដ្ឋមិនឱ្យកើតមាននៅថ្ងៃអនាគត ។ ម៉្យាងវិញទៀត ការអនុញ្ញាតឱ្យឧក្រិដ្ឋជនណាម្នាក់បំភិតបំភ័យ ឬធ្វើទុកបុកម្នេញដល់សាក្សីណាមួយ អាចជាការរួមចំណែកបង្កបរិយាកាសភ័យខ្លាច និងការមិនគោរពច្បាប់ ។[72]

**២. វិធានការណ៍ក្នុងការពារសាក្សី**

ជារឿយៗ មន្ត្រីនគរបាល តែងតែគាំទ្រផ្លូវចិត្ត ផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្តល់ជាយោបល់ ដល់សាក្សី ពោលគឺគាំទ្រផ្នែកសុខមាលភាព ។ ដែលគេត្រូវធ្វើយ៉ាងណាមិនឱ្យពួកគេមានអារម្មណ៍ថាខ្លួនគេឯកោ អសន្តិសុខនោះទេ ដូចជា មិនត្រូវឱ្យពួកគាត់រស់នៅឆ្ងាយដាច់ពីគេ ហើយត្រូវតែមកមើលគាត់ញឹកញាប់ ។ ក្នុងករណីដែលមានការព្រួយបារម្ភខ្លាំង ពីហានីភ័យដែលអាចកើតមានខ្ពស់ ត្រូវរកកន្លែងមួយសម្រាប់ពួកគាត់ស្នាក់នៅ ឬចាត់មន្ត្រីនគរបាលមួយចំនួនតាមការពារដោយសម្ងាត់ដើម្បីធានានូវសន្តិសុខរបស់ពួកគាត់ ។ មានពេលខ្លះសាក្សីខ្លួនឯងផ្ទាល់ក៏អាចជាឧក្រិដ្ឋជនផងដែរ ដែលអាចជាគូកនចាស់របស់ចុងចោទក៏មាន ។ ក្នុងករណីនេះ សាក្សីដែលជាប់ពន្ធនាគារនោះអាចប្រឈមមុខនឹងការគម្រាមកំហែងពីបុគ្គលដែលជាប់ក្នុងបន្ទប់ឃុំឃាំងជាមួយគ្នានោះក៏អាចថាបាន ដូចនេះគេត្រូវដាក់ពួកគេឱ្យនៅដាច់ដោយឡែកពីគ្នា ៕

## ចប់ជំពូកទី ៣

[72] សៀវភៅ **មគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកកម្មនៅកម្ពុជា ឆ្នាំ ២០១២ គ្រង់ ទំព័រ ១៩៣ ដល់ ទំព័រ ១៩៤

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវ និងវែកញែកស្វែងយល់ យ៉ាងលម្អិតទៅលើប្រធានបទទាំងមូល ដែលនិយាយអំពី "**បេសកកម្មរបស់នគរបាលយុត្តិធម៌**" រួមមក យើងឃើញថា នគរបាលយុត្តិធម៌ គឺមានមានសមាសភាព ដូចជា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដ៏ទៃទៀត ដែលច្បាប់ដោយឡែកប្រគល់សិទ្ធិអំណាចក្នុងការពិនិត្យបទល្មើសមួយចំនួន ។ ពួកគាត់ទាំងអស់នេះ គឺជានគរបាលយុត្តិធម៌ដែលជាជំនួយការយ៉ាងសំខាន់របស់ស្ថាប័នតុលាការ ហើយបំពេញបេសកកម្មកម្មរបស់ខ្លួនក្នុងគោលបំណងបង្ក្រាបបទល្មើស ធានាការអនុវត្តច្បាប់ និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ។ ប៉ុន្តែប្រភេទនៃការអនុវត្តនូវភារកិច្ច និងតួនាទីរបស់ពួកគាត់មានភាពខុសប្លែកពីគ្នា ។ មន្ត្រីនគរបាលយុត្តិធម៌ អនុវត្តនូវបេសកកម្មរបស់ខ្លួនក្រោមការដឹកនាំ និងសម្របសម្រួលពីព្រះរាជអាជ្ញា ពោលគឺគាត់មានទំនាក់ទំនងយ៉ាងខ្លាំងជាមួយព្រះរាជអាជ្ញា ។ រីឯភ្នាក់ងារនគរបាលយុត្តិធម៌វិញ គាត់គឺជាជំនួយការរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលគាត់មានតួនាទីរាយការណ៍នូវព័ត៌មានទាំងឡាយដែលគាត់បានដឹងឮ ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ហើយបន្តរាយការទៅកាន់ព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌នោះ ដើម្បីធានានូវប្រសិទ្ធិនៃកិច្ចនីតិវិធី ពោលគឺទាល់តែព្រះរាជអាជ្ញាអនុញ្ញាតដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទើបមន្ត្រីនគរបាលយុត្តិធម៌អាចអនុវត្តនូវបេសកកម្មរបស់ខ្លួនបាន ។

អ្វីដែលសំខាន់យើងឃើញថា បេសកកម្មដ៏ធំបំផុតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺស្ថិតនៅដំណាក់កាលស៊ើបអង្កេត ដែលគាត់មានអំណាចដ៏ធំធេងក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង ពោលគឺនៅពេលដែលគាត់បានដឹងពីការកើតឡើងនៃបទល្មើស ហើយគាត់អាចកំណត់ថាជាបទល្មើសជាក់ស្តែង នោះគាត់នឹងធ្វើការស៊ើបអង្កេតភ្លាមៗដោយគ្រាន់តែសុំការអនុញ្ញាតដោយផ្ទាល់មាត់ ពីព្រះរាជអាជ្ញាក៏បានដែរ ។ អំណាចនៃការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែងនេះ គឺមន្ត្រីនគរបាលយុត្តិធម៌អាចឈានរហូតដល់ការចាប់ខ្លួនជនសង្ស័យដោយមិនចាំបាច់មានការអនុញ្ញាត ឬមានដីកាពីតុលាការនោះទេ ។ ប៉ុន្តែ ប្រសិនបើវាជាការស៊ើបអង្កេតបទល្មើសមិនជាក់ស្តែង ឬការស៊ើបអង្កេតបឋមវិញ គឺអំណាចរបស់គាត់មិនមានភាពធំធេងនោះទេ មានន័យថារាល់ការធ្វើអ្វីមួយចាំបាច់ត្រូវតែមានដីកាពីតុលាការ ដូចជា ការឃាត់ខ្លួន ការឆែកឆេរជាដើម ដែលតម្រូវចាំបាច់ត្រូវតែមានដីកាទើបអាចអនុវត្តការងារនោះបាន ។

ដំណាក់កាលបន្ទាប់មួយទៀតដែលនគរបាលយុត្តិធម៌មានបេសកកម្ម គឺក្នុងដំណាក់កាលនៃស៊ើបសួរ ។ គាត់ទទួលបានអំណាច នៅពេលដែលមានដីកាចាត់ឱ្យស៊ើបសួរជំនួសដែលចេញដោយចៅក្រមស៊ើបសួរ ឬយុត្តាធិការស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញបេសកកម្មក្រោមការបញ្ជា និងអំណាចរបស់ចៅក្រមស៊ើបសួរ ។ គាត់ទទួលបានទាំងអំណាចមួយចំនួនដូចជា អំណាចក្នុងការកោះហៅនិងស្តាប់ចម្លើយសាក្សី អំណាចក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង ព្រមទាំងអំណាចក្នុងការឃាត់ខ្លួនជាដើម ។ ម្យ៉ាងវិញទៀត គាត់មានកាតព្វកិច្ចដូចជា អនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន និង ដីកាបង្គាប់ឱ្យចាប់ខ្លួនជាដើម ដែលចេញដោយយុត្តាធិការស៊ើបសួរ ពោលគឺបញ្ជូនដីកាទាំងនោះទៅកាន់បុគ្គលដែលមានកំណត់ក្នុងដីការនោះ។

ទទឹមនឹងនេះ នគរបាលយុត្តិធម៌ក៏មានបេសកកម្មផងដែរ នៅក្នុងដំណាក់កាលនៃសាលាជំនុំជម្រះក្តីទាំង ៣ (បី) ដែលមានសាលាដំបូងរាជធានី-ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ បេសកកម្មក្នុងការប្រគល់ដីកាកោះហៅទៅជំនុំជម្រះផ្ទាល់ ការអមជនជាប់ចោទនៅក្នុងនីតិវិធីចូលបង្ហាញខ្លួនភ្លាម ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួមភ្លាម បេសកកម្មក្នុងការធានាសណ្តាប់ធ្នាប់នៃសវនាការ ជាអាទិ៍ ដែលសុទ្ធតែអាចជាកិច្ចការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ឬអាចជាភ្នាក់ងារនគរបាលយុត្តិធម៌ ។ ម្យ៉ាងវិញទៀត នៅក្នុងដំណាក់កាលនៃនីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក នគរបាលយុត្តិធម៌ក៏មាននូវបេសកកម្មមួយចំនួន ដែលមានដូចជា ការធានារ៉ាប់រងនូវការអនុវត្តទោស ការស្នើសុំពិនិត្យជនជាប់ឃុំឃាំង ការស្នើសុំឱ្យបង្ហាញខ្លួនជនជាប់ចោទ និងការរក្សាទុកនូវលិខិតនៃកិច្ចនីតិវិធីជាដើម ។

រីឯ បេសកកម្មរបស់នគរបាលយុត្តិធម៌ដែលត្រូវបានលើកឡើងចុងក្រោយគឺ ទាក់ទងទៅនឹងនៅកន្លែងកើតហេតុ ដែលយើងឃើញថា នគរបាលយុត្តិធម៌មានបេសកកម្មក្នុងការធ្វើដំណើរទៅកាន់កន្លែងកើតហេតុផ្ទាល់ដើម្បីប្រមូលវត្ថុតាងនៅកន្លែងកើតហេតុ ព្រមទាំងបេសកកម្មក្នុងការរៃកមុខជនល្មើស តាមរយៈការសម្ភាសបុគ្គលទាំងឡាយដែលពាក់ព័ន្ធ ឬបានដឹងឮពីការកើតឡើងនៃបទល្មើសណាមួយ ដែលមានដូចជាសាក្សី ជនរងគ្រោះ និងជនសង្ស័យជាដើម ។ ម្យ៉ាងវិញទៀត ភារកិច្ចបន្ទាប់បន្សំមួយទៀតដែលគាត់អាចបំពេញផងដែរ គឺការការពារសាក្សី ដែលគាត់ត្រូវធានាថាសាក្សីនៃបទឧក្រិដ្ឋ ត្រូវតែបានការពារយ៉ាងយកចិត្តទុកដាក់នៅពេលដែលមាន ការភ័យខ្លាចពីសុវត្ថិភាពរបស់

ពួកគាត់ទាំងនោះ ព្រោះតែការដែលគាត់បានដឹង ឮ ឃើញ ឬបានផ្តល់សក្ខីកម្មដល់មន្ត្រីនគរបាលយុត្តិធម៌ ជាដើម ។

ទាំងអស់នេះ វាបានសរបញ្ជាក់ឱ្យកាន់តែច្បាស់អំពីស្ថាប័ននគរបាលយុត្តិធម៌ ដែលដើរតួនាទីយ៉ាងសំខាន់មិនអាចខ្វះបាន នៅក្នុងដំណើរនៃរឿងក្តីព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថាប័ននេះ មានបេសកកម្មស្ទើរតែគ្រប់ដំណាក់កាលនៃកិច្ចនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ។

សរុបសេចក្តីមក យើងអាចកំណត់បានពីលក្ខណៈមូលសព្វគ្រប់លើបេសកកម្មរបស់នគរបាលយុត្តិធម៌ទាំងឡាយដែលបានបកស្រាយ គឺវាពិតជាមានអត្តន័យ ដែលបេសកកម្មនីមួយៗរបស់ពួកគាត់ពិតជាបានចូលរួមយ៉ាងសកម្ម ក្នុងការការពាររក្សាសណ្តាប់ធ្នាប់សាធារណៈ ធានាការប្រព្រឹត្តទៅនៃដំណើរការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋឱ្យមានភាពស្មើរគ្នា ធានារកយុត្តិធម៌ជូនប្រជាពលរដ្ឋ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ដែលជាច្បាប់កំពូលរបស់រដ្ឋ ព្រមទាំងចូលរួមយ៉ាងច្បាស់ក្នុងការពង្រឹកនូវនីតិរដ្ឋ ។ បេសកកម្មរបស់នគរបាលយុត្តិធម៌ គឺពិតជាមានតម្លៃសម្រាប់ជាតិមាតុភូមិដែលមិនអាចកាត់ថ្លៃបាន គួរជាទីចងចាំ ជាទីស្រលាញ់រាប់អាន គោរពកោតសរសើរ និងជាទីស្ញប់ស្ញែងបំផុត នៃប្រជាពលរដ្ឋគ្រប់ៗរូប ។

**ចប់មេរៀន**

# អនុសាសន៍

ជាចុងក្រោយបំផុត ក្នុងគោលបំណង និងឆន្ទៈ ដើម្បីធ្វើឱ្យស្នាដៃមួយនេះ អាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវ សមស្របទៅនឹងស្ថានភាពនឹងកាលៈទេសៈជាក់ស្តែង ដើម្បីចែករំលែកនូវគំណិតខ្លះៗ ខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោម :

❖ **ចំពោះរដ្ឋ :**

-សូមយកចិត្តទុកដាក់ខ្ពស់ ពីសុវត្ថិភាពរបស់នគរបាលយុត្តិធម៌ ក្នុងពេលដែលពួកគាត់ចុះបំពេញបេសកកម្មក្នុងការបង្ក្រាបបទល្មើសនានា ធ្វើយ៉ាងណាឱ្យពួកគាត់ទទួលបាននូវសម្ភារៈសម្រាប់ការពារខ្លួនយ៉ាងគ្រប់គ្រាន់ ដើម្បីបង្ការពីការតបតពីសំណាក់ជនល្មើសជាយថាហេតុ ។

-សូមធ្វើការយកចិត្តទុកដាក់ឱ្យបានជាអតិប្បរមា ទៅដល់នគរបាលយុត្តិធម៌មួយចំនួនដែលបានពលីទាំងកំលាំងកាយចិត្ត ជូនជាតិមាតុភូមិ ហើយរងគ្រោះដោយហេតុពីការបំពេញបេសកកម្មរបស់ខ្លួននាំឱ្យពិការភាពជាដើម ដែលមិនអាចបំពេញភារកិច្ចតទៅទៀតបាន ។ ធ្វើយ៉ាងណាធានា ថាពួកគាត់ទទួលបាននូវការជួយសង្គ្រោះ និងឧបត្ថមពីរដ្ឋដ៏សមរម្យ ដើម្បីឱ្យពួកគាត់បន្តជីវិតរស់នៅតទៅទៀត ។

-ធានាដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូប ឱ្យទទួលបាននូវភាពស្មើគ្នាចំពោះមុខច្បាប់ ជាពិសេស ទទួលបាននូវយុត្តិធម៌យ៉ាងសមរម្យនៅពេលដែលគាត់ទទួលរងព្យសនកម្មពី អំពើល្មើសណាមួយ ។

❖ **ចំពោះនគរបាលយុត្តិធម៌ :**

-សូមឱ្យនគរបាលយុត្តិធម៌គ្រប់រូប បំពេញនូវបេសកកម្មរបស់ខ្លួនដោយភាពប្រុងប្រយ័ត្នខ្ពស់ និងត្រឹមត្រូវទៅតាមនីតិវិធីដែលបានចែង ជាពិសេសនៅពេលដែលមានបទល្មើសមួយបានកើតឡើង ត្រូវកំណត់ឱ្យបានច្បាស់ថាជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ដើម្បីកុំឱ្យមានផលវិបាកនៅពេលក្រោយគឺ បើគាត់កំណត់ខុស នោះកិច្ចការរបស់គាត់ និងការខិតខំប្រឹងប្រែងរបស់គាត់ទាំងឡាយដែលបានធ្វើនឹងអាចជាកម្មវត្ថុនៃការស្នើរសុំមោឃភាព មានន័យថា ត្រូវចាត់ទុកជាអសារបង់ ។

-សូមឱ្យនគរបាលយុត្តិធម៌ទាំងអស់ ព្យាយាមរក្សាទុកនូវលេខទូរស័ព្ទរបស់ព្រះរាជអាជ្ញាដែលជាអ្នកដឹកនាំសម្របសម្រួលការងាររបស់ខ្លួន ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទាក់ទងគ្នានៅពេលដែលមានបទល្មើសជាក់ស្តែងកើតឡើង ។ ហើយនគរបាលយុត្តិធម៌ គួរតែផ្សព្វផ្សាយនូវលេខទូរស័ព្ទរបស់ខ្លួន ដល់ប្រជាពលរដ្ឋដែលស្ថិតនៅមូលដ្ឋានរបស់ខ្លួន ដើម្បីបង្កលក្ខណៈដល់ពួកគាត់ងាយស្រួលក្នុងការទាក់ទង នៅពេលដែលពួកគាត់ជួបប្រទះបទល្មើសណាមួយដែលបានកើតឡើងជាយថាហេតុ ។

-សូមឱ្យមន្ត្រីនគរបាលយុត្តិធម៌គ្រប់រូប នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរកើតឡើងហើយមានបណ្តឹងពីជនរងគ្រោះ មិនត្រូវធ្វើការសម្របសម្រួល ឬតម្កល់រឿងទុកឥតចាត់ការនោះទេ ព្រោះថានេះ គឺជាការហាមឃាត់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយមន្ត្រីនគរបាលយុត្តិធម៌រូបនោះអាចនឹងទទួលនូវទណ្ឌកម្មខាងវិន័យពីសំណាក់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬក្រសួងយុត្តិធម៌ ឬពេលខ្លះអាចបាត់បង់ការងារ ឬទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌអំពីកំហុសដែលខ្លួនបានប្រព្រឹត្តនោះផងដែរ ។ ម៉្យាងវិញទៀត វាអាចជះឥទ្ធិពលអាក្រក់ដល់ស្ថាប័នអនុវត្តច្បាប់ដ៏ទៃទៀតពោលគឺប្រជាពលរដ្ឋដែលជនជនរងគ្រោះនឹងអស់ជំនឿលើពួកគាត់ រួមទាំងស្ថាប័នយុត្តាធិការផងដែរពីព្រោះតែការមិនស្វែងរកយុត្តិធម៌ជូនពួកគាត់ ដោយការមិនចាត់ការលើបណ្តឹងរបស់ពួកគាត់ដែលបានប្តឹងមកនោះ ។ ការតម្កល់រឿងទុកឥតចាត់ការ គឺមានតែព្រះរាជអាជ្ញាប៉ុណ្ណោះ ដែលជាអ្នកមានសិទ្ធិអំណាចស្របច្បាប់ក្នុងការសម្រេច ។

❖ **ចំពោះប្រជាពលរដ្ឋ :**

-សូមឱ្យប្រជាពលរដ្ឋធ្វើការសហការគ្នាជាមួយនគរបាលយុត្តិធម៌ នៅពេលដែលឃើញមានបទល្មើសព្រហ្មទណ្ឌកើតឡើង ចូរប្រញាប់រាយការណ៍ភ្លាមទៅនគរបាលយុត្តិធម៌ ឬមន្ត្រីទាំងឡាយដែលមានសមត្ថកិច្ច ដែលនៅជិតទីនោះបំផុត ដើម្បីឱ្យពួកគាត់ចុះទៅធ្វើការស៊ើបអង្កេត និងបំបែកសំនុំរឿងបានយ៉ាងរហ័ស និងមានប្រសិទ្ធភាព ។

-សូមឱ្យប្រជាពលរដ្ឋគ្រប់រូប រួមគ្នាក្នុងការអនុវត្តច្បាប់ទាំងឡាយរបស់រដ្ឋដែលមានចែង ព្រមទាំងជៀសឱ្យឆ្ងាយពីការប្រព្រឹត្តបទល្មើស ពីព្រោះបទល្មើសគឺវាជះឥទ្ធិពលដ៏អាក្រក់ដល់ខ្លួនឯង គ្រួសារ និងសង្គមជាតិយ៉ាងខ្លាំង ។ ការចូលរួមក្នុងការអនុវត្តច្បាប់ គឺវាបានចូលរួមចំណែក ក្នុងការធ្វើឱ្យសង្គមជាតិ មានភាពសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងមនុស្សរស់នៅក្នុងសង្គម

ប្រកបដោយភាពសុខដុមរមនា ។ ម្យ៉ាងវិញទៀត សូមប្រជាពលរដ្ឋគ្រប់រូប ព្យាយាមសិក្សាស្វែងយល់ឱ្យបានជាអតិប្បរមាពាក់ព័ន្ធនឹងវិស័យច្បាប់ព្រហ្មទណ្ឌ ពីព្រោះថាវាមានការទាក់ទងទៅនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សរាល់គ្នា ដែលចំណេះដឹងផ្នែកនេះ អាចបង្ការការពារខ្លួនឯងផ្ទាល់ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយកំរិតផងដែរ ពីព្រោះតែការដឹងអំពីផលវិបាកទាំងឡាយក្រោយពីបាន ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនេះ ៕

# ឯកសារយោង


-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

-ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

-ក្រមព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ២០០៩

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ" ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៨

-ច្បាប់ស្តីពីគយ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧

-ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារអនីតិជន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

-ច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២

-ប្រកាសអន្តរក្រសួងស្តីពី "ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌" រវាងក្រសួងយុត្តិធម៌ និងក្រសួងរុក្ខាប្រមាញ់ និងនេសាទ លេខ ៥៦ ប្រ.ក.ក.យ.ក.ស/០៨ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៨

-ប្រកាសស្តីពីរបៀបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ របស់ក្រសួងយុត្តិធម៌លេខ ២៧ ប្រ.ក .រ.ប.ក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៤

-រូបមន្តនីតិវិធីអនុវត្ត សម្រាប់នគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថ ឆ្នាំ ២០០៩ រវាងក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌

-សៀវភៅ "នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលយុត្តិធម៌" (អំណោយស្ថានទូតបារាំង ឆ្នាំ ២០០៩)

-សៀវភៅមគ្គុទេសក៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី "បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌" ចងក្រងដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ ហៅកាត់ថា អាយ.អូ.អឹម (IOM) បោះពុម្ពឆ្នាំ ២០១២

-សៀវភៅអត្ថាធិប្បាយច្បាប់ "ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ" រៀបរៀងដោយ លោកចៅក្រម ហ៊ីង ធីឬទ្ធិ (ភាគ ២) បោះពុម្ពលើកទី ១ ឆ្នាំ ២០០៨

-សៀវភៅ "នគរបាលយុត្តិធម៌" រៀបរៀងដោយ លោកសាស្ត្រាចារ្យ កៅសីហា បោះពុម្ពផ្សាយឆ្នាំ ២០០៩ (រោងពុម្ព អង្គរ)

-សៀវភៅ "នីតិព្រហ្មទណ្ឌទូទៅ" រៀបរៀងដោយសាស្ត្រាចារ្យ រុណ ពណ្ណារិទ្ធ កែសម្រួលដោយ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត បោះពុម្ពឆ្នាំ ២០១២

-សៀវភៅ "នីតិវិធីព្រហ្មទណ្ឌ" រៀបរៀងដោយសាស្ត្រាចារ្យ រុណ ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត បោះពុម្ពឆ្នាំ ២០១៥

-កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ក្រោមកិច្ចប្រតិបត្តិការណ៍រវាងក្រសួងយុត្តិធម៌ និងក្រសួងព័ត៌មាន

-គម្រូ "សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌"

-គម្រូ "វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាស្តីពីមន្ត្រីប៉ូលីសនគរបាល"

-វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

-សទ្ទានុក្រមពាក្យច្បាប់ ៕

# ឧបសម្ព័ន្ធ


THE GREENHOUSE...
'CRIME
SCENE'
W N S E
brown corduroy jacket
dirt
note
red pen
large shotgun case
counter
sink
locked west doors
root beer can
blood
cigarette butts
shotgun
ejection port (to be South)
bag
cigar box w/ narcotics
sunglasses, hat, $120,
cigarettes, lighter
2 towels, wallet
Presented at:
SShep.com

<u>**បច្ចេកទេសក្នុងការប្រមូលវត្ថុតាងជា ស្នាមស្បែកជើង**</u>

**-ត្រូវថតរូបស្នាមនោះឱ្យបានច្បាស់ ហើយដាក់បន្ទាត់នៅពីចំហៀង និងខាងខ្នងនៃស្នាមនោះ ដើម្បីវាស់ទំហំរបស់វា ហើយពិនិត្យទៅលើស្នាមនោះយ៉ាងលម្អិតដើម្បីកំណត់តិនភាគ រូបរាង និងធ្វើការប្រៀបធៀបឱ្យកាន់តែច្បាស់**



# <u>បច្ចេកទេសក្នុងការប្រមូលវត្ថុតាងជា ស្លាមក្រយៅដៃ</u>

❖ វិធីកែប្រែស្លាមក្រយៅដៅដែលមើលមិនឃើញ ៖

-ដំបូងគេយកច្រាសជ្រលក់ស្រាលៗចូលទៅក្នុងម្សៅ រួចយកម្រៀមដៃគោះជម្រុះម្សៅដែលជាប់ច្រាសនោះ ទុកតែម្សៅតិចតួចប៉ុណ្ណោះនៅលើច្រាសនោះ

-យកច្រាសមកបបោសថើៗលើកន្លែងស្លាមនោះជារាងខ្សែកោង

-កម្ទេសម្សៅនឹងជាប់លើកន្លែងដែលមានប្រេង ឬធូលី នោះវានឹងលេចចេញស្លាមក្រយៅដៃ

-ប្រើបន្ទះស្អិតបិទយក ស្លាមក្រយៅដៃនោះ

-យកទៅបិទលើក្រដាស ស មួយសន្លឹកដែលធ្វើការកែច្នៃ បន្ថែមទៀត



❖ វិធីយកស្នាមក្រយៅដៃដែលមើលមិនឃើញ ៖

-គេយកបន្ទះកញ្ចក់ ដាក់លើស្នាមក្រយៅដៃ រួចសង្កត់ឱ្យស្មើដៃ ហើយលើកចេញពេលវាជាប់ស្នាមព្រាលៗពីលើ




-ពេលខ្លះគេអាចប្រើរ៉ូឡូតូច ដើម្បីកិនឱ្យមត់រលោង កុំឱ្យមានពពុះ



-គេគួសចំណាំសញ្ញាសំគាល់ អំពីវត្ថុតាងនោះ នៅខាងខ្នង នៃប័ណ្ណជាមួយនឹងវត្ថុតាងនោះ



## វត្ថុតាង

ទីភ្នាក់ងារ: ..........................................................................

លេខវត្ថុតាង: ..........................ករណីលេខ: ..........................

ប្រភេទបទល្មើស: ..........................................................................

ជនសង្ស័យ: ..........................................................................

ជនរងគ្រោះ: ..........................................................................

កាលបរិច្ឆេទប្រមូល..................ពេលវេលាប្រមូល....................

ពណ៌នាវត្ថុតាង: ..........................................................................

..........................................................................................

..........................................................................................

ទីកន្លែងប្រមូល: ..........................................................................

ប្រមូលដោយ: ..........................................................................

ហត្ថលេខា: ..........................................................................

## ដំណើររក្សាវត្ថុតាង

ឈ្មោះអ្នករក្សាទី១: ..........................................................................

កាលបរិច្ឆេទ: ..........................................................................

ហត្ថលេខា: ..........................................................................

...............................

ឈ្មោះអ្នករក្សាទី២: ..........................................................................

កាលបរិច្ឆេទ: ..........................................................................

ហត្ថលេខា: ..........................................................................

...............................

ឈ្មោះអ្នករក្សាទី៣: ..........................................................................

កាលបរិច្ឆេទ: ..........................................................................

ហត្ថលេខា: ..........................................................................

...............................

## EVIDENCE

Agency: ..........................................................................

Item No: ......................Case No: ..........................................

Type of Offence: ..........................................................................

Suspect: ..........................................................................

Victim: ..........................................................................

Date of Collection....................Time of Collection...............

Description of Evidence: ..........................................................

..........................................................................................

..........................................................................................

Location of Collection: ..........................................................

..........................................................................................

Collected by ..........................................................................

Signature: ..........................................................................

## CHAIN OF CUSTODY

1st Receiving Officer: ..........................................................

Date: ..........................................................................

Signature: ..........................................................................

.................................

2nd Receiving Officer: ..........................................................

Date: ..........................................................................

Signature: ..........................................................................

.................................

3rd Receiving Officer: ..........................................................

Date: ..........................................................................

Signature: ..........................................................................

.................................

# បច្ចេកទេសក្នុងការប្រមូលវត្ថុតាង ជាសម្លៀកបំពាក់

-ដាក់លេខសំគាល់ ហើយថតរូប




-ចាប់យក ដោយប្រើដង្កៀប ដាក់ចូលក្នុងថង់ក្រដាសដាក់វត្ថុតាង



-បត់ជ្រុងទាំងពីរផ្នែកខាងលើនៃថង់ ក្នុងមុំ ៤៥ អង្សារ



-បន្តបត់ផ្នែកខាងលើឱ្យត្រូវតាមជ្រុងបត់



-បត់វាពីលើមួយជាន់ទៀត បន្ទាប់មកត្រូវបិទស្កុតតាមជ្រុងនីមួយៗនៃថង់



-បន្ទាប់មកត្រូវបន្តបិទស្កុតពីលើស្លាមបត់នោះទាំងមូល



-បិទស្កុតថង់ឱ្យបានត្រឹមត្រូវ



-សរសេរបំពេញលើស្លាកសញ្ញាសំគាល់វត្ថុតាង រួចប្រគល់ឱ្យមន្ត្រីកាន់កាប់វត្ថុតាង



## បច្ចេកទេសក្នុងការប្រមូលវត្ថុតាងដែលមុតស្រួច

-ដាក់វាចូលក្នុងដបផ្លាស្ទិករឹង




-បន្ទាប់មក ដាក់ចូលក្នុងថង់ដាក់វត្ថុតាង ហើយប្រគល់ឱ្យមន្ត្រីកាន់កាប់វត្ថុតាង



# បច្ចេកទេសក្នុងការប្រមូលវត្ថុតាង ដា ឌី អ៊ិន អេ

-ពាក់ស្រោមដៃ និងម៉ាសបិទមុខ ប្រើសំឡីចាប់យកសំណាកឈាមនោះ




-ប្រសិនបើស្ងួត ត្រូវប្រោសទឹកស្តេរីលបន្តិចពីលើស្លាមសំណាកនោះដើម្បីផ្សើមវា និងដើម្បីឱ្យដានស្លាមនោះត្រឡប់មកវិញ ។ ដាក់សំឡីនោះចូលក្នុងប្រអប់តូចមួយ



-ធ្វើការបិទប្រអប់តូចនោះឱ្យជិត





-ដាក់វត្ថុតាងនោះចូលក្នុងថង់ដាក់ភស្តុតាង




-ដើម្បីបិទមាត់ថង់ឱ្យជិត បកខ្សែនៅលើមាត់ថង់ នឹងឃើញបន្ទាត់ស្អិតមួយ



-បិទមាត់ថង់ដាក់ភស្តុតាងនោះ ដោយបត់ផ្នែកខាងលើ ចំខាងក្រោមដែលមានជាតិស្អិត






-សរសេរជាភាសាខ្មែរ បំពេញលើស្លាកសញ្ញាសំគាល់វត្ថុតាង ហើយបិទពីលើថង់ដាក់វត្ថុតាង រួចប្រគល់ឱ្យមន្ត្រីកាន់កាប់វត្ថុតាង



<u>**បច្ចេកទេសក្នុងការប្រមូលវត្ថុតាងដែលជា ដំណក់ទឹកកាមលើស្រោមអនាម័យ**</u>

**-ចាប់យកវាដោយប្រើដង្កៀប ហើយដាក់ចូលទៅក្នុងដបស្តែរីលដាក់វត្ថុតាងមួយ**




**-ធ្វើការបិទគម្របដបនោះ**



-បិទស្កុតគ្រប់កន្លែងមូលរវាងគម្រប និងដប ដើម្បីការពារការជ្រាប



-ដាក់ដបនោះចូលទៅក្នុង ថង់ដាក់ភស្តុតាង



-ធ្វើដូចពីមុន  គឺបិទស្លាកផ្លាកស្ទិកមាត់ថង់  ហើយសរសេរបំពេញជាភាសាខ្មែរលើស្លាក
សញ្ញាសំគាល់វត្ថុតាងនោះ រួចបិទវាភ្ជាប់ពីចំហៀង មុននឹងប្រគល់ឱ្យមន្ត្រីគ្រប់គ្រងវត្ថុតាង



| វត្ថុតាង | កន្លែងដែលអាចរកឃើញឌី អិន អេ លើវត្ថុតាង | ប្រភព ឌី អិន អេ |
|---|---|---|
| ដំបងវាយបាល់ ឬប្រហាក់ប្រហែលនឹងអាវុធ | កន្លែងចាប់កាន់ ឬចុង | ញើស ស្បែក ឈាម ក្រដាសអនាម័យ |
| មួក កន្សែងដៃធំ ឬម៉ាសបិទមុខ | ខាងក្នុង | ញើស សក់ អង្គែ |
| វ៉ែនតា | ផ្នែកនៃច្រមុះ ត្រចៀក ឡង់ទីយ៍ | ញើស ស្បែក |
| ក្រដាសជូតមុខ សំឡី | តំបន់ផ្ទៃ | សំបោរ ឈាម ញើស ទឹកមាត់ ឬអាចម៍ច្រចៀក |
| ប្រដាប់បោកគក់ | តំបន់ផ្ទៃ | ឈាម ញើស ទឹកកាម |
| ឈើចាក់ធ្មេញ | ជុង | ទឹកមាត់ |
| ត្រា ឬ ស្រោមសំបុត្រ | កន្លែងកាន់ | ទឹកមាត់ |
| បារីដែលបានប្រើប្រាស់ | ចានគោះបារី | ទឹកមាត់ |
| ដប ចាន ឬកែវ | ផ្នែកខាង ឬកន្លែងដាក់មាត់ | ទឹកមាត់ ញើស |
| ស្រោមអនាម័យដែលប្រើរួច | ខាងក្នុង ឬខាងក្រៅស្រោម | ទឹកកាម កោសិការវ៉ាហ្សីណាល់ ឬពោះវៀន |
| ភួយ ខ្នើយ កម្រាល | លើផ្ទៃ | ញើស សក់ ទឹកកាម ទឹកនោម ទឹកមាត់ |
| ស្នាមខាំ | ស្បែក ឬសំលៀកបំពាក់ | ទឹកមាត់ |
| ក្រចកដៃ ឬបំណែកក្រចកដៃ | កន្លែងខ្មៅ | ឈាម ញើស ក្រដាសអនាម័យ |